ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- "ឃ្លាតទៅសែនឆ្ងាយ"
- ការឈានទៅរកការកាត់ទោសខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣៣ ខែមករា ឆ្នាំ២០១១

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៣៣ ខែមករា ឆ្នាំ២០១១

## មាតិកា

◆"ឃ្លាតទៅសែនឆ្ងាយ" ........................................១

**ផ្នែកឯកសារ**

◆ឈូក ផុន : យុទ្ធជនភូមិភាគបូព៌ា ........................................៤

◆អោម រីម : ខ្មែរក្រហមពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ ........................................៨

◆ជីវិតរបស់ អ៊ឹម វ៉ាន់ថា ........................................១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆មិនអាចរស់នៅជាមួយជនដៃដល់នៅក្នុងភូមិ ........................................១៤

◆ក្រោយខ្មែរក្រហមឡើងកាន់កាប់អំណាច ........................................១៦

◆ស្អប់ខ្មែរក្រហម ........................................១៩

◆ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា ........................................២០

**ផ្នែកច្បាប់**

◆ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាល ........................................៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ........................................៤០

◆ការឈានទៅរកការកាត់ទោសខ្មែរក្រហម........................................៤២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆វិញ្ញាណចងចាំ ........................................៤៧

◆ការឈឺចាប់បានរសាយ ........................................៥៥

◆ការរួចរស់ជីវិតពីសង្គ្រាម ........................................៥៧

◆ជីតារបស់ខ្ញុំបង្អត់បាយខ្លួនឯង........................................៦០



ជនជាតិអ៊ីស្លាមស្តាប់ការពន្យល់របស់វាគ្មិនបកស្រាយពីអំពើប្រល័យពូជសាសន៍

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ឌី ខាំបូលី, លី សុខចំរើន, សេង គន្ធី, សូ ហ្វារីណា, មេហ្គេន ខាស, ឡូរ៉ា វីលីម, ប៉ែត វ៉ាន់ស្កាក់, ថៃ ច័ន្ទរិទ្ធ, ស សេងគា **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ជា ផល្លា **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ទេព ម៉េងឃាន, ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# "ឃ្លាតទៅសែនឆ្ងាយ"

## អំណាចនៃសេចក្តីស្នេហាចំពោះការស្រឡាញ់សម្រាប់ការផ្សះផ្សា និងការអប់រំ

ក្នុងនាមជាអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ ខ្ញុំគាំទ្រទាំងស្រុងនូវខ្សែភាពយន្តដែលផលិតដោយលោក ឆាយ បូរ៉ា អំពីរបបខ្មែរក្រហមមានចំណងជើងថា «ឃ្លាតទៅសែនឆ្ងាយ» ។ ខ្សែភាពយន្តនេះបានបង្ហាញពីភាពលំបាកវេទនាទុក្ខព្រួយ ជីវិតគ្រោតគ្រាតក្នុងសម័យខ្មែរក្រហម ប៉ុន្តែវាពោរពេញទៅដោយទេសភាពស្រស់ស្អាតបំព្រង និងអំណាចនៃសេចក្តីស្នេហាចំពោះការស្រឡាញ់ ។ អ្នកអាចមើលឃើញទឹកភ្នែករបស់អ្នកនៅពេលដែលអ្នកយំ ។ មានមូលហេតុមួយចំនួនដែលធ្វើឲ្យខ្សែភាពយន្តនេះមានលក្ខណៈពិសេស ។

ទីមួយ ខ្សែភាពយន្តនេះបានបង្ហាញពីភាពក្លាហាន ទុក្ខវេទនា និងការឈឺចាប់ដែលមិនអាចពិពណ៌នាបានរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមដោយភាពស្មោះត្រង់ សាមញ្ញ និងអត់ឱន ។ ដោយផ្អែកលើរឿងរ៉ាវពិតរបស់ម្តាយក្មេកលោក ឆាយ បូរ៉ា ដែលមានឈ្មោះថា លាវ សិលា (អមរា) ខ្សែភាពយន្តនេះអាចបង្ហាញពីអារម្មណ៍ពិតដែលកើតឡើងនៅក្នុងរបបនោះដោយប្រើប្រាស់តែម៉ាស៊ីនថតមួយនិងថវិកាសមល្មមប៉ុណ្ណោះ ។ ពោរពេញទៅដោយការឈឺចាប់និងការឆ្ពោះទៅមុខ ខ្សែភាពយន្តនេះបានបង្ហាញពីរឿងរ៉ាវរបស់ អមរា និងការតស៊ូរបស់គាត់ដើម្បីរួចផុតពីរបបខ្មែរក្រហមដ៏ព្រៃផ្សៃ ។ ដោយមកពីវណ្ណៈកណ្តាលរស់នៅទីក្រុងភ្នំពេញ អមរា និងគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមឲ្យឈ្មោះថា «ប្រជាជន១៧មេសា» និងចាត់ទុកថាជាសមាសភាពពុករលួយ ខ្ជិលច្រអូស និងគ្រោះថ្នាក់ដល់បក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងខ្សែភាពយន្ត អមរា បានប្រឈមមុខនឹងការឈឺចាប់ដែលបណ្តាលមកពីការស្លាប់របស់សមាជិកគ្រួសារមួយចំនួនរបស់គាត់ កូនរបស់គាត់ និងស្ត្រីចំណាស់ម្នាក់ដែលគាត់បានរាប់អាននៅក្នុងរបបនោះ ។ ទោះបីជាគាត់បានជួបប្រទះនូវការឈឺចាប់ដោយសារការបាត់បង់ក៏ដោយ ក៏គាត់អាចធ្វើដំណើរឆ្ពោះទៅមុខនៅក្នុងជីវិតដែរ ។ តាមរយៈរឿងរ៉ាវរបស់ អមរា ខ្សែភាពយន្តនេះបានបង្ហាញពីភាពក្លាហាន និងភាពរឹងមាំរបស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។ «ឃ្លាតទៅសែនឆ្ងាយ» គឺជាខ្សែភាពយន្តអំពីអ្នកជាទីស្រឡាញ់របស់ប្រជាជនកម្ពុជាទាំងអស់ ។


អមរា នៅក្នុងខ្សែភាពយន្តរឿង «ឃ្លាតទៅសែនឆ្ងាយ»

ទីពីរ ខ្សែភាពយន្តនេះបានផ្តល់សំឡេង និងការលើកទឹកចិត្តដល់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយដែលមិនអាច ឬមានការលំបាកក្នុងការនិយាយអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន ។ ទោះបីជាជនរងគ្រោះនៃរបបខ្មែរក្រហមមានចំនួនរាប់លាននាក់ក៏ដោយ ក៏មនុស្សជាច្រើននៅតែមានអារម្មណ៍ថាខ្លួនរងទុក្ខ និងមានការឈឺចាប់តែម្នាក់ឯង ។ វាគឺជាលទ្ធផលនៃភាពស្ងប់ស្ងាត់អស់រយៈពេលជាច្រើនទសវត្សរ៍ ពោលគឺភាពស្ងប់ស្ងាត់ដែលជាគោលនយោបាយផ្លូវការមួយ ហើយត្រូវបានសង្គមរក្សាទុក ។ នៅកម្រិតជាតិគឺមិនមានការចែករំលែកការឈឺចាប់ ឬនិយាយបើកចំហនូវរឿងរ៉ាវសោកនាដកម្មរបស់នរណាម្នាក់ឡើយ ។ ខ្ញុំយល់ថា ប្រជាជនកម្ពុជាមានការមមាញឹកក្នុងដំណើរជីវិតដែលមិនមានពេលតស៊ូក្នុងការធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីឆ្លុះបញ្ចាំងនិងផ្សះផ្សា ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវដោះស្រាយនឹងសង្គ្រាមស៊ីវិល ការថ្កោលទោសពីអន្តរជាតិ អំពើហិង្សាសង្គម ការបោះឆ្នោត និងការតស៊ូក្នុងជីវិតថ្មី ។ នៅមានប្រជាជនជាច្រើនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ ការចិញ្ចឹមបីបាច់និងថែទាំខ្លួនឯងនិងគ្រួសារ គឺជាអត្ថិភាពចម្បងមុននឹងដំណើរការ

ប្រឈមមុខនឹងអតីតកាលដ៏អាក្រក់របស់ខ្លួន ។ បទពិសោធន៍ដែលបានបង្ហាញនៅក្នុងខ្សែភាពយន្តរួមមាន ភាពអត់ឃ្លាន ការនឿយហត់ ការបំបែកចេញពីគ្រួសារនិងការបាត់បង់សមាជិកគ្រួសារបានកើតឡើងចំពោះជនរងគ្រោះគ្រប់រូប ។ ខ្សែភាពយន្តនេះបានផ្តល់ចន្លោះទំនេរមួយដល់ប្រជាជនឲ្យចងចាំ ចាប់ផ្តើមមានអារម្មណ៍យល់និងស្រង់យកបទពិសោធន៍នៃសោកនាដកម្មរបស់ខ្មែរក្រហម ។ ទស្សនៈនេះកើតចេញដោយផ្ទាល់ពីបេះដូង និងដួងវិញ្ញាណរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដូច្នេះវាមានលទ្ធភាពអាចបង្ហាញចេញមកក្រៅ ។ អាស្រ័យហេតុនេះអ្នកដែលនៅរស់រានជីវិតដែលពិបាកនឹងប្រឈមមុខនឹងអតីតកាលអាចមើលខ្សែភាពយន្តនេះ ហើយបង្កើតអារម្មណ៍សាមគ្គីរបរួមពីការផ្សះផ្សាគ្នា ។ ជាងនេះទៅទៀត បន្ទាប់ពីមើលខ្សែភាពយន្តនេះ អ្នកទាំងនោះនឹងដឹងថា វាមានសារសំខាន់ក្នុងការចងចាំ ហើយការសម្រក់ទឹកភ្នែកគឺជារឿងធម្មតា ។ ទាំងនេះគឺជាមធ្យោបាយដែលអាចជួយដល់ប្រជាជនដោះស្រាយនឹងអតីតកាលបាន ។

ទីបី «ឃ្លាតទៅសែនឆ្ងាយ» អាចដើរតួនាទីមួយក្នុងការអប់រំយុវជនកម្ពុជាជំនាន់ក្រោយអំពីរបបខ្មែរក្រហមដែលធ្វើឲ្យអ្នកទាំងនោះអាចយល់ និងជឿទៅលើបទពិសោធន៍របស់ឪពុកម្តាយព្រមទាំងសិក្សាពីផ្នែកសំខាន់មួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ។ ដូច្នេះ ខ្សែភាពយន្តនេះនឹងបន្តបេសកកម្មដ៏សំខាន់ក្នុងការអប់រំយុវជនដែលកើតក្រោយរបបខ្មែរក្រហមមិនឲ្យប្រព្រឹត្តដូចអតីតកាលម្តងទៀត ។ ទោះបីជាយុវជនខ្លះនៅតែមិនព្រមជឿក៏ដោយ អ្នកដែលនៅរស់រានមានជីវិតត្រូវតែបន្តអប់រំយុវជនទាំងអស់នោះបន្តទៀត ។ លោក ឆាយ បូរ៉ា បាននិយាយថា អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមមិនត្រូវបណ្តោយទៅតាមការមិនជឿរបស់យុវជនជំនាន់ក្រោយទេ ។ អ្នកដែលនៅរស់រានជីវិតពីរបបខ្មែរក្រហមមិនគួរបាក់ទឹកចិត្តនឹងការមិនជឿរបស់យុវជនជំនាន់ក្រោយឡើយ ផ្ទុយទៅវិញការមិនជឿនេះគួរតែជំរុញឲ្យអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែបន្តប្រាប់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមថែមទៀត ។

ជាងនេះទៅទៀត ខ្សែភាពយន្តនេះក៏អាចជួយជំរុញឲ្យមានការយល់ដឹង ការយល់ចិត្ត និងការផ្សះផ្សារបស់យុវជន











កម្ពុជាដែលកំពុងមានបញ្ហាក្នុងសង្គម ។ សារសំខាន់របស់វាគឺមានលក្ខណៈសាមញ្ញ ប៉ុន្តែពោរពេញដោយអំណាច ៖ ទោះបីជាបទពិសោធន៍នៃរបបខ្មែរក្រហមគួរឲ្យរន្ធត់ដល់កម្រិតណាក៏ដោយ ក៏យើងត្រូវតែដឹង និងចងចាំដើម្បីការចងចាំ យុត្តិធម៌ និងសន្តិភាពនៅអនាគត ។ យុវជនកម្ពុជាជំនាន់ក្រោយត្រូវតែឮសារនេះ ។ យុវជនត្រូវតែមានទំនាក់ទំនងខ្លាំងជាមួយឪពុកម្តាយ និងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត ។ ហេតុផលមួយចំនួនដូចជា ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ប្រព័ន្ធអប់រំខ្សោយ ភាពជាកុមារកំព្រា ការរំលោភ វប្បធម៌នៃអំពើពុករលួយ ភាពបែកបាក់នៃស្នេហាយុវជន គំរូអាក្រក់ក្នុងសង្គមផ្សេងទៀត បានធ្វើឲ្យយុវជនកម្ពុជាមិនមានការទទួលខុសត្រូវ មិនត្រូវបានគេឲ្យតម្លៃ ញៀនថ្នាំ ប្រព្រឹត្តបទល្មើសហិង្សា ឬបោះបង់ការសិក្សា ។ ខ្សែភាពយន្ត «ឃ្លាតទៅសែនឆ្ងាយ» អាចជួយដល់យុវជនដែលមានបញ្ហាទាំងនេះ ពីព្រោះវាអាចបង្ហាញថា ទោះបីជាឪពុកម្តាយ និងជីដូនជីតារបស់ខ្លួនបានឆ្លងកាត់ការលំបាកជាច្រើនយ៉ាងណាក៏ដោយ គាត់នៅតែមានភាពក្លាហានយកឈ្នះទៅលើអ្វីដែលបានកើតឡើងជានិច្ច ។ ខ្សែភាពយន្តនេះមិនអាចជួយដោះស្រាយគ្រប់បញ្ហាទេ ប៉ុន្តែវាមានសក្តានុពលអាចបង្កើតទំនាក់ទំនងដែលត្រូវតែមានរវាងយុវជនដែលកំពុងមានបញ្ហាក្នុងសង្គម និងអ្នកដែលនៅរស់រានមានជីវិត ជាពិសេសគឺឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ។

ខណៈពេលដែលខ្សែភាពយន្ត «ឃ្លាតទៅសែនឆ្ងាយ» គឺជាផលិតកម្មសាមញ្ញមួយ វាបានផ្តល់ជាសារមួយដែលពោរពេញដោយអំណាចនិងអារម្មណ៍ស្មោះត្រង់ ។ ពីជនរងគ្រោះម្នាក់ទៅជនរងគ្រោះម្នាក់ ខ្សែភាពយន្តនេះអាចជួយបង្កើតការចែករំលែកការឈឺចាប់ ការរស់នៅនិងភាពខ្លាំង ។ វាអាចជួយដល់អ្នកដែលនៅរស់រានមានជីវិតមានបញ្ហាមិនអាចប្រឈមមុខនឹងអតីតកាលដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម និងអប់រំយុវជនដែលកើតនៅក្រោយរបបនោះអំពីផ្នែកដ៏សំខាន់មួយរបស់ឪពុកម្តាយ និងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ។ ខ្សែភាពយន្តនេះគួរតែយកទៅបង្ហាញនៅគ្រប់សាលារៀន និងភូមិ-ស្រុកទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។ **ឆាំង យុ**






# ឈូក ផុន យុទ្ធជនភូមិភាគបូព៌ា


ឈូក ផុន

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យុទ្ធជនគ្រប់រូបមានតួនាទីសំខាន់ណាស់ក្នុងការកសាងប្រទេស និងប្រយុទ្ធការពារបូរណភាពទឹកដីរបស់កម្ពុជា ។ ក្រោយពេលខ្មែរក្រហមមានទំនាស់បញ្ហាព្រំដែនភាគខាងកើតជាមួយនឹងប្រទេសវៀតណាម មេដឹកនាំខ្មែរក្រហមបានជំរុញនិងលើកទឹកចិត្តឲ្យយុទ្ធជនទាំងនេះទៅប្រយុទ្ធប្តូរផ្តាច់ជាមួយនឹងកងទ័ពវៀតណាមបណ្តាលឲ្យយុទ្ធជនស្លាប់និងរងរបួសយ៉ាងច្រើននៅសមរភូមិ ។ ចំណែកអ្នកនៅរស់ជីវិតខ្លះបានក្លាយជាជនរងគ្រោះ ដោយសារមេដឹកនាំខ្មែរក្រហមសង្ស័យថា «បានទាក់ទងនិងរាយការណ៍ទៅឲ្យវៀតណាម» និងចោទថា «ក្បាលយួនខ្លួនខ្មែរ» ហើយក្រោយមកយុទ្ធជនទាំងនោះត្រូវបានចាប់ខ្លួន និងសម្លាប់ចោលម្តងទៀត ។ ជាក់ស្តែង ផុន បានចូលបដិវត្តន៍តាំងពីអាយុ១៩ឆ្នាំ នៅឃុំកំពង់អម្ពិល ដោយគាត់មានតួនាទីយាមការពារភូមិ ។ ក្រោយមកខ្មែរក្រហមបានបញ្ជូន ផុន ឲ្យទៅវាយជាមួយនឹងកងទ័ពវៀតណាមនៅសមរភូមិក្នុងស្រុករំដួល ខេត្តស្វាយរៀង រហូតរងរបួសបាក់ជើងម្ខាង និងស្ទើរតែបាត់បង់ជីវិតថែមទៀត ។

ឈូក ផុន អាយុ៥៥ឆ្នាំ កើតនៅភូមិបឹង ឃុំកំពង់អម្ពិល ស្រុករំដួល ខេត្តស្វាយរៀង ។ ផុន ចូលរៀននៅសាលាបឋមសិក្សាទួលច្រេះ ដែលមានអគារបីខ្នង និងប្រាំបួនបន្ទប់ ដោយទទួលសិស្សមកពីគ្រប់ភូមិក្នុងឃុំបឹងឲ្យចូលរៀន ។ ចំណែកគ្រូបង្រៀនភាគច្រើនមកពីក្រុងស្វាយរៀង និងមកពីខេត្តសៀមរាប ។ ផុន រៀនបានត្រឹមថ្នាក់ទី១ (ត្រួតថ្នាក់) ក៏ឈប់រៀន ព្រោះមានកម្លាំងតស៊ូចូលមកបំផុសប្រជាជនក្នុងភូមិ ម្យ៉ាងទៀតឪពុកម្តាយគាត់ពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបង់ថ្លៃសាលា និងទិញសម្ភារឲ្យគាត់សិក្សាផង ។ ទោះបី ផុន រៀននៅសាលារយៈពេលតែពីរឆ្នាំក៏ដោយ ក៏គាត់អាចអានអក្សរបានខ្លះៗដែរ ព្រោះជំនាន់នោះគាត់រៀនពីរវេន (ព្រឹកនិងល្ងាច) ។ ក្រោយពីឈប់រៀន ផុន បានមកជួយធ្វើស្រែចម្ការឪពុកម្តាយ ។

ផុន រៀបរាប់ថា នៅឆ្នាំ១៩៧១ កងទ័ពវៀតកុងដែលមានកាន់អាវុធគ្រប់ដៃបានចូលមកក្នុងភូមិ រួចហើយសុំផ្ទះប្រជាជនដើម្បីបែងចែកកម្លាំងទ័ពរបស់គេឲ្យរស់នៅជាមួយ ។ កងទ័ពវៀតកុងខ្លះចេះនិយាយភាសាខ្មែរ ចំណែកអ្នកដែលមិនចេះនិយាយភាសាខ្មែរបានប្រើកាយវិការដើម្បីទំនាក់ទំនងជាមួយអ្នកភូមិ ។ កងទ័ពវៀតកុងបានជ្រើសរើសផ្ទះប្រជាជនណាដែលមានទីធ្លាធំទូលាយសម្រាប់ជួបប្រជុំនិងហូបបាយរួម ។ ប៉ុន្តែកងទ័ពទាំងនោះស្នាក់នៅជាមួយប្រជាជនក្នុងភូមិបានរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ ក៏ដកចេញទៅវិញអស់ ។ ក្រោយមក ទើប ផុន ដឹងតាមរយៈចាស់ៗក្នុងភូមិប្រាប់គាត់ថា កងទ័ពវៀតកុងទាំងនោះមកវាយ លន់ នល់ ។ ផុន បន្តថា ដោយសារភូមិដែលគាត់រស់នៅឆ្ងាយពីក្រុងស្វាយរៀង ទើបកងកម្លាំង លន់ នល់ ចូលទៅមិនដល់ ហើយគាត់ក៏ពុំដឹងថាកម្លាំងខាងណាមកគ្រប់គ្រងច្បាស់លាស់ដែរ ។

រហូតមកដល់ឆ្នាំ១៩៧៣ កម្លាំងតស៊ូខ្មែរក្រហមបានចូលមកក្នុងភូមិកាន់តែច្រើន រួចហើយដើរឃោសនាតាមផ្ទះប្រជាជនឲ្យចូលរួមជាមួយចលនាបដិវត្តន៍របស់គេ ។ នៅពេលនោះខ្មែរក្រហមបានជ្រើសរើសភូមិចាស់ៗដែលមានម្លប់ឈើធ្វើជាទីតាំងហ្វឹកហាត់ទាហានរបស់ខ្លួន ។ ក្រោយមក ខ្មែរក្រហមបានជ្រើសរើសប្រុសៗជាអ្នកភូមិឲ្យចូលហ្វឹកហាត់បន្ថែមទៀត ។ នៅក្នុងភូមិ ខ្មែរក្រហមតែងតែរាក់ទាក់ និងនិយាយពាក្យគួរសមជាមួយអ្នកភូមិថា ពុកម៉ែបងប្អូនជានិច្ច រហូតធ្វើឲ្យអ្នកភូមិខ្លះជួយឧបត្ថម្ភស្បៀងអាហារ ស្រូវ អង្ករដល់ចលនាតស៊ូនោះទៀតផង ។ ប៉ុន្តែមួយរយៈក្រោយ

មក ខ្មែរក្រហមចាប់ផ្ដើមរឹតបន្តឹងការធ្វើដំណើររបស់ប្រជាជនពីតំបន់រំដោះដែលខ្លួនគ្រប់គ្រងចូលទៅក្នុងតំបន់ដែល លន់ នល់ គ្រប់គ្រងដូចជា ផ្សារកំពង់ចក (ស្ថិតក្នុងទីរួមស្រុករំដួល) និងក្រុងស្វាយរៀងជាដើម ។ នៅពេលនោះ គ្រូបង្រៀនម្នាក់ដែលរស់នៅក្នុងភូមិបានជូនកូនស្រីទៅជួបប្ដីដែលធ្វើការនៅក្រុងស្វាយរៀង ត្រូវឈ្លបខ្មែរក្រហមដេញតាមបាញ់ពីក្រោយ ប៉ុន្តែសំណាងល្អមិនត្រូវចំគាត់ ។ ជារឿយៗ ផុន បានឮសំឡេងវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់ នៅក្បែរទីរួមខេត្ត ។

នៅឆ្នាំ១៩៧៤ មេឃុំកំពង់អម្ពិល (ខ្មែរក្រហមទើបជ្រើសតាំងថ្មី) បានជ្រើសរើស ផុន និងក្មេងៗក្នុងភូមិប្រមាណជា១០នាក់ទៀតឲ្យចូលបម្រើបដិវត្តន៍ ដោយប្រាប់គាត់ថា «ទៅធ្វើឈ្លបការពារភូមិ» ។ ទៅដល់ឃុំដំបូង មេឃុំមិនបានប្រើ ផុន ឲ្យធ្វើការងារអ្វីទេ គឺឲ្យគាត់ដើររកត្រីមកផ្គត់ផ្គង់អង្គភាពឃុំដែលមានសមាជិកសរុបទាំងអស់ប្រមាណជា២០នាក់ ។ ក្រោយមក ផុន បានរៀនបាញ់កាំភ្លើង ដោះកាំភ្លើង និងលាងកាំភ្លើងជាមួយឈ្លបឃុំ ប៉ុន្តែគាត់មិនបានរៀនក្បួនយុទ្ធសាស្ត្រអ្វីផ្សេងទៀតទេ ។ តមកទៀត ខ្មែរក្រហមបានបញ្ចូល ផុន ទៅក្នុងកង «គ២» ដែលមានទាហានសរុបទាំងអស់ចំនួន១២០នាក់ ក្រោមការគ្រប់គ្រងរបស់លោក ព្រំ គិន (អតីតអភិបាលខេត្តពោធិ៍សាត់) ។

នៅឆ្នាំ១៩៧៥ ផុន ទទួលដំណឹងតាមវិទ្យុផ្សាយថា កងទ័ពខ្មែរក្រហមទទួលជ័យជម្នះហើយ ។ មួយរយៈក្រោយមក ផុន ឃើញខ្មែរក្រហមជម្លៀសប្រជាជនពីទីក្រុងស្វាយរៀង និងផ្សារកំពង់ចករាប់រយនាក់មកដាក់នៅក្នុងវត្តមួយ (ស្ថិតក្នុងភូមិរបស់គាត់) រួចហើយបែងចែកប្រជាជនទាំងនោះឲ្យទៅលើកភ្លឺស្រែ និងជីកប្រឡាយ ។ ចំណែកប្រជាជនខ្លះទៀតត្រូវកងសន្តិសុខចងបណ្ដើរមួយលើកៗប្រមាណជា២០នាក់យកចេញទៅបាត់ ។

រហូតដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចោទវៀតណាមថា «ឈ្លានពានទឹកដីកម្ពុជា» ហើយបានបញ្ជូន ផុន ឲ្យទៅវាយជាមួយនឹងវៀតណាម ។ ប៉ុន្តែក្រោយមក ដោយសារ ផុន មានវ័យក្មេងជាងគេ ទើបមេបញ្ជាការដកឲ្យមកនៅក្នុងកងដឹកជញ្ជូនបាយសម្រាប់កងទ័ពវិញ ។ ផុន បន្តថា នៅពេលវាយប្រយុទ្ធគ្នានោះបណ្ដាលឲ្យទាហានខ្មែរក្រហមស្លាប់រាប់រយនាក់ ហើយសាកសពទាំងអស់ត្រូវខ្មែរក្រហមដឹកមកកប់នៅគោកស្រម៉ និងនៅខាងកើតព្រះវិហារវត្តទួលសាលា ។ ពេលនោះ ទោះបីមានទាហានស្លាប់ច្រើនយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែបញ្ជូនកងទ័ពឲ្យទៅវាយជាមួយវៀតណាមដែរ ហើយពេលខ្លះខ្មែរក្រហមវាយចូលដល់ខេត្តរោងដំរីក្នុងទឹកដីវៀតណាមទៀតផង ។ ប៉ុន្តែរយៈពេលពីរបីថ្ងៃក្រោយមក ក៏ត្រូវកងទ័ពវៀតណាមវាយរុញច្រានទាហានខ្មែរក្រហមមកដល់ព្រំដែនខ្មែរវិញ ។

នៅឆ្នាំ១៩៧៨ ពេលកងទ័ពវៀតណាមចូលមក ផុន និងទាហានខ្មែរក្រហមពីរនាក់ទៀតបានរត់ចូលក្នុងរណ្ដៅត្រង់សេ ។ មួយសន្ទុះក្រោយមក ផុន សម្រេចចិត្តរត់គេចខ្លួនទៅទិសខាងជើងវិញ ប៉ុន្តែត្រូវមិត្តភក្តិនៅទីនោះឃាត់ឲ្យរង់ចាំគ្នាសិន ។ ខណៈនោះស្រាប់តែកងទ័ពវៀតណាមផ្លោងចូលមកត្រូវលេណដ្ឋានដែល ផុន ពួនក៏បណ្ដាលឲ្យ ផុន បាក់ជើង មិត្តភក្តិម្នាក់ដែលរស់នៅក្នុងឃុំស្វាយចេកបានស្លាប់ ចំណែកម្នាក់ទៀតដែលនៅក្រៅលេណដ្ឋានបានរួចផុតពីគ្រោះថ្នាក់នេះ ។ ខ្មែរក្រហមបានបញ្ជូន ផុន មកមន្ទីរពេទ្យស្រុកសំរោងស្ថិតក្នុងវត្តស្វាយចេក (បច្ចុប្បន្ន ឃុំស្វាយចេក ស្រុករំដួល) ទើបបញ្ជូនបន្តទៅមន្ទីរពេទ្យតំបន់២៣ សព្វថ្ងៃ មន្ទីរពេទ្យបង្អែកស្វាយរៀង) ក្នុងក្រុងស្វាយរៀង ។ មកដល់ដំបូង ផុន ឃើញប្រជាជន និងទាហានដែលត្រូវរបួសជាច្រើនចូលមកព្យាបាលនៅមន្ទីរពេទ្យនេះដែរ ប៉ុន្តែពេលនោះពេទ្យបានបែងចែកអ្នកជំងឺស៊ីវិល និងទាហានឲ្យនៅដាច់ពីគ្នា ។ ចំណែកម្ដាយ និង បងស្រី ផុន ក្រោយពីដឹងថា ផុន នៅមន្ទីរពេទ្យ គាត់ក៏ធ្វើដំណើរមកសួរសុខទុក្ខ ផុន ប៉ុន្តែមកដល់ភូមិព្រៃគាវក៏ត្រូវកងទ័ពខ្មែរក្រហមឃាត់ ។ ពេលនោះ ដោយសារនឹកអាណិតកូននិងប្អូន ម្ដាយនិងបងស្រី ផុន បានជិះកង់គេចតាមផ្លូវវាងរហូតបានមកជួប ផុន នៅមន្ទីរពេទ្យរយៈពេលតែមួយម៉ោងប៉ុណ្ណោះក៏ត្រូវគ្រូពេទ្យឲ្យត្រឡប់ទៅផ្ទះវិញ ។ នៅទីនោះ ទោះបីគ្មានបងប្អូននៅថែទាំក៏ដោយ ក៏ពេទ្យបានយកចិត្តទុកដាក់ព្យាបាលជំងឺ ផុន ដែរ ប៉ុន្តែរយៈពេលមួយខែក្រោយមកដោយសារជើងរបស់គាត់នៅតែហើមធំ ទើបពេទ្យបញ្ជូនគាត់ជាមួយនឹងអ្នកជំងឺធ្ងន់៤នាក់ទៀតមកវះកាត់នៅមន្ទីរពេទ្យ៧មេសា (បច្ចុប្បន្ន មន្ទីរពេទ្យរុស្ស៊ី) ក្រុងភ្នំពេញ ។

បន្ទាប់ពី ផុន បានធូរស្បើយទើបពេទ្យបញ្ជូនឲ្យទៅស្នាក់

នៅមន្ទីរពេទ្យ១៧ មេសា (បច្ចុប្បន្ន មន្ទីរពេទ្យកាល់ម៉ែត្រ) ។ នៅទីនោះ ដុន ឃើញមានគ្រូពេទ្យជនជាតិចិននៅចាំព្យាបាលអ្នកជំងឺដែលសុទ្ធសឹងជាកងទ័ព ។ នៅពេលមានការវះកាត់អ្នករបួសធ្ងន់ធ្ងរទើប ដុន ឃើញ អៀង ធីរិទ្ធ និងដុកទ័រ ដួន ជឿន ចូលមកពិនិត្យ និងរៀបចំវះកាត់អ្នកជំងឺ ។ ប៉ុន្តែបើ ដុកទ័រ ដួន ជឿន អវត្តមាន ត្រូវគ្រូពេទ្យចិនមកវះកាត់ជំនួសវិញ ។ ដុន បានបន្តថា នៅទីនោះអ្នកជំងឺអាចនិយាយពីរឿងវាយខ្មាំង និងសមរភូមិប្រយុទ្ធបាន ប៉ុន្តែមិនត្រូវនិយាយឲ្យប៉ះពាល់ដល់អង្គការទេ ព្រោះមានអ្នកចាំតាមដានជានិច្ច ។ ក្រោយមក ដុន ឃើញខ្មែរក្រហមយកឡានមកដឹកអ្នកជំងឺម្នាក់ចេញទៅបាត់ ពេលនោះ ដុន ក៏លួចសួរពេទ្យនៅទីនោះ ទើបគេប្រាប់ថា «អ្នកជំងឺនោះអង្គការយកទៅកសាង» ហើយ ។ ចាប់តាំងពីពេលនោះមក ដុន ចាប់ផ្តើមមានអារម្មណ៍ភ័យខ្លាច ហើយម្យ៉ាងទៀតដោយសារមិនចង់ឃើញអ្នកជំងឺដែលពេទ្យដឹកជញ្ជូនចូលមករាល់ថ្ងៃ ទើបគាត់សុំសំបុត្រពេទ្យត្រឡប់ទៅស្រុកវិញ ។

ពេទ្យបានជូន ដុន និងអ្នកជំងឺប្រមាណជា២០នាក់ទៅដាក់នៅផ្សារសួងរយៈពេលមួយសប្តាហ៍ក្រោយ ទើប ដុន សុំរទេះសេះជិះបន្តមកខេត្តស្វាយរៀងទៀត ប៉ុន្តែ ដុន មិនបានទៅចូលបម្រើកងទ័ពទេ គឺគាត់គេចមករស់នៅក្នុងភូមិវិញ ។ មកដល់ផ្ទះ ដុន បានជួបតែបងស្រីទីបីនិងឪពុកម្តាយប៉ុណ្ណោះ ចំណែកបងទីពីរបានស្លាប់និងបងទី១ធ្វើទាហាន លន់ នល់ និងគ្រួសារនៅភ្នំពេញបានបាត់ដំណឹងចាប់តាំងពីឆ្នាំ១៩៧៥ម្ល៉េះ ។ ក្រោយមក ប្រធានភូមិបានចាត់តាំង ដុន ឲ្យទៅជីកព្រែក និងលើកទំនប់ជាមួយនឹងប្រជាជនជាច្រើននាក់ទៀត ។

រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូន ដុន និងឪពុកម្តាយឲ្យទៅរស់នៅ និងធ្វើការងារដកស្ទូងនៅស្រុកព្រះស្តេច តំបន់២៤ ខេត្តព្រៃវែង ។ ក្រោយដកស្ទូងរួចរាល់ហើយ ខ្មែរក្រហមក៏បញ្ជូនគ្រួសារគាត់ និងអ្នកជម្លៀសផ្សេងទៀតឲ្យទៅរស់នៅខេត្តពោធិ៍សាត់ ដោយឃោសនាថា តំបន់នោះសម្បូរស្បៀងអាហារ ។ នៅទីនោះ ខ្មែរក្រហមបានបែងចែកឪពុកម្តាយ ដុន ឲ្យទៅរស់នៅភូមិឈើទាលខ្ពស់ (នៅខាងត្បូងទីរួមស្រុកក្រគរ) ចំណែក ដុន ទៅរស់នៅភូមិបឹងប្រីមានចម្ងាយប្រមាណ៥០គីឡូម៉ែត្រពីម្តាយគាត់) ។ នៅទីនោះ ខ្មែរក្រហមបែងចែកមនុស្សជាបីប្រភេទ គឺក្រុមមនុស្សចាស់ត្រូវច្រូតស្រូវនៅក្នុងភូមិ មនុស្សពេញវ័យ (ប៉ុកងចល័ត) ត្រូវចេញទៅលើកទំនប់ ជីកប្រឡាយ និងកុមារ ប្រមូលជី និងកាប់ទន្រ្ទានខែត្រ ហើយ ដុន ត្រូវនៅកងចល័ត ។ កន្លះខែក្រោយមក ប្រធានកងបញ្ជូន ដុន ឲ្យទៅបររទេះដឹកកណ្តាប់ ប៉ុន្តែបើធ្វើឲ្យខូចខាតកណ្តាប់ ប្រធានកងនឹងចោទអ្នកបររទេះថាជាខ្មាំង ។ ថ្ងៃមួយ ដោយសារ ដុន មិនចេះវិធីប្រើប្រាស់គោ ទើបគោទាញរទេះឡើងលើទួលហៀបនឹងក្រឡាប់ធ្វើឲ្យប្រធានសេដ្ឋកិច្ចមកឃើញក៏សួរទៅដុន ។ ប៉ុន្តែ ដុន បានឆ្លើយថាបណ្តាលមកពីគោមិនស្តាប់បញ្ជាទើបគាត់បានរួចខ្លួន ។

នៅក្រោយពេលត្រឡប់មកពីធ្វើការវិញ ដុន បានពឹងពាក់នារីម្នាក់ដែលនៅក្នុងកងជាមួយឲ្យជួយប៉ះអាវរហែករបស់គាត់ ។ ពេលរួចរាល់ហើយ នារីនោះនិយាយប្រាប់អ្នកនៅក្នុងកងជាមួយថា ដុន លួចស្រឡាញ់ខ្លួន ។ ក្រោយពីរឿងនេះ ប្រធានកងបានហៅ ដុន ទៅសួរ រួចហើយឲ្យគាត់សារភាព អង្គការនឹងរៀបការឲ្យ ។ ប៉ុន្តែពេលនោះ ដុន បានបដិសេធដោយលើកឡើងថា «គាត់គ្រាន់តែរាប់អាននារីនោះជាមិត្តភក្តិប៉ុណ្ណោះ» ។ នៅយប់ថ្ងៃមួយ ពេល ដុន កំពុងអង្គុយជជុះចំបើង ស្រាប់តែយុវជនម្នាក់ដែលអង្គុយជិតគាត់បានយកកណ្តាប់បោះទៅពន្លត់ភ្លើងចន្លុះនៅក្បែរនារីម្នាក់ ។ នារីនោះក៏ ស្រែក សួរថានរណាពន្លត់ភ្លើង? រួចហើយនិយាយបន្តថា ប្រុសធ្វើការងារចាញ់ស្រីៗ ។ យុវជនផ្សេងទៀតនៅក្បែរនោះនិយាយលេងថា «ចាញ់តែពេលថ្ងៃ យប់មិនចាញ់ទេ» ហើយ ដុន ក៏និយាយបន្ទរតាមក្រោយ ។ ក្រោយពីស្តាប់ពាក្យនេះ នារីនោះបានទៅប្រាប់ប្រធានកងឲ្យហៅ ដុន ទៅសាកសួរ ។ ប៉ុន្តែ ដុន បានសារភាពថា គាត់គ្រាន់តែនិយាយតាមគេប៉ុណ្ណោះ ទើបរួចផុតពីការដាក់ទោស ។ ដុន រៀបរាប់ថា នៅទីនោះ យុវជនម្នាក់ដែលជម្លៀសមកពីស្រុកពាមរក៍ ខេត្តព្រៃវែង បានមូរដៃអាវនៅពេលវាយបំបែកដុំថ្ម ពេលនោះឈ្លបខ្មែរក្រហមមកឃើញ ក៏ហៅគាត់យកទៅបាត់ ដោយចោទថា «អង្គការចែកអាវឲ្យពាក់ ហើយមើលងាយអង្គការទៀត» ។ ហើយចាប់តាំងពីពេលនោះមក ដុន មិនដែលឃើញយុវជននោះទេ ។

ក្រោយពីធ្វើការបានមួយរយៈ ជើងរបស់ ដុន ចាប់ផ្តើម

ហើយខ្លាំង ចំណែកឪពុកម្តាយគាត់ក៏មិនបានដឹងរឿងនេះដែរ ព្រោះចាប់តាំងពីទៅនៅភូមិបឹងប្រី ផុន មិនដែលបានទៅជួបគាត់ទេ ។ នៅពេលនោះ ផុន បានសុំអនុញ្ញាតប្រធានកងទៅព្យាបាលជំងឺនៅមន្ទីរមួយកន្លែងនៅអូរក្លោះ ។ ប៉ុន្តែស្នាក់នៅបានមួយរយៈកងទ័ពវៀតណាមក៏វាយចូលដល់ទើប ផុន ត្រឡប់មកភូមិកំណើត ។ ផុន ត្រូវរដ្ឋអំណាចជ្រើសរើសឲ្យធ្វើជាប្រធានយុវជនភូមិហើយក្រោយមកគាត់ឡើងធ្វើជាប្រធានភូមិ ។ សព្វថ្ងៃ ផុន មានកូនទាំងអស់ប្រាំមួយនាក់ និងប្រកបមុខរបរធ្វើស្រែ ។

ចុងក្រោយ ផុន បានបញ្ជាក់ថា ទោះបីគាត់ធ្លាប់ចូលបម្រើបដិវត្តន៍របស់ខ្មែរក្រហមក៏ដោយ ក៏គាត់ចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ ព្រោះរបបនេះបានធ្វើឲ្យប្រជាជនរងទុក្ខលំបាកវេទនាណាស់ ។ ផុន បន្តថា គាត់ចង់ឲ្យចាស់ៗនិយាយឡើងវិញពីអតីតកាលរបស់គាត់ដែលធ្លាប់ឆ្លងកាត់របបនោះ ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងឮនិងរៀនសូត្រទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្តងទៀត ។ **សោម ប៊ុនថន**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញា ចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការ ព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហមសូមទាក់ទង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

# ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ www.cambodiatribunal.org ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណ័រវេស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រតិបត្តិការជាមួយ Illinois Holocaust Museum and Educational Center ។ មុននឹងផ្សព្វផ្សាយ គេហទំព័រនេះត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ David Scheffer អតីតឯកអគ្គរដ្ឋទូតគោចររបស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ**

# អោម រឹម : ខ្មែរក្រហមពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ

អង្គុយនៅក្នុងចំណោមអ្នកភូមិ គ្រូបង្រៀន និង សិស្សានុសិស្សនៅក្នុងវេទិកាអប់រំសាធារណៈមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រារព្ធធ្វើឡើងនៅក្នុងបរិវេណវត្តភ្នំក្នុងឃុំកំពែង ស្រុកគីរីវង្ស ខេត្តតាកែវ អោម រឹម គឺ ជាស្ត្រីវ័យចំណាស់អាយុ៧០ឆ្នាំម្នាក់ដែលមានរូបរាងតូចស្តើង ។


អោម រឹម

រឹម អង្គុយនៅខាងមុខប្រកបដោយទឹកមុខយកចិត្តទុកដាក់ក្នុងការស្តាប់បន្ទាប់ពីបានឮថាវេទិកានេះនឹងពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឬប្រវត្តិសាស្ត្រខ្មែរក្រហមដែល រឹម ធ្លាប់បានឆ្លងកាត់ដោយផ្ទាល់ប្រកបដោយភាពឈឺចាប់ដែលបានដក់ជាប់នៅក្នុងចិត្ត រឹម អស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ មុនពេលចាប់ផ្តើមការពិភាក្សាទៅលើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់ជាសំណួរមួយថា «តើអ៊ំពូមីងនិងប្អូនៗជឿថាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនឬទេ?» ឮសំណួរនេះភ្លាម រឹម បានលើកដៃទទួលយកក្បាលមេក្រូពីក្រុមការងារ រួចក្រោកឈរឡើងហើយឆ្លើយថា «ខ្មែរក្រហមពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរមែនពីព្រោះប្តីខ្ញុំនិងកូនរបស់ខ្ញុំបួននាក់ទៀតបានស្លាប់នៅក្នុងរបបខ្មែរក្រហម» ។ ដោយអួលដើមកមិនអាចនិយាយតទៅទៀតបាន រឹម ត្រឡប់ទៅកាន់កន្លែងអង្គុយវិញប្រកបដោយទឹកមុខក្រៀមក្រំ ។

នៅពេលរសៀលខ្ញុំបានចុះទៅជួប រឹម ដល់ផ្ទះដើម្បីសួរនាំអំពីប្រវត្តិរឿងរ៉ាវរបស់ រឹម កាលពីសម័យខ្មែរក្រហម ។ រឹម មានស្រុកកំណើតនៅភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង្ស ខេត្តតាកែវ ។

រឹម រៀបការនៅក្នុងសម័យសង្គមរាស្ត្រនិយមជាមួយប្តីដែលជាអ្នកបើកបរឡានដឹកទំនិញ ហើយមានកូនបួននាក់ (ប្រុសបីស្រីមួយ) ។ ក្រោយជ័យជម្នះរបស់ខ្មែរក្រហមនៅខែមេសា ឆ្នាំ១៩៧៥ ប្តីរបស់ រឹម ត្រូវខ្មែរក្រហមបញ្ជាឲ្យដឹកអង្ករ ស្បៀងនិងរបស់របរផ្សេងៗទៀតទៅកាន់ខេត្តបាត់ដំបង ។ បន្តិចក្រោយមក រឹម និងកូនបួននាក់ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ តាមឡានធំមួយដែលផ្ទុកមនុស្សប្រមាណ៧គ្រួសារ ។ ទៅដល់សហករណ៍ឃុំរំលេច រឹម ត្រូវបានដាក់ឲ្យទទួលខុសត្រូវការងារចិញ្ចឹមជ្រូក កាប់ពោត និងដីកដំឡូង ។ រឹម មិនបានចុះទៅធ្វើស្រែចម្ការឬលើកទំនប់ដីកប្រឡាយ ដូចអ្នកភូមិផ្សេងទៀតទេ ដោយសារជើងម្ខាងរបស់ រឹម ពិការតាំងពីកំណើត ។ រៀងរាល់ពេលទៅដីកដំឡូង រឹម តែងតែលួចបោះមើមដំឡូងចោលទៅក្នុងព្រៃដើម្បីឲ្យយុវជនដែលធ្វើការងារធ្ងន់ៗរើសហូប ។ យុវជនមួយចំនួនដែលដឹងរឿងនេះបានលួចអរគុណ រឹម ចំពោះទង្វើល្អរបស់គាត់ ។ ដោយត្រូវបានចាត់ទុកថាជាអ្នកដែលត្រូវបានជម្លៀសមកពីកន្លែងផ្សេងនិងជាអ្នក១៧មេសា រឹម មិនទទួលបានការទុកចិត្តពីកម្មាភិបាលខ្មែរក្រហមនិងទទួលបានរបបអាហារដូចអ្នកមូលដ្ឋានទេ ។ ដោយកូនច្រើនហូបមិនគ្រប់ហើយឃ្លានខ្លាំង រឹម បានទៅលួចដកដំឡូងយកមកស្ងោរហូបដោយលាយជាមួយនឹងស្លឹកថ្នឹងបុកលាយអំបិល ។

ថ្ងៃមួយខណៈពេលកំពុងរស់នៅធ្វើការងារក្នុងសហករណ៍ឃុំរំលេច រឹម បានទទួលដំណឹងថាប្តីរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ ឃ្លាំងអង្ករដែលប្តីរបស់ រឹម ដឹកយកទៅស្តុកទុកត្រូវភ្លើងឆេះអស់ ។ ខ្មែរក្រហមបានចោទអ្នកបើកបរឡានដឹកអង្ករទាំងអស់ថាក្បត់ ហើយយកទៅសម្លាប់ចោលដែលរួមទាំងប្តីរបស់ រឹម ផង ។ សាច់ញាតិរបស់ រឹម ម្នាក់ដែលមានស្រុកកំណើតនៅខេត្តកំពតបាននាំយកដំណឹងនេះមកប្រាប់ រឹម ហើយប្រាប់ឲ្យគាត់ប្រយ័ត្នខ្លួនកុំឲ្យនិយាយអ៊ីផ្តេសផ្តាសក្រែងលោគេយកទៅសម្លាប់

ចោលទាំងពូជ ។ ក្រោយពីទទួលបានដំណឹងនេះ រីម មានការអស់សង្ឃឹមហើយគិតថានឹងបន្តរស់នៅក្នុងសហករណ៍ឃុំរំលេចជាមួយកូនបន្តទៀតព្រោះមិនដឹងថានឹងអាចរត់គេចទៅកន្លែងណាបានទៀតទេ ។ មួយរយៈក្រោយមក កូនប្រុសច្បងពីរនាក់របស់ រីម ម្នាក់ឈ្មោះ ណុយ និងម្នាក់ទៀតឈ្មោះ ភាព ត្រូវបានបញ្ជូនឲ្យទៅនៅសមរភូមិមុខក្បែរព្រំដែន ។ មួយថ្ងៃមុនពេលចាកចេញទៅ កម្មាភិបាលខ្មែរក្រហមបានកាប់គោមួយក្បាលដើម្បីជប់លៀងឲ្យយុវជនដែលនឹងត្រូវធ្វើដំណើរទៅកាន់សមរភូមិមុខ ។ នៅពេលយប់ បន្ទាប់ពីជប់លៀងរួច កូនទាំងពីររបស់ រីម បានលួចយកសាច់គោដែលសេសសល់ដាក់ក្នុងកំប៉ុងមកឲ្យ រីម ហើយប្រាប់ថា «ម៉ែនេះសាច់គោ ខ្ញុំគេបញ្ជូនទៅស្អែកហើយ ម៉ែឯងហូបចុះ» ។ កូនប្រុសទាំងពីររបស់ រីម បានបាត់ខ្លួនរហូតមកទល់ឥឡូវនេះមិនដឹងស្លាប់ឬរស់ ។

បន្ទាប់ពីកូនប្រុសទាំងពីរបានចាកចេញទៅ រីម រស់នៅជាមួយកូនប្រុសម្នាក់និងស្រីពៅម្នាក់ទៀតប្រកបដោយភាពភ័យខ្លាច ។ នៅថ្ងៃខ្លះ រីម បានស្តាប់ឮការសន្ទនារបស់កម្មាភិបាលខ្មែរក្រហមប្រកបដោយភាពព្រឺព្រួច ។ ថ្ងៃមួយពេល រីម កំពុងធ្វើការនៅក្នុងសហករណ៍ កម្មាភិបាលបានជជែកគ្នាថា «នែ! ថ្ងៃនេះនឹងវះពោះខ្លះហើយណា» ។ យប់ឡើង រីម ឮសូរសំឡេងចាប់ចងវាយនឹងដំបង និងបាញ់សម្លាប់ដែលរួមទាំងមនុស្សចាស់និងកូនក្មេង ។ រីម និយាយថាទីតាំងសម្លាប់គឺនៅមិនឆ្ងាយប៉ុន្មានពីសហករណ៍ទេ ហើយគាត់អាចមើលឃើញ ។ រីម បានឃើញកម្មាភិបាលខ្មែរក្រហមដឹកសាកសពអ្នកទោសដែលជាជនជាតិខ្មែរកម្ពុជាក្រោមទាំងរទេះៗយកទៅចាក់ចោលនៅក្នុងរណ្តៅសាកសព ។ មនុស្សមួយចំនួនដែលមិនទាន់អស់ដង្ហើមនៅឡើយបានប្រកាច់កន្ត្រាក់នៅក្នុងរណ្តៅ ។ រីម បាននិយាយប្រាប់ខ្ញុំទាំងអារម្មណ៍ភ័យខ្លាចថា «ក្ឌួយអើយក្ឌួយ ស្លាប់ច្រើនណាស់ដូចខ្មោចគោអីចឹងនៅក្នុងព្រៃ វាសាហាវយង់ឃ្នង់ខ្លាំងណាស់ធ្វើបាបប្រជាជនខ្លាំងណាស់មិនថាអ្នកណាជាអ្នកណាទេឲ្យតែខុស» ។

ថ្ងៃមួយ រីម បានជួបនឹងអតីតនាយទាហានសម័យ លន់ នល់ ម្នាក់ដែលមានរូបរាងស្អាត ។ អតីតនាយទាហានរូបនេះបានបង្ហាញរូបថតឲ្យ រីម មើលដែលមានសុទ្ធតែស័ក្តិនិងផ្កាយពេញខ្លួន ។ រីម បានសុំឲ្យនាយទាហានរូបនោះដុតរូបថតនោះចោល តែគាត់បានបដិសេធ ។ ប៉ុន្មានថ្ងៃក្រោយមក អតីតនាយទាហានរូបនេះនិងក្រុមគ្រួសារទាំងអស់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ រីម នៅចាំអ្នកសម្លាប់យ៉ាងច្បាស់គឺសមមិត្ត មាន និង សមមិត្ត ងៀល ។ រីម អះអាងថា គាត់រស់នៅក្បែរអ្នកទាំងពីរ ហើយឃើញមុខគ្នារៀងរាល់ថ្ងៃ ។ អ្នកទាំងពីរមានមាឌធំហើយខ្មៅ ។ រីម មានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំងក្នុងការរស់នៅក្បែរអ្នកទាំងពីរដែលមានមុខកាចគួរឲ្យខ្លាច ។ រីម មិនដែលហ៊ាននិយាយលេងឬសម្លឹងមើលមុខអ្នកទាំងពីរទេ ។ រីម បានឮសមមិត្ត មាន និង ងៀល និយាយគ្នាថា «សម្លាប់ពួកឆ្ងាយ ហើយបានសម្លាប់ពួកមូលដ្ឋាន» ។ ព្រឹត្តិការណ៍មួយទៀតដែលធ្វើឲ្យ រីម នៅ



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាឡើងបង្រៀនសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» នៅខេត្តតាកែវ

តែមានការភ័យតក់ស្លុតនៅឡើយគឺការចាប់រំលោភក្មេងស្រីដែលត្រូវបានជម្លៀសមកពីភូមិភាគបូព៌ា ។ រឹម និយាយថា កម្មាភិបាលខ្មែរក្រហមបានឃុំខ្លួនស្រីៗមួយចំនួនទុកមួយរយៈសិន ។ «វារំលោភអស់ចិត្តអស់ចង់ហើយបានវាយកទៅសម្លាប់តាមក្រោយ» ។ រឹម ដឹងអំពីហេតុការណ៍នេះដោយសារប្រពន្ធរបស់សមមិត្ត មាន និង ផៀល មានការប្រច័ណ្ឌហើយអង្គុយរអ៊ូក្រោមផ្ទះ ។ រឹម ស្តាប់ពុរឿងនេះដោយចៃដន្យ ។ គ្រាន់តែឮដូច្នេះ រឹម រត់គេចចេញភ្លាមឲ្យឆ្ងាយពីកម្មាភិបាលទាំងនេះខ្លាចខ្មែរក្រហមចោទថា ខ្លួនមកស៊ើបយកការណ៍ ។ មួយរយៈកន្លងមកទៀត កូនពីរនាក់ដែលរស់នៅជាមួយ រឹម បានធ្លាក់ខ្លួនឈឺហើម ហើយនឹងរាកមួលដោយសារតែខ្វះជាតិបាយ ។ ពេល រឹម បានយកកូនទាំងពីរទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យដែលនៅទីនោះ រឹម បានឃើញអ្នកជំងឺដេកស្លាប់នៅលើគ្រែជាច្រើន ។ អ្នកជំងឺខ្លះទៀតបានស្រែកអង្វរ រឹម សុំបាយដំណើប ដូង ស្ករ ហើយស្រែកថា «ឃ្លានខ្លាំងណាស់» ។ កម្មាភិបាលពេទ្យបានដាក់បាយចោលលើគ្រែឲ្យអ្នកជំងឺហូបដោយមិនខ្វល់ថាអ្នកជំងឺមានកម្លាំងលើកបាយហូបដោយខ្លួនឯងបុយ៉ាងណានោះទេ ។ អ្នកជំងឺខ្លះរាកដាក់លើគ្រែដោយគ្មានអ្នកសម្អាតបុថៃទាំអ្វីទាំងអស់ ។

ជារៀងរាល់ល្ងាច រឹម តែងតែចូលទៅមើលកូន បន្ទាប់ពីធ្វើការងាររួចមក ។ រឹម មិនត្រូវបានអនុញ្ញាតឲ្យសម្រាកនៅមន្ទីរពេទ្យដើម្បីមើលថែកូននោះទេ ។ មួយសប្តាហ៍ក្រោយមក កូនទាំងពីររបស់ រឹម ក៏បានស្លាប់ ។ កម្មាភិបាលពេទ្យបានដឹកសាកសពកូនទាំងពីរដែលដេកស្តូកស្តឹងលើរទេះ ហើយគ្មានសម្លៀកបំពាក់នៅជាប់នឹងខ្លួនយកទៅកប់ចោល ។ រឹម គ្រាន់តែបានឈរមើលកូនពីចម្ងាយប៉ុណ្ណោះហើយលួចសម្រក់ទឹកភ្នែកដោយក្តីសោកស្តាយដូចដែលគាត់ឈរសម្លឹងមើលកូនប្រុសច្បងទាំងពីរដែលត្រូវបានបញ្ជូនទៅសមរភូមិមុខដែរ ។ បន្ទាប់ពីកូនទាំងបួនបានចាកចេញនិងស្លាប់ចោលអស់ រឹម មានអារម្មណ៍ថា លែងចង់រស់នៅតទៅទៀតហើយ ។ រឹម បន្តរស់នៅក្នុងសហករណ៍ឃុំរំលេចបន្តទៅទៀត ។ នៅពេលនោះ រឹម ទទួលបន្ទុកដើរកាច់ពោតដេញចាបនិងរកចៃឲ្យប្រធានកង ។ ក្នុងពេលរត់ដេញចាប រឹម តែងតែលួចរើសស្វាយកែវនិងដូងដែលជ្រុះចោលលើដីយកទៅកប់លាក់ទុកក្បែរភ្លឺស្រែជារៀងរាល់ថ្ងៃ ។

នៅចុងឆ្នាំ១៩៧៧ រឹម ត្រូវបានបង្ខំឲ្យរៀបការជាលើកទីពីរ ។ កម្មាភិបាលខ្មែរក្រហមបានប្រាប់ រឹម ថា «ស្អែកឲ្យមានគ្រួសារហើយ អត់មានតវ៉ាអីទេ អង្គការសម្រេចថាឲ្យមានគ្រួសារ ហើយត្រូវសម្រេចតាមផែនការរបស់អង្គការនិងបដិវត្តន៍របស់កម្ពុជា» ។ រឹម មិនពេញចិត្តចំពោះការរៀបការបែបនេះទេ ។ រឹម ក៏ដូចជានារីដទៃទៀតដែរមិនហ៊ានតវ៉ា បុនិយាយមិនពេញចិត្តអ្វីទាំងអស់ ខ្លាចខ្មែរក្រហមចោទថាបំផុសបំផុលប្រឆាំងនឹងបដិវត្តន៍ ។ មួយថ្ងៃមុនពេលរៀបការ កម្មាភិបាលខ្មែរក្រហមបានចែកសម្លៀកបំពាក់ពណ៌ខ្មៅមួយ


សិស្សានុសិស្សនិងអ្នកភូមិចូលរួមនៅក្នុងវេទិកាអប់រំសាធារណៈនៅស្រុកគិរីវង្ស ខេត្តតាកែវ

សម្រាប់ ក្រមាមួយនិងស្បែកជើងកង់ឡានមួយគូ ។ នៅថ្ងៃរៀបការ បុរសនារីទាំងអស់បានមកជួបជុំគ្នានៅមន្ទីររបស់សហករណ៍នៅពេលព្រឹកដែលមានសមមិត្ត ញ៉ៅ និងសមមិត្តនារី ធាម ធ្វើជាអធិបតីនៅក្នុងពិធីនោះ ។ ពិធីរៀបការរបស់ រឹម មានដប់គូ ។ នៅក្នុងពិធីរៀបមង្គលការ រឹម និងប្តីបានធ្វើការប្តេជ្ញានៅចំពោះមុខអង្គការ ដែល រឹម នៅចាំ ហើយមានសេចក្តីថា «សូមគោរពអង្គប្រជុំ សូមគោរពមេកង ឥឡូវអង្គការរៀបចំឲ្យខ្ញុំ ខ្ញុំសម្រេចចិត្តថានឹងយកគ្រួសារតាមការណែនាំដើម្បីជំរុញចលនាឲ្យប្តីខ្ញុំខំធ្វើការកុំឲ្យខ្ជិល» ។ គូស្រករទាំងអស់ត្រូវឡើងមកប្តេជ្ញាម្តងមួយគូៗ ។ កម្មាភិបាលខ្មែរក្រហមបានរៀបចំបាយដែលមានម្ហូបឆាត្រឡាចនិងល្ពៅជាមួយសាច់ជ្រូកនិងស្ងោរឆៃថាវ ។ កម្មាភិបាលខ្មែរក្រហមបានយកដំឡូងមីកូរលាយជាមួយស្ករធ្វើជាបង្អែមសម្រាប់ជប់លៀងពិធីរៀបការជារួមនេះ ។ ក្រោយពីរៀបការរួច កម្មាភិបាលខ្មែរក្រហមបានចែកផ្ទះសង្គមនិយមដែលមានទំហំធំល្មមមួយឲ្យគូស្វាមីភរិយាថ្មីមួយគូមួយខ្នង ។ នៅពេលយប់ក្រោយពីរៀបការរួច ឈ្លបខ្មែរក្រហមបានមកលបស្តាប់ រឹម ក្រែងលោមាននិយាយអ្វីដែលប៉ះពាល់ដល់អង្គការខ្មែរក្រហម ។ ប្តីរបស់ រឹម បានដាស់តឿន រឹម ឲ្យខំសម្ងំដេកកុំឲ្យនិយាយអ្វីទាំងអស់ ។ ប្តីទីពីររបស់ រឹម ត្រូវជាមិត្តភក្តិប្តីទីមួយរបស់គាត់ដែលជាអ្នកបើកឡានដឹកអង្ករដូចគ្នា ។ ក្រោយពីរៀបការបានពីរបីថ្ងៃ ប្តីរបស់ រឹម ក៏ត្រូវធ្វើដំណើរត្រឡប់ទៅសមរភូមិមុខវិញ ។

ប៉ុន្មានខែក្រោយមក រឹម មានផ្ទៃពោះ (កូនដែលគាត់រស់នៅជាមួយសព្វថ្ងៃនេះ) ។ ក្នុងអំឡុងពេលមានផ្ទៃពោះ រឹម ហេវយ៉ាងខ្លាំងដោយចាញ់កូនផង ។ រឹម បានប្រាប់សមមិត្ត ញ៉ៅ ដែលជាប្រធានកងនិងដែលមកពីភូមិភាគនិរតីដូចគ្នាថាគាត់ចង់ហូបមាន់ ។ ប្រធានកងបានចាប់មាន់មួយមកស្ងោរឲ្យ រឹម ហូប ហើយប្រាប់ រឹម កុំឲ្យចេញមកក្រៅខ្លាចគេចាប់យកទៅសម្លាប់ ។

ក្រោយមក រឹម ឆ្លងទន្លេបានកូនស្រីមួយឈ្មោះ រំដួល ។ ប្តីរបស់ រឹម ក៏បានមកជួយមើលថែ រឹម បានមួយសប្តាហ៍ហើយក៏ត្រឡប់ទៅសមរភូមិមុខវិញ ។ ឆ្លងទន្លេបានប្រហែលបួនខែ វៀតណាមបានវាយចូលមក ។ រឹម រត់គេចចេញជាមួយខ្មែរក្រហម ។ កងទ័ពវៀតណាមដេញតាមទាន់ ហើយបានបញ្ជា រឹម ឲ្យដើរត្រឡប់មកក្រោយវិញ ។ រឹម បានដើរត្រឡប់មកភូមិកំណើតហើយបានជួបជុំជាមួយប្តីវិញ ។ ប្តីក្រោយរបស់ រឹម ស្លាប់នៅឆ្នាំ២០០៥ដោយសារជំងឺគ្រុនចាញ់ ។ សព្វថ្ងៃ រឹម ប្រកបរបរធ្វើស្រែនិងចិញ្ចឹមជ្រូកជាមួយកូនស្រីដែលរៀបការហើយមានកូនបួននាក់ ។

ក្នុងអំឡុងពេលរស់នៅក្នុងសហករណ៍ឃុំរំលេចក្នុងរបបខ្មែរក្រហម រឹម បានជួបប្រទះនូវការឈឺចាប់ផ្ទាល់ខ្លួននិងបានមើលឃើញនូវបទឧក្រិដ្ឋកម្មជាច្រើន ។ រឹម ស្លាប់ប្តីនិងកូនបួននាក់ ។ ជីវិតរស់នៅពោរពេញដោយភាពភ័យខ្លាច ។ រឹម បានស្តាប់ឮនិងមើលឃើញការសម្លាប់ស្ទើររៀងរាល់ថ្ងៃ ។ បទសម្ភាសន៍របស់ រឹម បានបង្ហាញឲ្យឃើញថា រឹម អាចរួចរស់ជីវិតបានដោយសារហេតុផលពីរយ៉ាងៈ ទីមួយប្រធានកងនិងគណៈឃុំដែលទៅកាន់កាប់សហករណ៍ឃុំរំលេចគឺជាកម្មាភិបាលមកពីភូមិភាគនិរតីដែលមានដើមកំណើតនៅខេត្តតាកែវដូច រឹម ដែរ និងទីពីរ រឹម មានប្តីដែលមានប្រវត្តិជាកម្មករបើកឡានដឹកទំនិញ ។

ទោះបីជារឿងរ៉ាវទាំងនេះបានកន្លងផុតទៅអស់រយៈពេលជាង៣០ឆ្នាំហើយក្តី រឹម នៅតែមានអារម្មណ៍ភ័យខ្លាចនិងក្រៀមក្រំនៅពេលរំឭកដល់បទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមម្តងៗ ។ រឹម និយាយថា ពេលខ្លះពេលគាត់សម្រាកពេលយប់ ហើយនឹកឃើញដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមម្តងៗគាត់នៅមានអារម្មណ៍ភ័យខ្លាចនៅឡើយ ។ ប៉ុន្តែ ក្រោយពីបានចូលរួមពិភាក្សាក្នុងវេទិកាអប់រំសាធារណៈដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងភូមិឃុំរបស់គាត់រួចមក រឹម មានអារម្មណ៍សប្បាយរីករាយដោយសាររឿងរ៉ាវរបស់គាត់ត្រូវបានអ្នកភូមិផ្សេងទៀត ជាពិសេសក្មេងជំនាន់ក្រោយបានដឹងឮ ។ រឹម និយាយថាគាត់ចង់បន្តស្តាប់វេទិកានេះបន្តទៀតមិនចង់ឲ្យចប់ឆាប់ពេកទេ ។ នៅពេលទំនេរ រឹម តែងប្រាប់ចៅៗថា «កាលពីជំនាន់ ប៉ុល ពត យាយគ្មានអីហូបទេ ហូបតែបបរលាយជាមួយស្លឹកថ្នឹង ។ កូនឯងសំណាងហើយដែលមានសៀវភៅមើលជំនាន់យាយគ្មានអីមើលទេ មានតែធ្វើការនៅតាមវាលស្រែ» ។ រឹម ចង់ឲ្យក្មេងជំនាន់ក្រោយរៀនសូត្រពីអ្វីដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម ដើម្បីកុំឲ្យក្មេងជំនាន់ក្រោយយកគំរូតាមរបបនេះទៀត ។ **ឌី ខាំបូលី**

# ជីវិតរបស់ អ៊ឹម វ៉ាន់ថា



អ៊ឹម វ៉ាន់ថា

អ៊ឹម វ៉ាន់ថា គឺជាកូនទីពីរក្នុងចំណោមបងប្អូនស្រីបង្កើតបួននាក់មានស្រុកកំណើតនៅស្រុកស្រីសន្ធរខេត្តកំពង់ចាម ។ ដោយសារតែការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ចេញពីតំណែងនិងការទម្លាក់គ្រាប់បែកដាខ្លាំង គ្រួសាររបស់ វ៉ាន់ថា ក៏សម្រេចចិត្តផ្លាស់ប្តូរទីលំនៅមកនៅភ្នំពេញវិញដោយម្តាយរបស់គាត់ប្រកបរបរធ្វើជាជាងកាត់ដេរសម្លៀកបំពាក់ ។

មិនយូរប៉ុន្មាន បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ គ្រួសាររបស់ វ៉ាន់ថា ក៏ដូចជាអ្នកដទៃទៀតត្រូវបានបង្ខំឲ្យធ្វើដំណើរទៅកាន់ទីជនបទ ។ នៅពេលនោះ ឪពុកម្តាយរបស់ វ៉ាន់ថា និងបងប្អូនផ្សេងទៀតបាននាំគ្នាធ្វើដំណើរត្រឡប់មកស្រុកស្រីសន្ធរ ដែលជាភូមិកំណើតវិញ ។ ប៉ុន្តែ ពេលមកដល់ភ្លាម ពូមីងព្រមទាំងសាច់ញាតិទាំងប៉ុន្មានរបស់ វ៉ាន់ថា ដែលរួមដំណើរជាមួយគ្នាត្រូវបានខ្មែរក្រហមជម្លៀសបន្តទៅស្រុកឆ្ងាយ ដោយសារតែអ្នកទាំងនោះធ្លាប់មានឋានៈខ្ពស់ក្នុងជួររដ្ឋាភិបាល (ក្រោយមកក៏ឮដំណឹងថា ស្លាប់ទាំងអស់នៅសល់តែក្មេងតូចៗប៉ុណ្ណោះ) ។

នៅឆ្នាំ១៩៧៦ ក្រោយពីខ្មែរក្រហមបានរៀបចំជាសហករណ៍រួចរាល់ វ៉ាន់ថា ដែលមានអាយុទើបបាន៩ឆ្នាំត្រូវបានចាត់តាំងឲ្យទៅកើបអាចម៍គោនិងកាប់ទន្ទ្រានខេត្តលាយជាមួយអាចម៍គោដើម្បីធ្វើជីដាក់ស្រែ ។ វ៉ាន់ថា នៅចាំបានថា គាត់ត្រូវក្រោកតាំងពីម៉ោង៤ព្រឹកទៅកើបអាចម៍គោ ពេលខ្លះត្រូវដណ្តើមគ្នាជាមួយក្មេងដទៃទៀត ពីព្រោះថាប្រសិនបើយើងមិនអាចរកអាចម៍គោតាមចំនួនកំណត់ទេ នោះនឹងគ្មានបបរហូបទេ ។ ដូច្នេះហើយ ទោះបីជាថ្ងៃខ្លះ វ៉ាន់ថា មានជំងឺស្ទើរតែក្រោកមិនរួចក៏ដោយ ក៏គាត់ត្រូវតែខិតខំធ្វើការដើម្បីទទួលបានរបបបបរនេះដែរ ។

ចំណែកឪពុកម្តាយរបស់ វ៉ាន់ថា វិញត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកន្លែងផ្សេងពីគ្នាដែរ ។ ដូច្នេះហើយ ម្តាយរបស់ វ៉ាន់ថា តែងតែមានការព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់ ប្តីនិងកូនជានិច្ចពីព្រោះគាត់តែងតែឃើញកងឈ្លបចុះមកចាប់មនុស្សនៅក្នុងភូមិរួចដឹកអ្នកទាំងនោះតាមកង់ដោយមានរុំភ្នែកជិតយកចេញទៅ ប៉ុន្តែមិនដែលឃើញត្រឡប់មកវិញឡើយ ។ ក្រោយមកនៅចុងឆ្នាំ១៩៧៦ នៅវេលាយប់ស្រាប់តែមានកងឈ្លបពីរទៅបីនាក់ចូលមកដល់ក្នុងផ្ទះរបស់ឪពុកម្តាយ វ៉ាន់ថា ដើម្បីចាប់



អ៊ឹម វ៉ាន់ថា ជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា

គាត់និងប្ដីយកទៅ ។ ដោយសារតែម្ដាយរបស់ វ៉ាន់ថា សម្រាកនៅផ្ទះខាងក្រោយបានឮដំណឹងមុន ដូច្នេះគាត់ក៏លួចរត់រួច ប៉ុន្តែឪពុករបស់គាត់ដែលសម្រាន្តនៅផ្ទះតូចខាងមុខគឺត្រូវខ្មែរក្រហមចាប់យកទៅដាក់គុកដោយមិនដឹងពីមូលហេតុ ។ ចាប់តាំងពីខ្មែរក្រហមចាប់ឪពុករបស់ វ៉ាន់ថា យកទៅ ម្ដាយរបស់គាត់តែងតែសម្រាន្តមិនលក់និងទន្ទឹងរង់ចាំប្ដីត្រឡប់មកវិញជារៀងរាល់ថ្ងៃ ។ ដោយនៅតែមិនដែលទទួលដំណឹងពីប្ដីសោះនៅទីបំផុតម្ដាយរបស់ វ៉ាន់ថា បានយកវត្ថុមានតម្លៃមួយចំនួនដែលបានសន្សំទុកកាលពីមុនដូចជា នាឡិកា និងខ្សែកទៅសូកមេកងដើម្បីឲ្យគេដោះលែង ។

មួយរយៈក្រោយមក ឪពុករបស់ វ៉ាន់ថា ក៏បានត្រឡប់មកវិញ ។ ទោះបីជាឪពុករបស់ វ៉ាន់ថា ត្រូវបានដោះលែងក៏ដោយ ក៏ប៉ុន្តែឪពុកគាត់មានអាការៈខុសប្លែកពីមុនទាំងស្រុង ។ ឪពុករបស់ វ៉ាន់ថា មានរូបរាងស្គមស្គាំង និងស្នាមរបួសពេញខ្លួនថែមទាំងមិនសូវនិយាយស្ដីដូចពីមុន ដោយគាត់តែងតែមានអារម្មណ៍ភ័យខ្លាចជានិច្ច ជាពិសេសពេលដែលឮសំឡេងឆ្កែព្រុស គាត់ភ័យបាត់មាត់បាត់ក ជួនកាលរត់ទៅពួននៅក្នុងពាងឬទូដាក់ខោអាវទៀតផង ។ វ៉ាន់ថា បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថាប្រហែលជាដោយសារការធ្វើទារុណកម្មនៅក្នុងគុកឬបង្ខំឲ្យធ្វើការធ្ងន់ហើយទើបគាត់មានសភាពបែបនេះ ដែលរហូតដល់សព្វថ្ងៃនេះបានបណ្ដាលឲ្យគាត់មានជំងឺបេះដូងថែមទៀត ។

នៅឆ្នាំ១៩៧៨ ដោយសារមិនអាចទ្រាំនឹងភាពអត់ឃ្លាន ការបង្ខំឲ្យធ្វើការងារធ្ងន់និងមានវ័យចំណាស់ផង យាយតារបស់ វ៉ាន់ថា បានស្លាប់ដោយសារជំងឺហើម ។ ក្រោយពីស្ថានភាពជំងឺរបស់ឪពុក វ៉ាន់ថា មានភាពធូរស្បើយនិងខណៈពេលដែលមានចលនារើបម្រះប្រឆាំងនឹងខ្មែរក្រហម គាត់ក៏បានស្ម័គ្រចិត្តចូលប្រយុទ្ធប្រឆាំងខ្មែរក្រហមវិញ ។ ក្រោយមកដោយសារតែឪពុក វ៉ាន់ថា សិក្សាបានខ្ពស់និងធ្វើសកម្មភាពដឹកនាំបានល្អ គាត់ក៏ត្រូវបានតែងតាំងឲ្យធ្វើប្រធានមន្ទីរគមនាគមន៍នៅស្រុកស្រីសន្ធរថែមទាំងទទួលការគាំទ្រពីប្រជាជនទៀតផង ។ នៅឆ្នាំ១៩៨២ ឪពុករបស់ វ៉ាន់ថា បានសម្រេចចិត្តឈប់ពីការងារជាមន្ត្រីរាជការទៅរកស៊ីដឹកជញ្ជូនថ្នាំកូតាបទៅលក់នៅតាមខេត្តផ្សេងៗនិងប្រទេសវៀតណាមវិញ ។

នៅឆ្នាំ១៩៨៤ បន្ទាប់ពី វ៉ាន់ថា ប្រឡងជាប់សញ្ញាបត្រឌីប្លូម ឪពុកម្ដាយរបស់ វ៉ាន់ថា បានផ្លាស់គាត់ឲ្យទៅរៀននៅវិទ្យាល័យបាក់ទូកក្រុងភ្នំពេញ និងបន្តការសិក្សារហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងបានក្លាយជាគ្រូបង្រៀនកម្រិតឧត្ដម ។ សព្វថ្ងៃ វ៉ាន់ថា ជាគ្រូបង្រៀនប្រវត្តិសាស្ត្រថ្នាក់ទី១១-១២នៅខេត្តកោះកុង ។ វ៉ាន់ថា បានរៀបរាប់ថា «ខ្ញុំចូលចិត្តការបង្រៀនប្រវត្តិសាស្ត្រជាខ្លាំង ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីព្រោះវាជារឿងពិតដែលបានកើតឡើងក្នុងប្រទេសកម្ពុជារបស់យើង ។

លើសពីនេះទៅទៀត វាក៏ជាបទពិសោធន៍ដែលឪពុកម្ដាយគាត់ រួមទាំងឪពុកម្ដាយរបស់សិស្សមួយចំនួនធ្លាប់បានឆ្លងកាត់ដោយផ្ទាល់ផងដែរ ដែលសិស្សទាំងអស់ត្រូវតែយល់ដឹងឲ្យបានច្បាស់ពីការសម្លាប់រង្គាលនិងអំពើឃោរឃៅរបស់ខ្មែរក្រហម មុននឹងស្វែងយល់ពីប្រវត្តិសាស្ត្របរទេស ។

**ផា ផល្លា**



# មិនអាចរស់នៅជាមួយជនដៃដល់នៅក្នុងភូមិ


ខៀវ សុផន

ខៀវ សុផន ភេទស្រី អាយុ៦៨ឆ្នាំ ជាកូនកាត់វៀតណាមមានម្តាយឈ្មោះ វ៉េ ជាជនជាតិវៀតណាមនិងឪពុកឈ្មោះ ផាត ជាជនជាតិខ្មែរ អតីតទាហានក្រហមនៅសម័យបារាំង (ក្រោយមកត្រូវបានខ្មែរក្រហមគប់គ្រាប់បែកសម្លាប់) ។ មុនឆ្នាំ១៩៦០ ផន បានរៀបការជាមួយបុរសជនជាតិខ្មែរម្នាក់ ហើយបានទៅរស់នៅស្រុកខាងប្តីនៅក្នុងឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ផន បានសម្រេចចិត្តទៅរស់នៅស្រុកកំណើតខាងម្តាយនៅឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងវិញ ដោយសារតែមិនអាចទ្រាំនឹងការរស់នៅក្នុងភូមិជាមួយក្រុមគ្រួសារឃាតករដែលបានយកប្តីរបស់គាត់ទៅសម្លាប់នៅក្នុងរបបខ្មែរក្រហម ។ សព្វថ្ងៃ ផន ប្រកបមុខរបរដាំដំឡូង និងផ្លែឈើហូបផ្លែ ព្រមទាំងធ្វើនំលក់ដើម្បីចិញ្ចឹមជីវិត ។

នៅឆ្នាំ១៩៧១ ដោយសារតែស្ថានភាពនៅក្នុងភូមិចាប់ផ្តើមមានភាពប្របូកប្រចល់ ក្រុមគ្រួសាររបស់គាត់បានសម្រេចចិត្តរត់មករស់នៅទីក្រុងភ្នំពេញវិញ ។ ប៉ុន្តែ ស្ថានភាពនៅក្នុងទីក្រុងភ្នំពេញក៏មិនខុសពីភូមិប៉ុន្មានដែរ ថែមទាំងមានការចាប់ទាហានខ្លាំងក្លាទៀតផង ។ ហេតុដូច្នេះហើយ ផន សម្រេចចិត្តវិលត្រឡប់មករស់នៅស្រុកកំណើតខាងប្តីវិញ ។ នៅឆ្នាំ១៩៧៥ ផន ក៏ត្រឡប់មករស់នៅជួបជុំជាមួយប្តីនៅឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។ នៅទីនោះ ផន ត្រូវបានចាត់តាំងឲ្យធ្វើការខាងកងដកស្ទូង ចំណែកប្តីនៅកងនេសាទ ។ ចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានស្នើប្តីរបស់ ផន ឲ្យទៅបង់ត្រី ដោយសន្យាទៅតែបីថ្ងៃប៉ុណ្ណោះ ។ ប៉ុន្តែរយៈពេលបីថ្ងៃបានកន្លងផុតទៅ ផន នៅតែមិនឃើញប្តីរបស់គាត់ត្រឡប់មកវិញ ។ ដោយសារតែមិនដែលបានទទួលដំណឹងអស់រយៈពេលកន្លះខែមកហើយ ផន ក៏សម្រេចចិត្តទៅសួរគណៈកង ។ ប៉ុន្តែ ចម្លើយដែលទទួលបានគឺថា «មិត្តឯងមិនបាច់ដេញដោលច្រើនទេ អ្នកគេទៅមុខ គេចេះតែទៅមុខហើយ យើងនៅខាងក្រោយ គិតតែពីខំកសាងខ្លួនទៅ» ។ ពេលឮភ្លាម ផន មិនហ៊ានឆ្លើយតបតជាមួយនឹងគណៈកងទេ ព្រោះខ្លាចអង្គការហៅទៅកសាង ។ បន្ទាប់មក អ្នកនៅក្នុងកងបានជួយលួងលោមគាត់ថា «កុំរង់ចាំអី ព្រោះប្តីរបស់ឯងគេយកទៅសម្លាប់ចោលហើយ» ។


ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅដល់សិស្សានុសិស្ស

នៅឆ្នាំ១៩៧៦ ផន ត្រូវបានគណៈកងហៅទៅធ្វើប្រវត្តិរូបជាច្រើនលើក ដោយក្នុងនោះមានសួរថាតើគាត់ និងប្តីកាលមុនធ្វើអ្វី? ដោយសារតែចម្លើយរបស់ ផន នៅតែដដែល និងមើលឃើញថាគាត់ចេះជំនាញជាច្រើនដែលអាចបម្រើដល់អង្គការ

បានដូចជា បេះអូសអួន ដួសដុលមង ធ្វើសំណាញ់ គណៈកងក៏បញ្ជាឲ្យគាត់ទៅធ្វើការ នៅកន្លែងនេសាទត្រី ដោយកំណត់មួយថ្ងៃរកឲ្យបានត្រី១០០គីឡូសម្រាប់ផ្គត់ផ្គង់រោងបាយ ។ ដូច្នេះ ដើម្បីរកត្រីឲ្យបានតាមការកំណត់ ផន ត្រូវក្រោកតាំងពីព្រលឹមម៉ោងបួនព្រឹកទៅរកត្រី ។ តែទោះជា ផន ខិតខំធ្វើការយ៉ាងណាក៏ដោយ ក៏គាត់នៅតែត្រូវអង្គការធ្វើបាបដដែល ដោយគាត់ត្រូវបានបង្ខំឲ្យគាត់រៀបគូស្រករថ្មី។ ដោយសារតែ ផន មានកូនប្រាំមួយនាក់នៅក្នុងបន្ទុករួចទៅហើយ គាត់បានប្រកែកជាដាច់ខាតមិនព្រមរៀបការទេ ដោយលើកហេតុផលថា «ប្រសិនបើខ្ញុំរៀបការ ខ្ញុំមិនអាចធ្វើការឲ្យបានល្អដើម្បីបម្រើអង្គការទេ ។ ម្យ៉ាងវិញទៀត ខ្ញុំត្រូវដោះស្រាយយ៉ាងណា ប្រសិនបើប្តីរបស់ខ្ញុំត្រឡប់មកវិញ» ។ ក្រោយមក អង្គការក៏លែងបង្ខំគាត់ទៀត ។



មិនយូរប៉ុន្មាន ស៊ុំ ដែលស្នាក់នៅក្នុងផ្ទះជាមួយគាត់បានរត់ទៅនៅជាមួយឪពុកម្តាយវិញ ដោយមិនផ្តល់ដំណឹងឲ្យគាត់ ឬគណៈកងដឹងជាមុនឡើយ រហូតធ្វើឲ្យគណៈឃុំចោទប្រកាន់គាត់ពីបទលាក់បាំងអង្គការបណ្តោយឲ្យមនុស្សរត់ចេញពីកង ។ ប៉ុន្តែសំណាងល្អ ដោយសារតែ ផន បកស្រាយបានច្បាស់លាស់ ទើបគាត់រួចខ្លួន ។ មិនយូរប៉ុន្មាន គណៈកងដែលច្រណែនគាត់បានចោទប្រកាន់គាត់ថា ជាប្រពន្ធស័ក្តិបីទៀត ។ លើកនេះ ផន ស្ទើរតែបាត់បង់ជីវិតដោយសារតែនេះជាទោសធ្ងន់មិនអាចលើកលែងបាន ។ ប៉ុន្តែដោយសារតែ ផន ជាមនុស្សចិត្តល្អ និងទទួលបានការទុកចិត្តពីអង្គការផង ទើបគណៈឃុំម្នាក់ទៀតបានអះអាងថាបានស្គាល់ប្រវត្តិរបស់គាត់ច្បាស់ ទើបគាត់អាចរួចពីការចោទប្រកាន់នេះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ ផន តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះគាត់សម្គាល់ឃើញថា មនុស្សនៅក្នុងក្រុមតែងតែបាត់ជារៀងរាល់ថ្ងៃ រហូតស្ទើរតែគ្មានមនុស្សមកធ្វើការ ។ ជាក់ស្តែង នៅប្រហែលចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានរៀបចំគម្រោងយកមនុស្សទៅសម្លាប់ទាំងអស់ ដោយបានរាយមីននៅជុំវិញកន្លែងប្រជុំ រួមមានភូមិ១ ភូមិ២ ភូមិ៣ និង ភូមិ៤ ប៉ុន្តែដោយសារតែប្រជាជនមកមិនទៀងពេល ហើយមិនគ្រប់គ្នា និងផែនការបែកការណ៍ ព្រោះបងប្អូនជីដូនមួយរបស់គាត់ឈ្មោះ យា ដែលជាកងឈ្លបបាននិយាយប្រាប់ (ក្រោយមក យា ក៏បានស្លាប់ដោយសារតែខ្មែរក្រហមយកទៅសម្លាប់) ទើបគម្រោងការនេះបរាជ័យទៅ ។

សព្វថ្ងៃនេះ ទោះបីជារបបខ្មែរក្រហមដួលរលំទៅអស់រយៈពេល៣១ឆ្នាំហើយក៏ដោយ ក៏ ផន មិនដែលត្រឡប់ទៅលេងស្រុកកំណើតខាងម្តាយរបស់គាត់ដែរ ។ ការស្លាប់បាត់បង់ជីវិតរបស់ប្តីគាត់ បងប្អូន ព្រមទាំងសាច់ញាតិពិតជាមិនអាចឲ្យគាត់រសាយពីកំហឹងបានឡើយ ។ រឿងនេះបានក្លាយទៅជាការស្អប់ខ្ពើម និងមិនចង់ឃើញមុខក្រុមគ្រួសាររបស់ឃាតករទេ ដោយគាត់សុខចិត្តជ្រើសរើសយកការចាកចេញពីស្រុកកំណើតវិញប្រសើរជាង ហើយក៏មិនព្រមទៅរស់នៅក្នុងភូមិជាមួយក្រុមគ្រួសាររបស់ឃាតករដែរ ។

**លី សុខចំរើន**

*កំណាព្យៈ*

## ទៅធ្វើទ័ពដើម្បីសងឈាមឱ្យប្តី

ស្រណោះក្មេងខ្មែរលេងក្នុងពេលការ អើយ! នៅមុខមេបា
ទទួលពរជ័យ ស្រាប់តែមានមារចង្រៃ ប៉ុល ពត អប្រិយចាប់
ប្តីប្រហារ អូនស្ទុះត្រកងរាងកាយវល័ក្ខណ៍ លោហិតដោក
ពេញប្រាណស្រីថ្លៃ លោហិតនេះឯងហាក់ដូចសម្តី
ដើម្បីឲ្យស្រីទៅសងសឹកជួស លោកឪពុកអ្នកម្តាយកូនសូមពលី
វេលាកូនត្រូវទៅសងឈាមហើយ កូនកាន់អាវុធរត់ឡើង
សមរភូមិ ដើម្បីចាប់សត្រូវអារ-ក
ស្រង់ឈាមយកមកសំលៀងលើផ្នូរប្តីខ្ញុំ ។

**ខៀវ សុផន**

# ក្រោយរបបខ្មែរក្រហមឡើងកាន់អំណាច

ក្រោយពីបដិវត្តន៍ខ្មែរក្រហមដួលរលំទៅ យ៉ាងហោចណាស់មានប្រជាជនប្រមាណ១.៧លាននាក់បានស្លាប់បាត់បង់ជីវិត។ លទ្ធផលនៃរបបនេះភាគច្រើនបានបន្សល់ទុកស្ត្រី មេម៉ាយ កុមារ កំព្រា និងជនពិការនៅទូទាំងប្រទេស។ អ្នកដែលនៅរស់រានមានជីវិតមិនត្រឹមតែរស់នៅឱបជាប់នឹងអតីតកាលរបស់ខ្លួនដ៏គួរភ័យខ្លាចប៉ុណ្ណោះទេ ថែមទាំងត្រូវតស៊ូនឹងជីវិតថ្មីដែលចាប់ផ្តើមពីបាតដៃទទេទៀត តួយ៉ាងក្រោយពីរបបខ្មែរក្រហមឡើងកាន់អំណាច ជីវិតរបស់ ស៊ិន ស៊ីណែត ត្រូវបានផ្លាស់ប្តូរទាំងស្រុងដោយគាត់បានក្លាយជាក្មេងកំព្រាម្នាក់។

ស៊ិន ស៊ីណែត ហៅ ស៊្រិន មានស្រុកកំណើតនៅសង្កាត់បឹងទំពុន ក្រុងភ្នំពេញ។ ឪពុករបស់ ស៊ីណែត ឈ្មោះ នី ម្តាយឈ្មោះ សុផុន ចំណែកប្អូនឈ្មោះ លីន (អាយុប្រហែលពីរឆ្នាំ)។ ដោយសារឪពុកម្តាយ ស៊ីណែត មានការមមាញឹកក្នុងការងារជាគ្រូបង្រៀននៅសាលាបឹងត្របែក និងពុំសូវមានពេលវេលាគ្រប់គ្រាន់មើលថែកូន អ្នកទាំងពីរក៏សម្រេចចិត្តឲ្យ ស៊ីណែត ទៅរស់នៅជាមួយជីតាឈ្មោះ ស៊ិន មានមុខរបរជាងម៉ាស៊ីននៅរោងចក្រផលិតស្រា (អេស-កា-ដេ) យាយឈ្មោះ ណុប សេង, ពូ វណ្ណី ព្រមទាំងប្រពន្ធរបស់គាត់ឈ្មោះ ផាត។ នៅទីនោះ ជីតារបស់ ស៊ីណែត បាននាំគាត់ទៅចូលរៀននៅសាលាបឋមសិក្សាឃ្លាំងលើ។

នៅខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមបានឡើងកាន់អំណាចទូទាំងប្រទេស ស៊ីណែត រួមទាំងយាយ តា ពូ និងមីងដែលសរុបមានសមាជិកប្រាំនាក់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីក្រុងកំពង់សោម ដោយមិនបានប្រាប់គោលដៅច្បាស់លាស់ទេ។ ធ្វើដំណើរមកដល់សង្កាត់ព្រៃនប់ ទាំងអស់គ្នាត្រូវបែកបែកឲ្យធ្វើការងារនៅតាមកងតាមការកំណត់របស់អង្គការ។ ដំបូងអង្គការចាត់តាំងឲ្យគ្រួសាររបស់ ស៊ីណែត ធ្វើកញ្ច្រែង និងធ្វើស្រែចម្ការ ចំណែកគាត់ធ្វើការនៅកងកុមារ ដូចជាដើរប្រមូលដី កើបអាចម៍គោ និងកាប់ទន្រ្ទានខែត្រ។ រយៈពេលប្រមាណពីរខែក្រោយមក នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនឲ្យមកធ្វើការនៅរោងចក្រកាត់ដេរអូរប៉ុស្សី ឬ មន្ទីរ «គ៩» នៅភ្នំពេញវិញ។ នៅទីនោះ យាយរបស់ ស៊ីណែត ធ្វើជាអ្នកដាំស្ល តា និងពូធ្វើជាងចាក់ពុម្ពដែក មីង ជាអ្នកដេរសម្លៀកបំពាក់ ចំណែកគាត់ជាជាងជួសជុលម៉ាស៊ីនដេរក្នុងកងកុមារប្រចាំមន្ទីរ «គ៩»។

នៅឆ្នាំ១៩៧៧ យាយតា ពូមីង រួមជាមួយអ្នកធ្វើការនៅក្នុងមន្ទីរផ្សេងទៀតត្រូវបានចាប់ខ្លួន។ ស៊ីណែត បាននិយាយថា «មានមិត្តមីងម្នាក់នៅមន្ទីរនេះបានប្រាប់ខ្ញុំថា មានឡានទ្រុងពណ៌សបានដឹកគាត់ទាំងបួននាក់ និងអ្នកផ្សេងទៀតទៅកសាងខ្លួនបាត់ហើយ»។ គាត់បន្តទៀតថា «កុំប្រាប់ឲ្យគេដឹងថាឯងជាសាច់ញាតិរបស់គាត់ ហើយប្រសិនបើនឹកគាត់ ក៏កុំយំឲ្យគេឃើញដែរ។ ប្រសិនបើយំ ត្រូវកុហកថាយំដោយសារតែឈឺធ្មេញ»។ ចាប់


ស៊ិន ស៊ីណែត

តាំងពីពេលនោះមក ស៊ីណែត មិនដែលបានទទួលដំណឹងពីគាត់ទាំងបួននាក់ឡើយ ។ ក្រោយមក ស្ថានភាពនៅក្នុងមន្ទីរកាន់តែតឹងតែងឡើងៗ ដោយអ្នកធ្វើការនៅក្នុងមន្ទីរចាប់ផ្តើមបាត់ខ្លួនជាបន្តបន្ទាប់ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ អង្គការបានចាត់តាំងឲ្យអង្គភាពទាំងអស់ដែលមានទីតាំងនៅក្រុងភ្នំពេញលើកអាងទឹកនៅម្តុំផ្សារដើមគ-បឹងសាឡាងទាំងយប់ទាំងថ្ងៃ ដែលអាងនោះទំហំធំមានរាងបួនជ្រុង និងថ្នល់ទំនប់កម្ពស់ប្រហែលប្រាំម៉ែត្រ ។ ដើម្បីធ្វើការឲ្យទាន់តាមផែនការនេះ ប្រធានកងបានបង្ខំឲ្យកម្មករទាំងអស់ធ្វើការសម្រុកទាំងយប់ទាំងថ្ងៃស្ទើរតែគ្មានពេលឈប់សម្រាកឡើយ ។ លើសពីនេះទៅទៀត ម្នាក់ៗត្រូវព្រួយបារម្ភខ្លាចអង្គការយកទៅសម្លាប់ថែមទៀត ដោយសារតែសមាជិកកងតែងតែបាត់ខ្លួនម្តងមួយៗ ។ នៅទីនោះ ស៊ីណែត នៅទន្ទឹងរង់ចាំមើលផ្លូវយាយតា ព្រមទាំងពូមីងរបស់គាត់ដែរ ប៉ុន្តែអ្វីៗដូចជាកាន់តែឃ្លាតឆ្ងាយទៅៗ ដោយបាត់ដំណឹងសូន្យឈឹង ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ពេលដែល ស៊ីណែត និងអ្នកផ្សេងទៀតកំពុងធ្វើការងារនៅការដ្ឋាន កងទ័ពវៀតណាមបានចូលមកដល់ក្រុងភ្នំពេញ ។ ពេលនោះ ស្ថានភាពច្របូកច្របល់ជាខ្លាំង ដោយ ស៊ីណែត បានឃើញហេតុការណ៍ខ្មែរក្រហមបាញ់មនុស្សយ៉ាងសាហាវព្រៃផ្សៃ ប្រសិនបើនរណាម្នាក់ប្រកែកមិនព្រមទៅ ។ ខ្មែរក្រហមបានកៀរប្រជាជននៅការដ្ឋានឲ្យធ្វើដំណើរឆ្លងកាត់ភ្នំឱរ៉ាល់ឆ្ពោះទៅស្រុកបវេល ។ ពេលទៅដល់ភ្នំចោលចាប ស៊ីណែត បានឃើញសាកសពមនុស្សជាច្រើនរួមទាំងអ្នកធ្វើដំណើរជាមួយគ្នាក៏ស្លាប់ជាបន្តបន្ទាប់ដែរ ដោយសារពុំមានទឹក និងអាហារ ជាពិសេសក្មេងៗដែលងាយឆ្លងជំងឺបានស្លាប់ច្រើនជាងគេ ។ ក្រោយមក ពេលធ្វើដំណើរទៅដល់ពាក់កណ្តាលផ្លូវមានអូរធំមួយ ស៊ីណែត និងក្រុមស្ត្រីដែលមានកូនតូចក៏បានសម្រេចចិត្តដើរត្រឡប់មករកភូមិប្រជាជននៅឯខេត្តបាត់ដំបងវិញ ព្រោះប្រសិនបើអ្នកណាឆ្លងមិនផុតនឹងត្រូវលង់ទឹកស្លាប់ ។ ពេលមកដល់ស្រុកមោងឫស្សី ស៊ីណែត បានដើរសុំអង្ករអ្នកភូមិទុកសម្រាប់ហូបតាមផ្លូវដើម្បីបន្តដំណើរទៅខេត្តកំពង់ធំ ។ នៅតាមផ្លូវមានស្ត្រីម្នាក់អាណិតស្រឡាញ់គាត់ ហើយយកគាត់ទៅរស់នៅជាមួយ ដោយចាត់ទុកគាត់ដូចជាកូន ។ ប៉ុន្តែដោយសារតែ ស៊ីណែត មានពងបែកពេញជើងមិនអាចបន្តដំណើរបាន គាត់ក៏បានបែកគ្នានៅពេលដែលស្ត្រីនោះធ្វើដំណើរទៅខេត្តកំពង់ចាម ។

នៅឆ្នាំ១៩៨០ ស៊ីណែត បានរស់នៅខេត្តកំពង់ធំជាមួយក្រុមគ្រួសារមួយ ។ ដោយសារ ស៊ីណែត ត្រូវទទួលខុសត្រូវមើលថែផ្ទះសម្បែង និងកូនតូចៗរបស់ម្ចាស់ផ្ទះ ដូច្នេះគាត់មិនបានចូលរៀននៅសាលាដូចជាក្មេងដទៃទេ ទោះបីជាគាត់បានសុំទៅរៀនជាច្រើនលើកច្រើនសាហើយក៏ដោយ ។ ដោយសារតែគិតថាការរស់នៅក្នុងគ្រួសារនេះនឹងគ្មានអនាគត ស៊ីណែត បានសម្រេចចិត្តទៅរស់នៅកន្លែងកុមារកំព្រាវិញ ។ ក្រោយមក ស៊ីណែត ត្រូវបានបញ្ជូនឲ្យចូលរៀនដូចបំណងប្រាថ្នារបស់គាត់ដែលចង់ធ្វើពេទ្យនៅថ្ងៃអនាគត ។ នៅទីនោះ ក្រៅពីការងាររៀនសូត្រ គាត់ឆ្លៀតពេលខ្លះទៅជួយធ្វើការនៅសាលាឃុំដូចជាដាំបាយជាដើម ។ ដោយសារឃើញ ស៊ីណែត ជាមនុស្សខស្សាហ៍ព្យាយាម ស្ត្រីម្នាក់នៅសាលាឃុំបានសុំ ស៊ីណែត ឲ្យរស់នៅជាមួយ ។ ប៉ុន្តែនៅមួយរយៈ ស៊ីណែត បែរជាទទួលបន្ទុកមើលថែទាំងកូនតូចៗរបស់ម្ចាស់ផ្ទះដូចមុនដដែល ថែមទាំងមិនអនុញ្ញាតឲ្យទៅរៀនទៀត ។ ស៊ីណែត បានរៀបរាប់ថា «គាត់មិនឲ្យខ្ញុំទៅរៀនទេ ខ្លាចខ្ញុំមានចំណេះដឹងខ្ពស់ ហើយលែងបាននៅបម្រើគាត់ទៀត ។ ម្យ៉ាងទៀត ស្ត្រីនោះក៏ប្រចណ្ឌខ្ញុំជាមួយប្តីគាត់ដែរ» ។ ក្រោយពីចាកចេញពីទីនោះ ស៊ីណែត បានទៅរៀនធ្វើពេទ្យយោធានៅសាលាហ៊ឹកហ៊ឺន ហើយក៏ត្រូវប្រធាននៅទីនោះរៀបចំឲ្យមានគ្រួសារ ។ ស៊ីណែត មានតួនាទីជាអ្នកស្ម័គ្រចិត្តនៅក្នុងភូមិ ដោយជួយផ្សព្វផ្សាយ និងអប់រំពីជំងឺទូទៅដែលកើតមានតាមរដូវកាលដូចជាជំងឺគ្រុនឈាម និងគ្រុនចាញ់ ព្រមទាំងអប់រំយេនឌ័រ និងសុខភាពស្ត្រីមានផ្ទៃពោះ និងជំរុញឲ្យពួកគេឆ្លងទន្លេនៅមណ្ឌលសុខភាពក្នុងភូមិ ។ សព្វថ្ងៃ ស៊ីណែត មានកូន៦នាក់ (ស្រី២នាក់ ប្រុស៤នាក់) ។

ស៊ីណែត បានរំឭកថា កាលពីឆ្នាំ១៩៨០ គាត់បានទទួលដំណឹងពីមិត្តភក្តិរបស់ឪពុកម្តាយគាត់ថាបានឃើញរូបថតជីតាគាត់ឈ្មោះ ស៊ិន នៅទួលស្លែង ។ ពេលនោះ ដើម្បីបញ្ជាក់ឲ្យច្បាស់គាត់បានមកទួលស្លែងដើម្បីរករូបថតជីតារបស់គាត់ ។ បន្ទាប់ពីរកឃើញហើយ គាត់ក៏សុំអ្នកយាមដើម្បីថតរូបថតរបស់ជីតាគាត់ទុក

សម្រាប់គោរពបូជានៅផ្ទះ ប៉ុន្តែអ្នកយាមនៅទីនោះមិនអនុញ្ញាតឲ្យថតទេ ។ ចាប់តាំងពីពេលនោះមក ស៊ីណែត មិនមានឱកាសបានទៅភ្នំពេញទេ ។ ក្រោយមកនៅឆ្នាំ២០០៨ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួប ស៊ីណែត ដោយចៃដន្យ ហើយក៏បានរកឃើញប្រវត្តិរូបជីតារបស់គាត់ឈ្មោះ ភាគ គឹម ហៅ ស៊ិន ។ ដូច្នេះ គាត់ក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីរកយុត្តិធម៌ជូនជីតារបស់គាត់ដែលបានស្លាប់នៅក្នុងគុកទួលស្លែង ។

ទោះបីជា ស៊ីណែត មានការមមាញឹកនឹងការងារក៏ដោយ ក៏គាត់មិនដែលអាក់ខានក្នុងការចូលរួមសវនាការកាត់ទោសអតីតប្រធានមន្ទីរស-២១ ឬ គុកទួលស្លែង កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរ ។ ជារៀងរាល់ពេលដែលមានសវនាការ ស៊ីណែត តែងតែធ្វើដំណើរពីខេត្តកំពង់ធំមកភ្នំពេញ ។ រយៈពេល៧៧ថ្ងៃនៃសវនាការកាត់ទោស ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ ១៩៤៩ ស៊ីណែត បានចូលរួមដោយផ្ទាល់នៅក្នុងសាលាក្តីនេះ ។ ស៊ីណែត ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតបានទទួលជំនួយផ្នែកផ្លូវច្បាប់តាមរយៈមេធាវីជាតិ និងអន្តរជាតិ ។

ស៊ីណែត យល់ឃើញថា ការចូលរួមនេះពិតជាមានសារសំខាន់ណាស់សម្រាប់គាត់ ដើម្បីយល់ដឹងពីដំណាក់កាលរបស់ច្បាប់ និងការផ្តល់សក្ខីកម្មរបស់សាក្សី ។ ស៊ីណែត បានបន្តថា ចាប់តាំងពីថ្ងៃបញ្ចប់កិច្ចដំណើរការសវនាការនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ រហូតមកដល់ថ្ងៃប្រកាសសាលក្រមរបស់ ឌុច ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ គាត់មានក្តីបារម្ភថា តុលាការអាចនឹងបដិសេធមិនទទួលស្គាល់គាត់ជាចៅស្រីរបស់ ភាគ គឹម ហៅ ស៊ិន ដែលស្លាប់នៅទួលស្លែង ព្រោះថាមិនមានឯកសារណាដែលអាចបញ្ជាក់ពីចំណងសាច់ញាតិរវាងគាត់និងជីតារបស់គាត់នោះទេ ។ រយៈពេលប្រាំបីខែដែលនៅទន្ទឹងរង់ចាំដំណឹងនេះ គាត់បានរៀបរាប់ថា «ប្រសិនបើតុលាការមិនទទួលស្គាល់ខ្ញុំ ខ្ញុំពិតជាខកចិត្តខ្លាំងណាស់ ។ ខ្ញុំនឹកស្រណោះចំពោះរឿងកើតឡើងចំពោះខ្ញុំនៅក្នុងរបបខ្មែរក្រហម ។ ម្យ៉ាងទៀត ខ្ញុំបានចូលរួមក្នុងដំណើរការនោះតាំងពីដើមដំបូងមក ដល់ទីបំផុតខ្ញុំមិនមានលទ្ធផលអ្វីទាំងអស់ ខ្ញុំខ្លាចខកបំណង និងធ្វើឲ្យខ្ញុំកាន់តែបាក់ទឹកចិត្តថែមទៀត ។ ការចូលរួមក្នុងសវនាការរបស់ ឌុច បានផ្តល់ឲ្យខ្ញុំនូវយុត្តិធម៌ពេញលេញ ។ យុត្តិធម៌នេះមានសារសំខាន់ណាស់ ហើយការទទួលស្គាល់ភាពជាជនរងគ្រោះក្នុងរបបខ្មែរក្រហមពិតជាមានអត្ថន័យធំធេងណាស់» ។ ប៉ុន្តែសំណាងល្អ គាត់មានក្រុមគ្រួសារនិងមជ្ឈមណ្ឌលបានជំរុញនិងលើកទឹកចិត្តកុំឲ្យគាត់បារម្ភ ដរាបណាសាលក្រមនៅមិនទាន់ត្រូវបានប្រកាសនៅឡើយនោះ ។

ជាចុងក្រោយថ្វីត្បិតតែសាលក្រមកាត់ទោស ឌុច បានបន្ធូរបន្ថយទោសពី៣៥ឆ្នាំមក១៩ឆ្នាំ ដែលធ្វើឲ្យជនរងគ្រោះភាគច្រើនមិនពេញចិត្តទាំងស្រុងក៏ដោយ ប៉ុន្តែចំពោះ ស៊ីណែត នៅតែមានការពេញចិត្តជាខ្លាំង ។ ស៊ីណែត បញ្ជាក់ថា «ទោះបីជាយុត្តិធម៌មិនបានមួយរយភាគរយ ក៏ខ្ញុំបានអស់ចិត្តខ្លះដែរ ព្រោះខ្ញុំជឿថាតុលាការធ្វើនេះពឹងផ្អែកទៅលើច្បាប់» ៖ ១) គាត់ត្រូវបានទទួលស្គាល់ថាជាចៅស្រីរបស់ ភាគ គឹម តាមផ្លូវច្បាប់ ។ ២) គាត់បានចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ ទោស ឌុច ជាពិសេសបានស្តាប់រឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរស-២១ ។ ទី៣) គាត់ទទួលបានការជួយជ្រោមជ្រែងពីសំណាក់មេធាវីជាតិ និងអន្តរជាតិដែលបានពន្យល់អំពីដំណើរការផ្លូវច្បាប់នៅក្នុងអង្គជំនុំជម្រះ ។ និងទី៤) គាត់បានធ្វើដំណើរទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែង និងវាលពិឃាតជើងឯកជាច្រើនលើកច្រើនសារាល់ពេលដែលមានសវនាការរបស់ ឌុច ព្រមទាំងបានធ្វើបុណ្យឧទ្ទិសកុសលដល់លោកតានៅគុកទួលស្លែង ។ ចុងក្រោយ ស៊ីណែត មានប្រសាសន៍ថា «ខ្ញុំមានអារម្មណ៍ស្រឡះក្នុងខ្លួនច្រើន ក្រោយពីប្រកាសសាលក្រមរបស់ ឌុច ។ ខ្ញុំក៏សូមអរគុណដល់តុលាការដែលផ្តល់ឱកាសដល់ជនរងគ្រោះបានចូលរួមក្នុងដំណើរការសនាវការនេះដែរ» ។ ទោះជាយ៉ាងណា ក៏ ស៊ីណែតមានការសោកស្តាយចំពោះដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលមិនត្រូវបានទទួលស្គាល់ដោយតុលាការក្នុងដំណើរការនីតិវិធីកាត់ទោសអតីតប្រធានគុកទួលស្លែង ។

**សេង គន្ធី**

# ស្អប់ខ្មែរក្រហម

សាក់ បូរ៉ា មានស្រុកកំណើតនៅខេត្តព្រៃវែង និងជាគ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាល័យភ្នំស្រុកខេត្តបន្ទាយមានជ័យ ។ ទោះបីជា បូរ៉ា កើតក្រោយរបបខ្មែរក្រហមក៏ដោយ ប៉ុន្តែរឿងខ្មែរក្រហមបានធ្វើឲ្យដក់ជាប់នៅក្នុងគំនិតរបស់គាត់ជានិច្ច ជាពិសេសអារម្មណ៍ភ័យខ្លាចនិងស្អប់ខ្មែរក្រហម ។ បូរ៉ា នៅចាំបានថា កាលពីនៅតូច នៅពេលដែលពុចាស់ៗនៅក្នុងភូមិឬ ឪពុកម្តាយរបស់គាត់រៀបរាប់អំពីរបបខ្មែរក្រហម ជាពិសេសការកាប់សម្លាប់ប្រជាជនយ៉ាងសាហាវព្រៃផ្សៃបានបណ្តុះគំនិតរបស់គាត់ឲ្យស្អប់ខ្មែរក្រហមជាខ្លាំង ទោះបីជាគាត់មិនដឹងថាខ្មែរក្រហមជានរណាក៏ដោយ ។ មិនតែប៉ុណ្ណោះ ថ្ងៃមួយ គ្រាន់តែពុចាស់ៗនៅក្នុងភូមិយោសនាថា «បើកូនសិស្សមិនទៅរៀន ឈ្លបនឹងមកចាប់យកទៅឲ្យវាយជាមួយអាពត» ពេលនោះ បូរ៉ា ស្រាប់តែមានអារម្មណ៍កាន់តែស្អប់ ខ្មែរក្រហមថែមទៀត ។

ប៉ុន្តែ អារម្មណ៍ទាំងនេះបានផ្លាស់ប្តូរបន្តិចម្តងៗតាមរយៈការសិក្សានិងស្រាវជ្រាវបន្ថែមទៀត ដោយ បូរ៉ា ចាប់ផ្តើមដឹងថាប្រជាជនមានទស្សនៈយល់ឃើញផ្សេងៗគ្នាចំពោះរបបខ្មែរក្រហម ។ បូរ៉ា បានរៀបរាប់ឲ្យដឹងថា ទោះបីជារបបនេះសម្លាប់មនុស្សយ៉ាងសាហាវយោរយៅយ៉ាងណាក៏ដោយ ក៏ប៉ុន្តែនៅតែមានប្រជាជនមួយចំនួនស្រឡាញ់និងគាំទ្រខ្មែរក្រហមដែរ ។ ជាក់ស្តែង អ៊ំស្រីម្នាក់ដែលរស់នៅភូមិភាស ឃុំសារង្គ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ តែងតែលើកសរសើរពីរបបខ្មែរក្រហមរហូតដល់ពេលដែលរបបនេះដួលរលំទៅ ក៏គាត់នៅតែផ្តល់ស្បៀងដើម្បីគាំទ្រខ្មែរក្រហមទៀត ព្រោះគាត់យល់ថា ដោយសារតែពេលដែលវៀតណាមចូលមករំដោះបែរជាកងទ័ពទាំងនេះធ្វើបាបប្រជាជនទៅវិញនិងយករបស់របរប្រជាជនហូបដោយគ្មានការអនុញ្ញាតឡើយ ។

អ៊ំស្រីនោះបានរៀបរាប់ឲ្យដឹងទៀតថានៅក្នុងរបបខ្មែរក្រហមគាត់មានជីវភាពរស់នៅស្រួល ដោយគាត់ធ្វើការនៅក្នុងកងនារីមួយក្រុមមានគ្នាចំនួន១០នាក់ ។ ដោយសារតែក្រុមរបស់គាត់ជាក្រុមឆ្នើម ដូច្នេះគាត់មានរបបហូបចុកគ្រប់គ្រាន់ហើយថែមទាំងអាចបើកយករបបនោះមកផ្ញើគ្រួសាររបស់គាត់និងអាចមកលេងផ្ទះបានទៀតផង ។ លើសពីនេះទៅទៀត ការរស់នៅមិនដែលមានការភ័យខ្លាចទេ ព្រោះខ្មែរក្រហមមិនបានសម្លាប់មនុស្សហើយមួយសប្តាហ៍ម្តងថែមទាំងមានធ្វើនំអន្សមឲ្យប្រជាជនហូបថែមទៀត ។ ដោយសារតែការស្រឡាញ់និងគាំទ្រកងទ័ពខ្មែរក្រហមបែបនេះ ទោះបីជាវៀតណាមចូលមករំដោះនិងខំប្រយុទ្ធដើម្បីឲ្យខ្មាំងចេញពីភូមិក៏ដោយ ក៏គាត់នៅតែជួយឧបត្ថម្ភជាអង្ករទៅឲ្យខ្មែរក្រហមដែរ ។ ប៉ុន្តែ គាត់ក៏មិនបដិសេធពីរឿងដែលថាប្រជាជនស្អប់ខ្មែរក្រហមនិងប្រឆាំងរដ្ឋាភិបាលដែលវាយខ្មែរក្រហមឲ្យដួលរលំដែរ ។ ហេតុដូច្នេះហើយ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់កូនគាត់ ភ្ញៀវដែលចូលរួមមានទាំងទាហានខ្មែរក្រហមនិងកងទ័ពរបស់រដ្ឋាភិបាលបានមកហូបនៅក្នុងរោងតែមួយ ។

បូរ៉ា មានការជឿងឆ្ងល់ជាខ្លាំងថាហេតុអ្វីបានអ៊ំស្រីនេះគាំទ្រខ្មែរក្រហម ប៉ុន្តែបែរជាប្រជាជននៅក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យស្អប់ខ្មែរក្រហមទៅវិញ ហើយមិនចង់ឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ព្រោះខ្មែរក្រហមបានបង្ខំឲ្យធ្វើការជាទម្ងន់ និងឲ្យហូបតែបបររាវៗប៉ុណ្ណោះ ជាពិសេសសម្លាប់មនុស្សយ៉ាងសាហាវយោរយៅបំផុត ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ បូរ៉ា មិនចង់ឲ្យរបបនេះកើតឡើងជាលើកទីពីរទៀតទេ ។ ហេតុដូច្នេះហើយ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះពិតជាល្អប្រសើរខ្លាំងណាស់ ព្រោះធ្វើឲ្យលោកគ្រូ-អ្នកគ្រូ យល់កាន់តែច្បាស់ថែមទៀត ដើម្បីយកទស្សនៈនេះទៅសាបព្រោះដល់កូនសិស្សឲ្យកាន់តែជឿជាក់ និងយល់ថាមិនមែនជាការនិយាយបន្លាចនោះទេ ហើយត្រូវនាំគ្នាសិក្សារៀនសូត្រដើម្បីធ្វើឲ្យប្រទេសជាតិកាន់តែមានភាពរុងរឿងទៅមុខ ។ **គាត លក្ខិណា**

# ការប្រជុំជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា យល់ដឹងពីអំពើប្រល័យពូជសាសន៍ : ការពិត ការចងចាំ និង យុត្តិធម៌ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

នៅខែកញ្ញា ឆ្នាំ២០១០ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបួននាក់ត្រូវបានចោទប្រកាន់ជាផ្លូវការដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានទៅលើច្បាប់កម្ពុជា ដែលការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ជាពិសេសបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំង ។ ទោះបីជាប្រជាពលរដ្ឋកម្ពុជាប្រើពាក្យ «ប្រល័យពូជសាសន៍» ជាយូរមកហើយដើម្បីពិពណ៌នាការសម្លាប់ដោយរបបខ្មែរក្រហមក៏ដោយ ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាមិនបានយល់ស្របទៅលើអត្ថន័យរបស់ពាក្យនោះឬថាប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងច្បាស់លាស់អំពីនិយមន័យរបស់ពាក្យនេះតាមផ្លូវច្បាប់និងប្រវត្តិសាស្ត្រយ៉ាងណាទេ ។

ដោយទទួលស្គាល់ការយល់ច្រឡំយ៉ាងខ្លាំងពីបទចោទលើអំពើប្រល័យពូជសាសន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំការប្រជុំធំៗពីរជាមួយក្រុមជនជាតិភាគតិចនៅកម្ពុជា ។ ការប្រជុំលើកទី១ធ្វើឡើងនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយបង្ហាញជូនអ្នកចូលរួមពីការប្រើប្រាស់ពាក្យប្រល័យពូជសាសន៍និងប្រវត្តិនៃពាក្យដោយស្របតាមច្បាប់ក្នុងស្រុកនិងអន្តរជាតិ ក៏ដូចជាវិទ្យាសាស្ត្រសង្គមនិងអក្សរសាស្ត្រខ្មែរ ។ ការប្រជុំក៏បញ្ចូលសកម្មភាពមួយចំនួនដើម្បីផ្តល់កិត្តិយសដល់ជនរងគ្រោះ និងជំរុញឲ្យមានការសន្ទនាជុំវិញប្រធានបទទាំងឡាយដែលបានលើកឡើង ។

បន្ថែមទៅលើការបកស្រាយពាក្យប្រល័យពូជសាសន៍ និងជួយឲ្យប្រជាពលរដ្ឋចូលរួមក្នុងដំណើររបស់តុលាការ ការប្រជុំនេះមានគោលបំណងដើម្បីរៀបចំឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែពេញលេញតាមរយៈការប្រមូលសាច់រឿងរបស់អ្នកចូលរួម ការពិភាក្សា និងការចូលរួមក្នុងដំណើរការស្វែងរកការពិត ។

## ១) អ្នកចូលរួម


អ្នកចូលរួមនៅក្នុងវេទិកាពិភាក្សា

តំណាងក្រុមជនជាតិភាគតិចប្រហែល២០០នាក់ បានចូលរួមក្នុងការប្រជុំថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ។ អ្នកចូលរួមទាំងនេះរួមមាន ជនជាតិចាម (ស្ត្រីនិងអ្នកដឹកនាំសហគមន៍) សមាជិកខ្មែរកម្ពុជាក្រោម សមាជិកក្រុមជនជាតិភាគតិចវៀតណាម ព្រះសង្ឃ បព្វជិត និងសមាជិកក្រុមជនជាតិភាគតិចតំបន់ភ្នំ ។

ក្រុមជនជាតិភាគតិចទាំងនេះបានរងគ្រោះយ៉ាងធ្ងន់ធ្ងរក្រោមរបបខ្មែរក្រហម ។ ជនជាតិចាមចំនួនមួយសែនទៅបួនសែននាក់ និងជនជាតិភាគតិចវៀតណាមប្រហែលបីសែននាក់បានស្លាប់បាត់បង់ជីវិតដោយសារគោលនយោបាយខ្មែរក្រហម ។

ខ្មែរកម្ពុជាក្រោមជាច្រើនត្រូវបានចោទប្រកាន់ថា មាន «ក្បាលយួនខ្លួនខ្មែរ» ហើយត្រូវបានជម្លៀសចេញ ធ្វើទារុណកម្ម និងសម្លាប់ ។ ព្រះសង្ឃត្រូវបានបង្ខំឲ្យសឹក និងធ្វើការនៅតាមវាលស្រែ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញតំណាងក្រុមជនជាតិភាគតិចមកចូលរួមការប្រជុំរួមជាមួយគ្នា ។ ការប្រជុំតម្រូវឲ្យមានការរៀបចំទុកជាមុននិងការសម្របសម្រួលយ៉ាងខ្លាំង ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំការដឹកជញ្ជូន កន្លែងស្នាក់នៅ ម្ហូបអាហារ និងសោហ៊ុយធ្វើដំណើរពីលំនៅដ្ឋានរបស់អ្នកចូលរួមមកទីក្រុងភ្នំពេញ ។

**២) កម្មវិធីពេលព្រឹក ៖ ប្រល័យពូជសាសន៍ក្នុងបរិបទច្បាប់ និងវប្បធម៌**

នៅពេលដែលអ្នកចូលរួម វាគ្មិន អ្នកសារព័ត៌មាន និងអ្នកអង្កេតបានជួបជុំគ្នានៅក្នុងសាលប្រជុំនៅម៉ោង៨ព្រឹក ថ្ងៃទី២៥ កញ្ញា សូ ហ្វារីណា ដែលជាប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកកម្មវិធីប្រជុំជាមួយសុន្ទរកថាស្វាគមន៍ និងសេចក្តីសង្ខេបកម្មវិធីប្រជុំ ។

បន្ទាប់មក កញ្ញា ហ្វារីណា បានស្នើឲ្យអ្នកចូលរួមបំពេញតារាងស្ទង់មតិដើម្បីស្ទាបស្ទង់មើលការយល់ដឹងនិងទស្សនៈវិស័យទៅលើអំពើប្រល័យពូជសាសន៍ ។ សំណួរនៅក្នុងតារាងស្ទង់មតិរួមមាន សមាជិកក្រុមគ្រួសារដែលបានបាត់បង់ក្រោមរបបខ្មែរក្រហម មុនដំបូងអ្នកចូលរួមឮពាក្យ «ប្រល័យពូជសាសន៍» ហេតុផលដែលសាលាក្តីមិនធ្វើការចោទប្រកាន់មេដឹកនាំខ្មែរក្រហមក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើក្រុមជនជាតិភាគតិចផ្សេងទៀតក្រៅពីជនជាតិភាគតិចចាម និងជនជាតិភាគតិចវៀតណាម ។

នៅពេលដែលអ្នកចូលរួមទទួលបានក្រដាសស្ទង់មតិ សាលប្រជុំមានសភាពស្ងាត់ជ្រងំមួយស្របក់ ដោយសារអ្នកចូលរួមកំពុងតែគិតពីចម្លើយយ៉ាងប្រុងប្រយ័ត្ន ។ មានតែសំឡេងខ្សឹបៗរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយដល់អ្នកចូលរួមដែលមិនចេះសរសេរ ។ កញ្ញា ហ្វារីណា បានពន្យល់សំណួរទាំងឡាយ ហើយទុកពេលវេលាឲ្យអ្នកចូលរួមបំពេញវិញ ។ បន្ទាប់ពីផ្តល់ពេលវេលាអស់មួយស្របក់មក កញ្ញា ហ្វារីណា បានសុំឲ្យអ្នកចូលរួមប្រគល់តារាងស្ទង់មតិមកឲ្យក្រុមការងារ ។ បន្ទាប់មកទៀត កញ្ញា ហ្វារីណា បានជម្រាបឈ្មោះវាគ្មិនកិត្តិយសដែលនឹងធ្វើបទបង្ហាញនៅក្នុងការប្រជុំ ដែលវាគ្មិនដំបូងគឺលោក អេនគ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ក) និយមន័យប្រល័យពូជសាសន៍តាមផ្លូវច្បាប់និងប្រវត្តិអនុសញ្ញាការពារអំពើប្រល័យពូជសាសន៍ ដោយលោក អេនគ្រូ ខេលី និងតំណាងរបស់លោកស្រី ជា លាង**


ការប្រជុំពិភាក្សាពីអំពើប្រល័យពូជសាសន៍

លោក អេនគ្រូ ចាប់ផ្តើមសុន្ទរកថារបស់គាត់ដោយការទទួលស្គាល់ថាអំពើប្រល័យពូជសាសន៍គឺជាពាក្យពិបាកកំណត់ ហើយមេធាវីជាច្រើនមានការលំបាកក្នុងការស្វែងរកការពន្យល់ពាក្យនេះតាមផ្លូវច្បាប់ឲ្យបានសមស្រប ។ ទោះបីយ៉ាងណាក៏ដោយ មុនពេលចូលដល់ការពិភាក្សាពីការវិវត្តនៃនិយមន័យពាក្យនេះ គាត់យកពេលខ្លះពិភាក្សាបទចោទប្រកាន់លើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ គាត់បានផ្តល់យោបល់ដល់អ្នកចូលរួមមិនឲ្យសង្កត់ធ្ងន់ហួសហេតុពេកទៅ

លើការចោទពីបទប្រល័យពូជសាសន៍ នៅពេលគិតទៅដល់បទចោទទូទៅផ្សេងៗទៀតទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ខណៈពេលដែលអំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងច្បាប់អន្តរជាតិ មានឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើនទៀតនៅក្រោមច្បាប់ជាតិនិងអន្តរជាតិដែលមេដឹកនាំទាំងបួននាក់ត្រូវបានចោទប្រកាន់ ។

បទបង្ហាញទូទៅរបស់លោក អេនឌ្រូ បានចាប់ផ្តើមពីការពិពណ៌នាហេតុការណ៍ទាំងឡាយដែលនាំឲ្យកើតមានច្បាប់និងបញ្ញត្តិប្រល័យពូជសាសន៍ ការពិភាក្សាពីក្របខណ្ឌច្បាប់បច្ចុប្បន្ន ការអនុវត្តច្បាប់លើអង្គហេតុក្នុងសំណុំរឿង០០២ ការឲ្យយោបល់ជាថ្មីម្តងទៀតដល់អ្នកចូលរួមដោយមិនឲ្យគិតថាមានតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មយង់ឃ្នងជាងគេនៅក្នុងបទចោទទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

អ្នកចូលរួមប្រុងប្រៀបស្តាប់ដោយមានការប្រុងប្រយ័ត្នជាពិសេសនៅពេលដែលលោក អេនឌ្រូ បកស្រាយអំពីសំណុំរឿង ០០២ ។ គាត់បានប្រាប់ថា ការិយាល័យរបស់គាត់កំពុងតែធ្វើការងារឈានទៅមុខ ចេញពីការបង្ហាញថាខ្មែរក្រហមបានផ្សឹកនិងសម្លាប់ព្រះសង្ឃដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងច្បាស់ក្រឡែត រហូតដល់ការបង្ហាញថា ខ្មែរក្រហមបំបែកនិងសម្លាប់ជនជាតិចាម ដែលនេះជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងប្រល័យពូជសាសន៍ ។ ក្នុងការគោរពដល់ជនជាតិភាគតិចវៀតណាម លោក អេនឌ្រូ បានបញ្ជាក់ថាភ័ស្តុតាងនៃការបញ្ជូនចេញពីភូមិភាគបូព៌ាភូមិភាគកណ្តាល និងភូមិភាគនិរតីគួរតែអាចប្រើដើម្បីបង្ហាញពីបទចោទពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ។ អ្នកចូលរួមរក្សាភាពស្ងប់ស្ងាត់ជាសញ្ញានៃការទទួលយកនូវអ្វីដែលសហព្រះរាជអាជ្ញាបានរៀបរាប់ ។

លោក អេនឌ្រូ បញ្ចប់សុន្ទរកថារបស់គាត់ ហើយប្រគល់នាទីឲ្យទៅលោក ចាន់ តារាវស្មី សហព្រះរាជអាជ្ញារងកម្ពុជា ។ លោកបានថ្លែងអំណរគុណដល់លោក អេនឌ្រូ ចំពោះការបកស្រាយយ៉ាងក្បោះក្បាយ ហើយក៏បន្តសង្កត់ធ្ងន់យ៉ាងស៊ីជម្រៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ គាត់កត់សម្គាល់ថា ខ្មែរក្រហម «បំផ្លាញ» ចំនួនប្រជាជនតាមមធ្យោបាយជាច្រើន ហើយអស់រយៈកាលជាច្រើនឆ្នាំបន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំ ដោយធ្វើឲ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេស និងពន្យឺតការអភិវឌ្ឍយ៉ាងខ្លាំង ។ អ្នកចូលរួមយល់ស្របនឹងការលើកឡើងនេះដោយសំឡេងខ្សឹបៗ ហើយក្រោយមកក៏ទះដៃយ៉ាងខ្លាំងបន្ទាប់ពីគាត់បញ្ចប់សុន្ទរកថា ។

កញ្ញា ហ្វារីណា បានថ្លែងអំណរគុណដល់វាគ្មិនទាំងពីររូបហើយប្រកាសប្រាប់អ្នកចូលរួមថា គាត់អាចមានឱកាសសួរសំណួរទៅកាន់សហព្រះរាជអាជ្ញាទាំងពីរ ប៉ុន្តែជាដំបូងទទួលស្គាល់ថា ទស្សនៈច្បាប់មានភាពស្មុគស្មាញនិងលំបាកយល់បន្តិច ហើយសុំឲ្យអ្នកចូលរួមប្រើប្រាស់ឱកាសនេះដើម្បីសួរនូវអ្វីដែលមិនទាន់យល់ ។ អ្នកចូលរួមពីរ-បីនាក់បានសួរសំណួរ រួមទាំងបុរសម្នាក់ដែលចង់ដឹងអំពីទោសទណ្ឌដែលខ្ពស់បំផុតសម្រាប់អ្នកដែលជាប់ទោស ហើយម្នាក់ទៀតសួរថាហេតុអ្វីបានជាប្រទេសដែលរួមចំណែកឲ្យមានជម្លោះនៅកម្ពុជាមិនត្រូវបានកាត់ទោស ។ សម្រាប់សំណួរចុងក្រោយ លោក អេនឌ្រូ ឆ្លើយថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយុត្តាធិការជំនុំជម្រះតែបុគ្គលដែលប្រព្រឹត្តកំហុស មិនអាចកាត់ទោសប្រទេសទេ ដែលចម្លើយនេះហាក់ដូចជា


វាគ្មិនបកស្រាយអំពីនិយមន័យនៃអំពើប្រល័យពូជសាសន៍

ធ្វើឲ្យអ្នកចូលរួមបី-បួននាក់ មិនសូវសប្បាយចិត្ត ។

### ១) ការរំឭកនិងគោរពដល់ក្រុមជនជាតិភាគតិច

ដោយសម្រាកបន្តិចពីការធ្វើបទបង្ហាញនិងបានពិភាក្សាពីអំពើប្រល័យពូជសាសន៍ លោក អេនឌ្រូ ខេលី លោក ឆាំង យុ និងតំណាងរបស់លោកស្រី ជា លាង បានជូនផ្ទាំងចំណារដល់តំណាងក្រុមជនជាតិភាគតិចដែលចូលរួមក្នុងកម្មវិធីប្រជុំ ។ នេះជាឱកាសមួយប្រកបដោយភាពឱឡារិកនិងមានអត្ថន័យបំផុតសម្រាប់អ្នកចូលរួម ។

ខ្លឹមសារដែលបង្កប់នៅក្នុងផ្ទាំងចំណារសម្រាប់ក្រុមទាំងប្រាំរួមមាន ៖

**សម្រាប់ជនជាតិចាម ៖**



ពិធីប្រគល់ជូនផ្ទាំងចំណារដល់ជនជាតិចាម

«ចំណារនេះធ្វើឡើងដើម្បីរំឭកនូវការឈឺចាប់និងការសម្លាប់របស់ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ចំណារនេះក៏បង្ហាញឲ្យឃើញនូវសេចក្ដីសង្ឃឹមដ៏ស្ងប់ស្ងាត់ និងកំណត់ថាយុត្តិធម៌នឹងកើតមានឡើង ហើយហេតុការណ៍ទាំងឡាយពីអតីតកាលនឹងមិនកើតឡើងជាថ្មីម្ដងទៀតទេ ទោះបីជានៅកន្លែងណាក៏ដោយ ។ សម្រាប់អ្នកដែលអានចំណារនេះនៅពេលអនាគតនឹងមិនបំភ្លេចនូវអ្វីដែលបានកើតឡើងចំពោះជនជាតិឡើយ ។ សូមសម្ដែងនូវការគោរពនិងរាប់អានគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃក្នុងជីវិតរស់នៅរបស់អ្នក» ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សម្រាប់ជនជាតិភាគតិចតំបន់ភ្នំ ៖**



ពិធីប្រគល់ជូនផ្ទាំងចំណារដល់ជនជាតិភាគតិចតំបន់ភ្នំ

«ចំណារនេះរំឭកឡើងវិញប្រកបដោយក្ដីស្រឡាញ់និងមេត្តាករុណាចំពោះសមាជិកជនជាតិភាគតិចទាំងឡាយនៅក្នុងប្រទេសកម្ពុជាដែលបានទទួលរងទារុណកម្មនិងស្លាប់បាត់បង់ជីវិតក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ សូមចងចាំថា ទោះបីជាយើងមានភាពខុសគ្នាក៏ដោយ ចំណងរួមជាមូលដ្ឋានរបស់មនុស្ស គឺយើងរស់នៅក្នុងភពដ៏តូចមួយនេះជាមួយគ្នា ។ យើងដកដង្ហើមដោយប្រើខ្យល់តែមួយប្រភេទ ។ យើងទាំងអស់គ្នាឲ្យតម្លៃទៅលើអនាគតកូនចៅរបស់យើង ។ យើងទាំងអស់គ្នាមិនមែនអមតៈទេ ។

អំពើប្រល័យពូជសាសន៍ ៖ ការពិត ការចងចាំ និងយុត្តិធម៌ ។ ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សម្រាប់ព្រះសង្ឃ ៖**

«ក្នុងការចងចាំព្រះសង្ឃប្រកបដោយសេចក្ដីគោរពដែលបានសុគតនិងទទួលរងដោយសារជំនឿនៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ យកឈ្នះកំហឹងដោយក្ដីស្រឡាញ់ យកឈ្នះកំហុសដោយធ្វើអំពើល្អ យកឈ្នះមនុស្សចិត្តអាក្រក់ដោយស្មារតីសប្បុរស និងយកឈ្នះមនុស្សកុហកដោយការពិត» ។



ពិធីប្រគល់ជូនផ្ទាំងចំណារដល់ព្រះសង្ឃ

អំពើប្រល័យពូជសាសន៍ៈ ការពិត ការចងចាំ និងយុត្តិធម៌ ។

ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សម្រាប់បព្វជិត ៈ**

«ការរំឭកឡើងវិញនូវជីវិតនិងជំនឿរបស់បព្វជិតដែលត្រូវបានសម្លាប់និងស៊ូទ្រាំនឹងការលំបាកក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ សេចក្តីស្រឡាញ់និងមេត្តាករុណាជាភាពចាំបាច់របស់យើង មិនមែនភាពល្អប្រណីតនោះទេ ។ ប្រសិនបើគ្មានសេចក្តីស្រឡាញ់និងមេត្តាករុណាទេនោះ មនុស្សជាតិមិនអាចរស់រានបានឡើយ» ។

អំពើប្រល័យពូជសាសន៍ៈ ការពិត ការចងចាំ និងយុត្តិធម៌ ។




ពិធីប្រគល់ជូនផ្ទាំងចំណារដល់បព្វជិត

ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សម្រាប់ជនជាតិភាគតិចវៀតណាម ៈ**



ពិធីប្រគល់ជូនផ្ទាំងចំណារដល់ជនជាតិភាគតិចវៀតណាម

«សម្រាប់ជនជាតិភាគតិចវៀតណាមដែលត្រូវបានសម្លាប់ និងធ្វើទុក្ខបុកម្នេញដោយខ្មែរក្រហមសូមឲ្យយុត្តិធម៌កើតមានឡើងចំពោះអ្នកដែលបានទទួលរងនិងស្លាប់បាត់បង់ជីវិត ហើយសូមឲ្យព្រលឹងរបស់អ្នកដែលបានចែកឋានទៅកាន់សុគតិភព» ។

អំពើប្រល័យពូជសាសន៍ៈ ការពិត ការចងចាំ និងយុត្តិធម៌ ។

ភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅពេលដែលចំណារចុងក្រោយ (ដែលមានបង្កប់ទាំងអក្សរខ្មែរនិងអង់គ្លេស) ត្រូវបានប្រគល់ជូនដល់តំណាងអ្នកចូលរួម លោក ឆាំង យុ បានលើកផ្ទាំងរូបថតរបស់អ្នកគ្រូ ខុន សាវិន ឡើងលើ ហើយប្រគល់ឲ្យលោក អេនឌ្រូ ។ បន្ទាប់មក

លោក អេនឌ្រូ បានជូនរូបថតនេះទៅអ្នកគ្រូ សាវិន ដោយសួរគាត់ថាតើគាត់នៅចងចាំការប្រជុំនៅឃុំរំលេចកាលពីខែមិថុនាកន្លងទៅដែរឬអត់ ។ លោក អេនឌ្រូ និយាយថា អ្នកគ្រូបានប្រាប់គាត់អំពីសាច់រឿងរបស់ឪពុកខ្លួនដែលបានលះបង់ជីវិតដើម្បីជួយស្រោចស្រង់ជីវិតរបស់អ្នកគ្រូ ហើយថាគាត់មានការរំជើបរំជួលនៅពេលដែលឮរឿងនេះ ។ នៅពេលដែលគាត់បានឃើញរូបថតរបស់អ្នកគ្រូ សាវិន ដែលថតដោយ កញ្ញា ស្រ៊ុន វ៉ូសានី មកពីអង្គភាពឆ្ពោះទៅរកយុត្តិធម៌នៅអាស៊ី គាត់ចង់ពង្រីករូប និងដាក់ស៊ុមជូនដល់អ្នកគ្រូ ។ អ្នកគ្រូ សាវិន ឈរក្បែរលោក អេនឌ្រូ ដែលកំពុងអានខ្លឹមសារដែលយកចេញពីគម្ពីរគួរអាននិងគម្ពីរសាសនាគ្រិស្តចាស់នៅខាងក្រោមរូបថត : «អ្នកណាដែលសង្គ្រោះជីវិតមួយនេះចាត់ទុកថាអ្នកនោះបានសង្គ្រោះពិភពលោកទាំងមូល ។ អ្នកណាដែលបំផ្លាញជីវិតមួយហាក់ដូចជាអ្នកនោះបំផ្លាញពិភពលោកទាំងមូល» ។

## ក) អំពើប្រល័យពូជសាសន៍ក្នុងបរិបទវប្បធម៌

ការប្រជុំនេះបន្តជាមួយការធ្វើបទបង្ហាញរបស់វាគ្មិនបីនាក់ដែលនិយាយអំពីនិយមន័យប្រល័យពូជសាសន៍នៅក្នុងបរិបទច្បាប់និងអក្សរសាស្ត្រ ។ ដំបូង លោកសាស្ត្រាចារ្យ ជួរ គារី ប្រធាននាយកដ្ឋានខេមរនីយកម្ម វចនានុក្រម និងបកប្រែនៅរាជបណ្ឌិត្យសភាកម្ពុជា ពិភាក្សានិយមន័យអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទអក្សរសាស្ត្រនិងវប្បធម៌ ។ គាត់បានពន្យល់ថា ការពិតពាក្យប្រល័យពូជសាសន៍តាមអក្សរសាស្ត្រខ្មែររួមមានធាតុផ្សំបីខុសៗគ្នាគឺពាក្យ «ប្រល័យ» «ពូជ» និង «សាសន៍» និង «វប្បធម៌ជាមូលដ្ឋានរបស់មនុស្ស» ។ លោកសាស្ត្រាចារ្យបានសង្ខេបពាក្យនេះដោយនិយាយថាអំពើប្រល័យពូជសាសន៍គឺជាអំពើបំផ្លិចបំផ្លាញក្រុមជាក់លាក់ណាមួយ ទោះបីជាក្រុមនោះមានវប្បធម៌ដូចគ្នាឬខុសគ្នាក៏ដោយ ។

លោក ស៊ីវ ធួន ជាវាគ្មិនទីពីរ និងជាគ្រូបង្រៀនថ្នាក់ជាតិក្នុងគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានពិភាក្សាពាក្យទាំងពីរនេះ ដោយភ្ជាប់ជាមួយពាក្យខ្មែរក្រហម មានដូចជាពាក្យ «ការសម្លាប់បំផុតពូជ» និង «ដកទាំងឫស» ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ខ្មែរក្រហមជឿថាគេត្រូវតែបំផ្លាញក្រុមឬជីកទាំងឫសនូវក្រុមជាក់លាក់ទាំងនេះ ។ គាត់បានបញ្ជាក់ថា ខ្មែរក្រហមមិនបានជ្រើសរើសដោយផ្អែក




ពិធីប្រគល់ជូនផ្ទាំងចំណារដល់ខ្មែរក្រោម

លើអ្វីដែលគេគិតថាជាក្រុមដែលត្រូវតែបំផ្លាញចោល គេស្វះស្វែងបំផ្លាញក្រុមគ្រួសារ ជាតិសាសន៍ និងសមាជិកក្រុមទាំងស្រុងដែលជាក្រុមងាយស្រួលធ្វើការកំណត់អត្តសញ្ញាណតាមរយៈរបៀបរបបនៃការរស់នៅនិងវប្បធម៌របស់គេ ។

វាគ្មិនទីបីដែលត្រូវនិយាយគឺលោក អេង កុកថាយ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គាត់បានលើកឡើងថា គាត់យល់ស្របនឹងការបកស្រាយនិយមន័យប្រល័យពូជសាសន៍តាមអក្សរសាស្ត្រខ្មែរ ហើយចង់ភ្ជាប់និយមន័យនោះទៅនឹងវិទ្យាសាស្ត្រសង្គម ។ ដោយប្រើអត្ថបទរបស់លោកសាស្ត្រចារ្យផ្នែកសិទ្ធិមនុស្សដ៏ល្បីល្បាញ គឺលោក វីលៀម សាបាស់ ធ្វើជាមូលដ្ឋាន លោក អេង កុកថាយ បានពិនិត្យមើលពីទំនាក់ទំនងរវាងទស្សនៈស្តីពីអំពើប្រល័យពូជសាសន៍តាមទស្សនវិជ្ជាច្បាប់និងសង្គមវិទ្យា ។

គួរបញ្ជាក់ថា ការបកស្រាយពីនិយមន័យប្រល័យពូជសាសន៍របស់វាគ្មិនទាំងបីខាងលើនេះមានភាពខុសគ្នាបន្តិចពីការបកស្រាយតាមផ្លូវច្បាប់របស់លោក អេនឌ្រូ សហព្រះរាជអាជ្ញាអន្តរជាតិ ។ លោក អេនឌ្រូ បានសង្កត់ធ្ងន់ថា អំពើប្រល័យពូជសាសន៍គឺជាចេតនាសម្លាប់សមាជិកជាតិ ពូជសាសន៍ ជាតិពន្ធុ និងសាសនាទាំងស្រុងឬដោយផ្នែក ហើយថាដូចជាក្នុងករណីសំណុំរឿង០០២ ខ្មែរក្រហមត្រូវបានរកឃើញថា មានចេតនាបំបាត់ពូជសាសន៍ចាមនិងវៀតណាម ។ បើតាមការបកស្រាយរបស់លោកសាស្ត្រាចារ្យ ជូរ គារី និង ស៊ីវ ឌួន វិញឃើញថា ខ្មែរក្រហមប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិទាំងអស់ដែលរស់នៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ ប៉ុន្តែលោកសាស្ត្រាចារ្យទាំងពីរក៏ទទួលស្គាល់ថា ការបកស្រាយនេះវាទូលំទូលាយ ហើយថាទាក់ទងនឹងទោសទណ្ឌ និងការចោទប្រកាន់គឺអាស្រ័យលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់ជាអ្នកកំណត់ ។

នៅពេលវាគ្មិនទាំងបីនាក់បញ្ចប់ការធ្វើបទបង្ហាញរបស់ខ្លួន កញ្ញា ហ៊ុរីណា បានអនុញ្ញាតឲ្យមានការសួរសំណួរ ។ ស្ត្រីម្នាក់ដែលមកពីខេត្តមណ្ឌលគិរីបានសួរអំពីដំណើរការនៃការសងសំណងដែលដាក់ចេញដោយតុលាការ ។ សំណួររបស់គាត់បានជំរុញឲ្យបុរសចាមម្នាក់ទៀតមកពីខេត្តព្រះសីហនុសួរសំណួរដែរ ។ អ្នកចូលរួមអន្ទះសាចង់ដឹងអំពីមូលនិធិនៃការសងសំណង ព្រមទាំងទំនាក់ទំនងរវាងសំណងនិងការដាក់ទោសដែលកំណត់ដោយតុលាការ ។

## ៤) អាហារថ្ងៃត្រង់របស់អ្នកចូលរួម



ជនជាតិអ៊ីស្លាមចេញពីការប្រជុំ

ការប្រជុំនេះបានសម្រាកសម្រាប់អាហារថ្ងៃត្រង់និងការថ្វាយបង្គំរបស់ជនជាតិចាម ។ អ្នកចូលរួមមានឱកាសអង្គុយពិសាអាហារតាមបែបប្រពៃណីរួមគ្នា ។ នៅឯតុអាហារ អ្នកចូលរួមអង្គុយចម្រុះគ្នា ដែលក្នុងនោះភ្ញៀវអន្តរជាតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអង្គុយពិសាអាហារជាមួយស្ត្រីចាមមកពីខេត្តពោធិ៍សាត់ ហើយខ្មែរកម្ពុជាក្រោមអង្គុយពិសាជាមួយអ្នកចូលរួមដែលជាជនជាតិភាគតិចតំបន់ភ្នំ ។

## ៥) ការប្រជុំពេលរសៀល ការបញ្ចាំងខ្សែភាពយន្តរឿង «ឃ្លាតទៅសែនឆ្ងាយ» គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាម និងសុន្ទរកថារបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

### ក) ការសន្ទនាអំពីខ្សែភាពយន្តនិងគម្រោងប្រវត្តិសាស្ត្រ

នៅពេលជួបប្រជុំឡើងវិញ ក្រុមអ្នកចូលរួមបានទស្សនាខ្សែភាពយន្តដែលផលិតដោយលោក ឆាយ បូរ៉ា មានចំណងជើងថា «ឃ្លាតទៅសែនឆ្ងាយ» ដែលរឿងនេះបង្ហាញជូនដោយផលិតករផ្ទាល់ ។ បន្ទាប់ពីរឿងរ៉ាវដ៏គួរឲ្យព្រឺព្រួចដែលនិយាយពីការបាត់បង់សមាជិកគ្រួសារនិងការរស់រានមានជីវិតពីរបបនោះ ខ្សែភាពយន្តរបស់លោក ឆាយ បូរ៉ា រៀបរាប់ពីបទពិសោធន៍ដ៏

ដួរចត់របស់ម្តាយក្មេកគាត់ក្រោមរបបខ្មែរក្រហម ។

នៅដើមរឿង ខ្សែភាពយន្តនេះបានទាញការចាប់អារម្មណ៍ទស្សនិកជនយ៉ាងខ្លាំង ។ បុរសក៏ដូចជាស្ត្រីដែរបានឈ្ងោកទៅខាងមុខដែលនេះស្តែងឲ្យឃើញពីភាពប្រុងប្រយ័ត្នកុំឲ្យបាត់ពាក្យពេចន៍ ឬសកម្មភាពណាមួយរបស់ខ្សែរឿង ។ ទស្សនិកជនមានប្រតិកម្មតបរាល់ឈុតឆាកនីមួយៗដែលឈុតឆាកខ្លះត្រូវនឹងសាច់រឿងរបស់គាត់ដែរ ។ ជាពិសេសនៅក្នុងឈុតដែលពាក់ព័ន្ធនឹងការស្លាប់ ឬការនិរាសព្រាត់ប្រាសកូនចេញពីឪពុកម្តាយ ទស្សនិកជនភាគច្រើនបានជូតទឹកភ្នែក ខណៈដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារបានដើរចុះឡើងក្នុងបន្ទប់ប្រជុំដើម្បីផ្តល់ជំនួយចាំបាច់ ។




នៅពេលការបញ្ចាំងចប់ កញ្ញា ហុរីណា បាននិយាយទៅកាន់អ្នកចូលរួមទាំងនោះ ។ ដោយទទួលស្គាល់ថាខ្សែភាពយន្តនេះបានបង្ហាញពីបទពិសោធន៍ដ៏លំបាកជាច្រើន កញ្ញា ហុរីណា បានស្នើឲ្យអ្នកចូលរួមធ្វើការសម្រាកមួយរយៈដើម្បីធ្វើឲ្យអារម្មណ៍បានធូរស្រាលបន្តិច ។ ទោះបីជាមានភាពរំជើបរំជួលនិងលំបាកតាំងអារម្មណ៍ពីសំណាក់អ្នកចូលរួមយ៉ាងណាក៏ដោយ ខ្សែភាពយន្តនេះបានបម្រើឲ្យគោលបំណងសំខាន់មួយចំនួន ។ ទី១ ខ្សែភាពយន្តនេះនាំមកនូវការពិភាក្សាទៅលើអំពើប្រល័យពូជសាសន៍ដោយផ្សារភ្ជាប់ជាមួយសាច់រឿងរបស់បុគ្គលម្នាក់ៗដែលនេះជួយឲ្យមានការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកាន់តែច្បាស់និងទូលំទូលាយជាងមុន ។ ខ្សែភាពយន្តនេះក៏ជួយឲ្យអ្នកចូលរួមមួយចំនួនមានការធូរស្រាលផងដែរ ។ ចុងក្រោយ ខ្សែភាពយន្តនេះក៏បង្កើតឱកាសផ្សេងៗសម្រាប់ទស្សនិកជនដើម្បីស្គាល់គ្នានិងបន្តការទាក់ទងជាមួយគ្នា ។ អ្នកចូលរួមមួយចំនួនជួយលួងលោមបបោសអង្អែលថ្នមៗអ្នកអង្គុយនៅក្បែរខាងរបស់គេ នៅពេលដែលពួកគេយំ ឬសម្លឹងគ្នាទៅវិញទៅមកដោយការយល់ចិត្ត ។

***ខាងក្រោមនេះគឺជាប្រតិកម្មនិងយោបល់ផ្សេងពីអ្នកចូលរួមទៅលើខ្សែភាពយន្តនិងការប្រជុំទាំងមូល ៖***

**១) ឡាច គ្រី**

ខ្ញុំឈ្មោះ ឡាច គ្រី ដែលជាប្អូនប្រុសរបស់ ឡាច នី រស់នៅភូមិពោធិចិនដាំ ឃុំពោធិចិនដាំ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។ ខ្ញុំយល់ស្របជាមួយនឹងខ្សែភាពយន្តឯកសារនេះពីព្រោះវាស្រដៀងគ្នាជាមួយនឹងបទពិសោធន៍របស់ខ្ញុំក្រោមរបបខ្មែរក្រហម ។ នៅក្នុងខ្សែភាពយន្ត តួឯកស្រីស្ទើរតែបាត់បង់សមាជិកគ្រួសាររបស់គាត់ទាំងអស់ ។ មានតែខ្លួនគាត់និងកូនពីរនាក់ប៉ុណ្ណោះដែលអាចវិលត្រឡប់មកស្រុកកំណើតនៅភ្នំពេញវិញ ។ ចំណែកខ្ញុំបាត់បង់សមាជិកគ្រួសារ ១៧នាក់នៅក្រោមរបបខ្មែរក្រហម ។ សូមអរគុណ ។

**២) ម៉ាត់ ហ៊ីម**

ខ្ញុំសូមគោរពដល់លោក ឆាយ បូរ៉ា និងអ្នកចូលរួមទាំងអស់ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកឧបត្ថម្ភការប្រជុំនេះ ។ ខ្ញុំឈ្មោះ ម៉ាត់ ហ៊ីម មកពីឃុំត្រពាំងរពៅ ស្រុកកំពង់ត្រាច ខេត្តកំពត ។ ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់ខ្សែភាពយន្តនេះ ពីព្រោះវាជួយរំឭកយើងទាំងអស់គ្នាអំពីរបបខ្មែរក្រហមដែលហាក់ដូចជានៅថ្មីៗ ។ វាក៏ជាវិធីមួយដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋមិនឲ្យកើតឡើងសាជាថ្មីទៀត ។ ដូចដែលលោក បូរ៉ា បកស្រាយម្តងហើយថា គាត់មិនអាចបញ្ចូលអ្វីៗទាំងអស់ទៅក្នុងខ្សែភាពយន្តនេះទេដោយសារតែថវិកានិងពេលវេលាមានកម្រិត ។

ខ្ញុំសូមសួរពីរសំណួរ ។ ទី១ តើទឹកជ្រោះនៅក្នុងខ្សែភាពយន្តនេះថតនៅកន្លែងណា? ទី២ ទោះបីជាខ្ញុំបានរៀនសូត្រពីលោកសហព្រះរាជអាជ្ញានិងអ្នកជំនាញអក្សរសាស្ត្រខ្មែរកាលពី

ព្រឹកមិញទាក់ទងនឹងអំពើប្រល័យពូជសាសន៍ក៏ដោយ ប៉ុន្តែខ្ញុំនៅតែឆ្ងល់ ។ ការពិត អំពើប្រល័យពូជសាសន៍បានកើតឡើងរវាងឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៤៥ ហើយអនុសញ្ញាប្រល័យពូជសាសន៍ត្រូវបានអនុម័តនៅឆ្នាំ១៩៤៨ ។ ខ្ញុំឆ្ងល់ថាតើប្រទេសកម្ពុជាក្លាយជាសមាជិកអនុសញ្ញានោះដែរឬទេនៅពេលនោះ? ហើយប្រសិនបើជាសមាជិកហេតុអ្វីបានជាអង្គការសហប្រជាជាតិមិនអាចជួយទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា?

**បូរ៉ា ៖**

សូមអរគុណចំពោះសំណួររបស់លោក ។ ខ្ញុំសូមបកស្រាយសំណួរទី១ ។ ទីតាំងទឹកជ្រោះនេះថតនៅភ្នំវង់ ខេត្តកោះកុង ។ យើងមានការលំបាកណាស់ក្នុងការថតទីតាំងនេះពីព្រោះវាត្រូវបានលក់ទៅឲ្យក្រុមហ៊ុនឯកជន ។ ទោះបីជាយ៉ាងណាក៏ដោយ យើងបានព្យាយាមអស់ពីសមត្ថភាពដើម្បីថតយកទឹកជ្រោះនោះ ។

**៣) រីម មូសា ៖**


រីម មូសា ឡើងមានមតិ

ខ្ញុំឈ្មោះ រីម មូសា មកពីភូមិឃុំព្រែកទួល ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ខ្ញុំមកចូលរួមកម្មវិធីប្រជុំជាមួយម្តាយខ្ញុំ «ដែលយំខ្សឹកខ្សួលនៅពេលតាមដានខ្សែភាពយន្តរបស់លោក» ។ ខ្ញុំសូមហៅលោកថា «បង» ដើម្បីឲ្យកាន់តែជិតស្និទ្ធ ។ នៅពេលដែលបងផលិតខ្សែភាពយន្តនេះឡើងហាក់ដូចជាបងបានសហការជាមួយខ្ញុំអ៊ីចឹង «សើច» ។ ចំណុចដែលដូចគ្នានឹងរឿងរបស់ខ្ញុំខ្លាំងជាងគេគឺនៅត្រង់ឈុតមួយដែលម្តាយរបស់ខ្ញុំវាយខ្ញុំជាមួយនឹងមែកដំឡូងប្រហែល៧ដើម នៅពេលដែលមេកងរបស់ខ្ញុំហៅខ្ញុំឲ្យវិលត្រឡប់ទៅកងកុមារវិញ ។ ខ្ញុំទទួលស្គាល់ថា ខ្សែភាពយន្តនេះមិនដូចសាច់រឿងផ្ទាល់របស់យើងទាំងស្រុងទេដោយសារការកែសម្រួលខ្លះៗ ។ ប៉ុន្តែវាបានធ្វើឲ្យយើងចងចាំឡើងវិញ ។ នេះគឺជាការពិត ។

ខ្ញុំសូមថ្លែងអំណរគុណដល់បង បូរ៉ា ដែលបានខិតខំប្រឹងប្រែងផលិតកុននេះឡើង ។ ប្រសិនបើបងផលិតខ្សែភាពយន្តលើកក្រោយទៀតខ្ញុំស្ម័គ្រចិត្តដើរតួដើម្បីបង្ហាញពីអារម្មណ៍រំជើបរំជួលផ្សេងគ្នា «ស្ទួរទះដៃ» និងថាតើជនជាតិចាមបានតស៊ូយ៉ាងដូចម្តេចដើម្បីរស់ដោយផ្សារភ្ជាប់ជាមួយសាសនា វប្បធម៌ និងអាហារ ។ល ។ សូមឲ្យបងលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងសហការីមានសុខភាពល្អ និងទទួលជោគជ័យគ្រប់ភារកិច្ច ។

**បូរ៉ា ៖**

សូមអរគុណ មូសា ។ ខ្ញុំសូមជម្រាបថា ខ្ញុំមានគម្រោងផលិតខ្សែភាពយន្តមួយទៀតស្តីពីជនភៀសខ្លួនខ្មែរនៅតាមព្រំដែនកម្ពុជា-ថៃនៅក្រោយនិងក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីថតយកការរស់នៅក្រោមវាលពិឃាតមួយ ទៅវាលពិឃាតមួយ ។ នៅពេលខ្ញុំបានមើលខ្សែភាពយន្តដែលផលិតឡើងដោយជនជាតិញូហ្ស៊ីឡង់អំពីក្រុមគ្រួសារខ្មែរដែលរស់នៅតាមបណ្តោយព្រំដែន វាប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំជាខ្លាំង ។ ក្រុមគ្រួសារនោះមានបំណងសុះស្វែងរកការជួយពីអង្គការសហប្រជាជាតិ ប៉ុន្តែជាជំនួសមកវិញ គេទទួលរងបទពិសោធន៍ដ៏ជូរចត់ ។ បុរសដែលជាមេគ្រួសារត្រូវបានប្រាប់ថា គាត់នឹងត្រូវបញ្ជូនទៅប្រទេសទីបី ប៉ុន្តែនៅពេលគាត់ទៅដល់ព្រំដែន គាត់បែរជាស្ថិតក្នុងភាពងងឹតនៅពេលគាត់បើកបង្អួចឡើង ។ ជោគវាសនារបស់ក្រុមគ្រួសារនោះបញ្ចប់ដោយភាពជូរចត់ ។

ខ្សែភាពយន្តថ្មីនេះមិនជំរុញឲ្យមានការសងសឹកឬជំរុញឲ្យមានការយល់ឃើញជាអវិជ្ជមានទៅលើប្រទេសជិតខាងឡើយ ដោយសារតែនៅទីនោះក៏មានមនុស្សល្អជាច្រើនដែរ ។

សម្រាប់រូបខ្ញុំ នៅពេលដែលអ្នកសារព័ត៌មានសួរខ្ញុំថា តើខ្ញុំខឹងនឹង អៀង សារី ដែរឬអត់ ខ្ញុំឆ្លើយថា «បាទ» ប៉ុន្តែខ្ញុំមិនចង់សងសឹកទេ ដោយសារតែហេតុការណ៍ទាំងឡាយបានកើតឡើងជាង៣០ឆ្នាំមកហើយ ។ ខ្ញុំគិតថា វាល្មមគ្រប់គ្រាន់សម្រាប់ជនជាតិខ្មែរដែលត្រូវបញ្ឈប់ការចងគំនុំនិងសម្លាប់គ្នាទៀតហើយ ។

**៤) ពៅ ស៊ីនួន ៖**

ខ្ញុំមកពីឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ខ្ញុំរំភើបនិងរំជួលចិត្តនៅពេលដែលបានទស្សនាខ្សែភាពយន្តនេះ ។ ខ្ញុំក៏ដូចជាអ្នកចូលរួមផ្សេងទៀតដែរ សូមថ្លែងអំណរគុណដល់ការខិតខំប្រឹងប្រែងក្នុងការផលិតរឿងនេះឡើង ។ ខ្ញុំមិនដែលឃើញខ្សែភាពយន្តណាដែលវែងដូចនេះឡើយ លើកលែងតែខ្សែវីដេអូខ្លីៗស្តីអំពីជីវិតរស់នៅប្រចាំថ្ងៃក្រោមរបបខ្មែរក្រហមចាប់តាំងពីរបបនេះដួលរលំ ។

ខ្ញុំសូមសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើយ៉ាងណាចាក់ផ្សាយខ្សែភាពយន្តនេះតាមកញ្ចក់ទូរទស្សន៍ឲ្យបានពីរដងក្នុងមួយឆ្នាំដើម្បីរំឭកនិងបង្រៀនក្មេងជំនាន់ក្រោយឲ្យដឹងពីការឈឺចាប់ ដើម្បីឲ្យគេចេះជួយអភិវឌ្ឍន៍ប្រទេសជាតិ ។ ចុងក្រោយខ្ញុំសូមប្រសិទ្ធពរដល់អ្នកចូលរួមនិងអ្នករៀបចំកម្មវិធីឲ្យជួបប្រទះតែសេចក្តីសុខនិងជោគជ័យនៅគ្រប់ការងារទាំងអស់ ។

**៥) ឡាច ស៊ីថា ៖**

ខ្ញុំមកពីឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ សូមអភ័យទោសឲ្យខ្ញុំផងប្រសិនបើមានកំហុសខុសឆ្គង ។ ខ្ញុំចាប់អារម្មណ៍ទៅលើខ្សែភាពយន្តយ៉ាងខ្លាំង ព្រោះវាជាការពិត ។ យើងខ្វះខាតសព្វបែបយ៉ាងតាំងពីទូទាប់ជើងនិងម្ហូបអាហារនៅក្រោមរបបខ្មែរក្រហម ។ នៅពេលយើងប្រាប់ក្មេងជំនាន់ក្រោយអំពីការឈឺចាប់របស់យើង គេមិនជឿ ។ គេសួរយើងថា «ប្រសិនបើរបបខ្មែរក្រហមលំបាកអ៊ីចឹង ហេតុអ្វីបានជាយើងមិនរត់?» ខ្សែភាពយន្តនេះជួយរំឭកឡើងវិញនិងអប់រំឲ្យដឹងពីការឈឺចាប់របស់យើង ។

**បូវ៉ា ៖**

ខ្ញុំនឹងព្យាយាមបំពេញតាមសំណូមពររបស់បងៗ «ប្រាប់តាមត្រង់ទៅចុះ» ខ្ញុំក៏ជួបប្រទះដូចជាបងៗដែរ ។ ខ្ញុំឈឺចាប់យ៉ាងខ្លាំងនៅពេល «កូនសិស្សរបស់ខ្ញុំនិងក្មេងជំនាន់ក្រោយ» មិនជឿការឈឺចាប់របស់យើងនៅពេលយើងនិយាយប្រាប់វា ។ មន្ត្រីម្នាក់ដែលជាមិត្តភក្តិរបស់ខ្ញុំបារម្ភជំនួសខ្ញុំក្រែងលោខ្សែភាពយន្តនេះមិនអាចទាក់ទាញក្មេងជំនាន់ក្រោយដោយសារគេចាប់អារម្មណ៍ខ្សែភាពយន្តផ្សេងទៀត ដូចជា រឿងខ្មោច ឬ រឿងស្នេហាច្រើនជាង ។ ទោះបីយ៉ាងនេះក៏ដោយ ប្រសិនបើយើងដកថយ យើងនឹងបរាជ័យ ។ យើងគួរតែបន្តអប់រំក្មេងជំនាន់ក្រោយថែមទៀត ។ ដូចបង យុ «ឆាំង យុ» បានលើកឡើងថា ប្រសិនបើយើងភ្លេចប្រវត្តិសាស្ត្ររបស់យើង នោះហាក់ដូចជាយើងសម្លាប់អត្តសញ្ញាណជាតិរបស់យើង ។ ដូចជានៅប្រទេសអាល្លឺម៉ង់ ប្រជាជនរបស់គេត្រូវបានជំរុញឲ្យនិយាយអំពីហូឡូខូសន៍ដើម្បីឲ្យដឹងពីការពិតឲ្យកាន់តែទូលំទូលាយ ហើយដើម្បីលើកកម្ពស់ការយល់ដឹងរបស់ក្មេងជំនាន់ក្រោយកុំឲ្យយកគំរូតាម ។ គ្មាននរណាដឹងថាតើក្មេងជំនាន់ក្រោយនឹងមិនប្រព្រឹត្តអំពើបែបនេះទេប្រសិនបើក្មេងជំនាន់ក្រោយនេះក្លាយជាអ្នកដឹកនាំនៅពេលអនាគតដោយសារតែមិនដឹងពីផលវិបាកនិងមូលហេតុដែលនាំឲ្យកើតអំពើនេះ ។

ដូចជាលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលើកឡើងអ៊ីចឹង យើងត្រូវតែយកឈ្នះឧបសគ្គទាំងឡាយ ។ ការនិយាយពីបទពិសោធន៍អតីតកាលមិនត្រឹមតែបម្រើឲ្យប្រវត្តិសាស្ត្រប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យក្មេងជំនាន់ក្រោយមានការអាណិតអាសូរចំពោះឪពុកម្តាយគេ ក្រុមគ្រួសារនិងមនុស្សជំនាន់មុនទាំងមូល ។ ខ្ញុំសុំទោស ខ្ញុំនិយាយច្រើនបន្តិចហើយ ។ ប្រសិនបើអ៊ំពូមីងមានសំណួរឬយោបល់អ្វីសូមសួរមកចុះ ។

**៦) លី សារី ៖**

ខ្ញុំមកពីឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត ។ អ្នកចូលរួមមានសំណួរជាច្រើនអំពីខ្សែភាពយន្តដែលទាំងអស់នេះជារឿងពិត ។ នេះវាគ្រប់គ្រាន់ហើយ ។ ប្រសិនបើខ្សែភាពយន្តនេះកាន់តែឈឺចាប់ជាងនេះ ខ្ញុំប្រហែលជាមិនអាចទ្រាំមើលបានទេ ។ វាប្រហែលជាបង្កឲ្យអ្នកដែលមានជំងឺបេះដូងកាន់តែលំបាកថែមទៀត ។

ខ្ញុំសូមចូលរួមក្នុងការពិភាក្សានេះ ។ តាមដែលខ្ញុំដឹងអង្គការសហប្រជាជាតិបានអនុម័តលើអនុសញ្ញាការពារអំពើប្រល័យពូជសាសន៍តាំងពីឆ្នាំ១៩៤៨ ប៉ុន្តែអង្គការសហប្រជាជាតិមិនជឿឬមិនចាប់អារម្មណ៍នឹងរឿងនេះទេ តើយើងចង់ឲ្យក្មេងជំនាន់ក្រោយជឿយ៉ាងម៉េចទៅ? វាលំបាកជឿណាស់ ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំសង្កេតឃើញថា បន្ទាប់ពីអង្គការសហប្រជាជាតិដឹង ពួកគេចាប់អារម្មណ៍ជាងយើងទៅទៀត ហើយកំពុងធ្វើការយ៉ាងសកម្ម ។

និយាយដល់និយមន័យអំពើប្រល័យពូជសាសន៍ យើង

*បានរៀនសូត្រអំពីពាក្យនេះពីសហព្រះរាជអាជ្ញានិងអ្នកជំនាញអក្សរសាស្ត្រខ្មែរកាលពីពេលព្រឹកមិញ ។ តាមដែលខ្ញុំយល់ ពាក្យនេះមកពីបន្សំរវាង «ប្រល័យពូជសាសន៍» មានន័យថា លុបបំបាត់ពូជដោយគ្មានគិតពិចារណា ។ ចុងក្រោយនេះ សូមឲ្យបង (ប៉ូវ៉ា) បន្តខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យប្រជាជនជឿថាមានអំពើប្រល័យពូជសាសន៍ ។ ខ្ញុំសូមស្ងើចសរសើរការខិតខំប្រឹងប្រែងរបស់បងយ៉ាងខ្លាំង ។*

**ប៉ូវ៉ា ៖**



*ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់វត្តមាននិងយោបល់របស់អ៊ំពូមីងទាំងអស់គ្នា ។ ខ្ញុំមិនដែលគិតថាយើងខុសគ្នានោះទេ ហើយមិនដែលចាត់ទុកថាបងប្អូនមូស្លីមខុសពីបងប្អូនខ្មែរឬជនជាតិដទៃឡើយ ។ ខ្ញុំសប្បាយរីករាយណាស់ដោយនេះជាលើកទី១ ហើយដែលខ្ញុំឈរនៅចំមុខអ៊ំពូមីងទាំងអស់គ្នាដែលជាអ្នកកាន់សាសនាអ៊ិស្លាមជាច្រើនរយនាក់ ។ អតីតកាលធ្វើឲ្យយើងឈឺចាប់ ហើយម្នាក់ៗមានមុខរបរចិញ្ចឹមជីវិត ប៉ុន្តែសូមកុំអស់សង្ឃឹម យើងត្រូវតែបន្តការខិតខំប្រឹងប្រែងតទៅទៀត ។*

*បន្ទាប់ពីបញ្ចប់ការពិភាក្សាទៅលើខ្សែភាពយន្តរួចមក កញ្ញា ហ្វារីណា បានជម្រាបជូនដោយសង្ខេបអំពីគម្រោងប្រវត្តិ-សាស្ត្រតាមរយៈការសួរនាំក្នុងសហគមន៍ចាម ដោយជំរុញឲ្យអ្នកចូលរួមចែករំលែកបទពិសោធន៍របស់ខ្លួន ។ ហ្វារីណា ក៏បានអនុញ្ញាតឲ្យមានការសួរសំណួរអំពីគម្រោងខ្សែភាពយន្តនិងសុំឲ្យមានការសន្ទនាអំពីបទពិសោធន៍នៅក្នុងការប្រជុំ ព្រមទាំងបន្តការសហការចងក្រងសាច់រឿងក្រោមរបបខ្មែរក្រហម ។ អ្នកចូលរួមទាំងអស់គ្នាបានបន្លឺសំឡេងនិងកាយវិការយល់ព្រមនឹងការលើកឡើងរបស់ ហ្វារីណា ។ ជនជាតិចាមពីរនាក់បានសួរសំណួរទាក់ទងនឹងតួនាទីរបស់អង្គការសហប្រជាជាតិដែលបរាជ័យក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៨-៧៩ ។ លោកនាយកមជ្ឈមណ្ឌលឯកសារបានឆ្លើយតបទៅវិញ ប៉ុន្តែជំរុញឲ្យពួកគាត់សួរអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន ដែលនឹងមកធ្វើទស្សនកិច្ចនៅកម្ពុជានៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ដោយផ្ទាល់ ។*

### ៥) ប្រសាសន៍របស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ

*លោក ឆាំង យុ បានសង្ខេបសុន្ទរកថារបស់លោកប្រកបដោយអត្ថន័យស្តីពីឫសគល់ដែលបណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍និងវិធីទប់ស្កាត់អំពើនេះ ។ លោកបានបញ្ជាក់ថាការរំលោភបំពានទាំងឡាយដូចជាការមិនគោរពភាពខុសគ្នានិងមិនចេះអត់ឱនឲ្យគ្នាអាចប៉ះពាល់ដល់ប្រជាធិបតេយ្យ ។ លោកបាននិយាយថា «ទោះបីជាយើងមានជំនឿដូចគ្នា ប៉ុន្តែយើងមិនដូចគ្នាបេះបិទទេ ទោះបីយ៉ាងណា ក៏យើងមិនខុសគ្នាដែរ ។ យើងទាំងអស់គ្នាចូលរួមចំណែកកសាងប្រជាធិបតេយ្យនៅក្នុងពិភពលោក» ។ លោកបានសង្កត់ធ្ងន់ថា «នេះជាប្រវត្តិសាស្ត្ររបស់យើង ។ សូមបន្តការសហការ ដើម្បីសម្រេចឲ្យបានគោលដៅ» ។*

### ៦) ការវាយតម្លៃកម្មវិធីប្រជុំនិងបូកសរុបលទ្ធផល

*មុនពេលចាកចេញពីបន្ទប់ប្រជុំ អ្នកចូលរួមបានបំពេញតារាងវាយតម្លៃកម្មវិធីប្រជុំ ។ ជាលទ្ធផល៩៧ភាគរយនៃអ្នកចូលរួមបានសរសេរថា ពេញចិត្តនឹងការប្រជុំយ៉ាងខ្លាំង ហើយ៣ភាគរយទៀតសម្តែងការពេញចិត្តនឹងការប្រជុំ ការរៀបចំនិងកិច្ចស្វាគមន៍រាក់ទាក់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកចូលរួមជាច្រើនបានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសាររៀបចំកម្មវិធីបែបនេះធ្វើយ៉ាងណាឲ្យបានមួយឆ្នាំម្តងដើម្បីរំឭកឡើងវិញនិងបង្កើនការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍ ។ តំណាងជនជាតិចាមមួយចំនួនបានប្រគល់រូបថតវិហារនិងស្ថិតិភូមិដល់ក្រុមការងារសម្រាប់ចុះផ្សាយក្នុងប្រព័ន្ធគេហទំព័រចាមដែល*

រៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

មជ្ឈមណ្ឌលឯកសារកម្ពុជាវាយតម្លៃកម្មវិធីប្រជុំផ្អែកលើតារាងវាយតម្លៃនេះ ការអង្កេត និងការពិភាក្សានៅក្នុងការប្រជុំដើម្បីកំណត់ថាតើការប្រជុំនេះត្រូវតាមគោលដៅដែលចង់បានឬអត់ ។

ដោយផ្អែកលើភ័ស្តុតាងទាំងនេះ ការប្រជុំបានពង្រឹងការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍តាមផ្លូវច្បាប់និងសង្គមរបស់អ្នកចូលរួម ក៏ដូចជាតាមផ្លូវវប្បធម៌និងអក្សរសាស្ត្រ ។ ការប្រជុំនេះបានផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការកត់ត្រានូវសាច់រឿងរបស់អ្នកចូលរួមនិងអ្វីដែលពួកគាត់ពុំនិងរៀនសូត្រនៅក្នុងកម្មវិធីប្រជុំ ។ នេះជាឱកាសមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាអាចឆ្លើយតបនឹងសំណូមពររបស់អ៊ីម៉ាំខេត្តព្រះសីហនុ ហើយចូលរួមជាវិភាគទាននូវទឹកប្រាក់១៥០ដុល្លារ ដើម្បីជួសជុលវិហារអាល់មូខលីហ្វាស់នៅភូមិអូរសំអាត សង្កាត់៣ ខេត្តព្រះសីហនុ ហើយការចូលរួមចំណែកនេះអាចជួយថែរក្សាវប្បធម៌និងសាសនារបស់សហគមន៍ចាម ។

បើទោះបីជាការប្រជុំជួបប្រទះឧបសគ្គមួយចំនួន ដោយផ្អែកទៅលើលទ្ធផលខាងលើ មជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកការប្រជុំលើកទី១ជាមួយជនជាតិភាគតិចស្តីពីការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍ជាជោគជ័យមួយ ។ មជ្ឈមណ្ឌលឯកសារនឹងរៀបចំការប្រជុំលើកទី២នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១០ទៀត ។

## សាច់រឿងខ្លីរបស់ ខុន សាវិន

នៅក្នុងកិច្ចប្រជុំជាមួយអ្នកនៅរស់រានដែលជាខ្មែរក្រោមនៅខេត្តពោធិ៍សាត់ ខុន សាវិន ដែលជាគ្រូបង្រៀននៅសាលាបឋមសិក្សាឃុំស្វាយដូនកែវ បានរំឭកពីការឈឺចាប់ដែលគាត់រស់នៅក្នុងឃុំរំលេចកាលពីសម័យខ្មែរក្រហម ។ ទោះបីជារឿងរ៉ាវបានកើតឡើងអស់រយៈពេលជាងបីទសវត្សរ៍មកហើយក៏ដោយក៏ សាវិន ដែលបច្ចុប្បន្នមានអាយុជាង៤០ឆ្នាំបានរៀបរាប់ពីរឿងរ៉ាវរបស់គាត់នៅក្នុងកិច្ចប្រជុំជាមួយ អេនឌ្រូ ខេលី ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។



លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកភូមិដើរចូលសាលប្រជុំ

រឿងរ៉ាវដែលគាត់មិនអាចបំភ្លេចបានគឺការស្លាប់របស់ឪពុកគាត់ដែលមានឈ្មោះថា ស៊ុយ ហុង។ សារិន និងគ្រួសារត្រូវជម្លៀសទៅឃុំរំលេចនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅពាក់កណ្តាលឆ្នាំ១៩៧៥ ។ ប្រហែលជាមួយឆ្នាំបន្ទាប់ពីការជម្លៀស ម្តាយរបស់គាត់ដែលជាខ្មែរក្រោមក៏មានផ្ទៃពោះនិងមានសុខភាពខ្សោយជាលំដាប់ ។ ខ្មែរក្រហមបានចោទប្រកាន់ម្តាយគាត់ថាពូកែឈឺ ដូច្នេះត្រូវតែសម្លាប់ចោល ។ សារិន នៅចាំបានថា នៅពេលដែលគាត់មានអាយុ៦ឆ្នាំ ខ្មែរក្រហមចង់សម្លាប់ខ្មែរក្រោមទាំងអស់ ពីព្រោះខ្មែរក្រោមត្រូវចោទប្រកាន់ថាមាន «ខ្លួនក្បាល វៀតណាម» ។ នៅថ្ងៃមួយ ម្តាយរបស់ សារិន ឈឺធ្ងន់ ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យ ។ ក្រោយមក គាត់ឮថាម្តាយរបស់គាត់ត្រូវគេចាក់ទឹកបញ្ចូលហើយស្លាប់ភ្លាមមួយរំពេច ។ ហុង ដែលត្រូវជាឪពុករបស់ សារិន ត្រូវបានចោទប្រកាន់ថាបានស៊ីសាច់មនុស្ស ដូច្នេះខ្មែរក្រហមក៏សម្លាប់គាត់នៅឆ្នាំ១៩៧៧ ។ គាត់មិនមែនជាកូនកាត់ខ្មែរវៀតណាមឬកម្ពុជាក្រោមទេ ។ ម្តាយរបស់ សារិន ទើបជាខ្មែរក្រោម ។

នៅក្នុងរបបខ្មែរក្រហម ហុង ត្រូវអង្គការបញ្ជាឲ្យជីករណ្តៅនិងកប់សាកសព និងធ្វើការងារផ្សេងៗទៀត ។ ថ្ងៃមួយគាត់ត្រូវបានបញ្ជាឲ្យទៅកប់សាកសពជាមួយនឹងបុរសពីរបីនាក់ ។ ដោយអស់កម្លាំងពេកនៅថ្ងៃនោះ គាត់មិនបានជីករណ្តៅឲ្យជ្រៅល្មមសម្រាប់កប់សាកសពទេ ។ ក្រោយមក ក៏មានឆ្កែព្រៃនិងសត្វផ្សេងៗទៀតស៊ីសាច់សាកសពនោះ ។ ដោយហេតុនេះ កម្មាភិបាលខ្មែរក្រហមក៏ចោទប្រកាន់ ហុង ថាបានស៊ីសាច់សាកសពទាំងនោះ ។ ដូច្នេះ កម្មាភិបាលខ្មែរក្រហមពីរនាក់ដែលមានកាំបិតផ្គាក់នៅជាប់ខ្លួនបានមកបណ្តើរគាត់ទៅសម្លាប់ទាំងថ្ងៃ ។ នៅពេលដែលឃើញខ្មែរក្រហមបណ្តើរឪពុករបស់ខ្លួន សារិន ក៏ដើរតាមពីក្រោយ ។ នៅពេលនោះ ពូរបស់ សារិន ដែលជាអ្នកមូលដ្ឋានម្នាក់ និងមានឈ្មោះ ខន ក៏នៅទីនោះដែរ ។ ឃើញដូច្នោះ ឪពុករបស់ សារិន ក៏បានសុំឲ្យពូរបស់ សារិន ជួយស្រោចស្រង់ជីវិតកូនស្រីរបស់គាត់ផង ។ ពូរបស់ សារិន ក៏សន្យាថានឹងព្យាយាមអស់ពីសមត្ថភាពមិនឲ្យអ្នកណាធ្វើបាប សារិន ឡើយ ។

សារិន នៅចាំបានថានៅ ថ្ងៃមួយគាត់ចង់ទៅជាមួយមនុស្សមួយក្រុមដែលត្រូវបានអង្គការហៅឲ្យទៅដាំពោត ប៉ុន្តែ ខន មិនបានអនុញ្ញាតឲ្យ សារិន ទៅជាមួយគេទេ ពីព្រោះគាត់ដឹងថា ក្រុមនោះនឹងត្រូវគេបញ្ជូនទៅសម្លាប់ ។ នៅក្នុងរបបខ្មែរក្រហម ការបញ្ជាឲ្យមនុស្សម្នាក់ប្តូរពីកន្លែងមួយទៅកន្លែងមួយឬឲ្យទៅដាំដំណាំនៅកន្លែងផ្សេងគឺតែងតែមានន័យថាយកមនុស្សទៅសម្លាប់ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ សារិន ប្រើប្រាស់នាមត្រកូលរបស់ពូគាត់គឺ «ខន» ដោយសារ ខន បានជួយជីវិតរបស់គាត់ និងដើម្បីបង្ហាញពីការគោរពស្រឡាញ់ពូរបស់គាត់ផង ។


អ្នកភូមិនៅក្នុងវេទិកាពិភាក្សាពីអំពើប្រល័យពូជសាសន៍

ដោយសារតែនេះគឺជាការឈឺចាប់ សារិន មិនដែលភ្លេចនូវបទពិសោធន៍នេះទេ ។ វានៅដក់ជាប់ក្នុងចិត្តរបស់គាត់ដូចជារឿងនេះនៅថ្មីៗអ៊ីចឹង ។ គាត់បានរំឭកពីការស្លាប់របស់ឪពុកគាត់យ៉ាងច្បាស់ក្រឡែត ។ គាត់បាននិយាយថា «ទោះបីជានៅពេលនោះ ខ្ញុំគឺជាក្មេងក៏ដោយ ប៉ុន្តែខ្ញុំនៅចាំអ្វីដែលបានកើតឡើងជាច្រើនរួមទាំងការរងទុក្ខវេទនាផង ។ វាហាក់ដូចជានៅថ្មីៗនៅឡើយ» ។ **មេហ្គាន ខាស**

# ការចោទប្រកាន់អំពីការអនុវត្តផ្នែកសុខាភិបាលរបស់ខ្មែរក្រហមថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

***(តចប់)***

*យ៉ាងហោចណាស់ចាប់ពីឆ្នាំ១៩៧៦មក គណៈមជ្ឈិមបក្សដឹងពីស្ថានភាពសុខភាពដ៏អាក្រក់ដែលកើតឡើងដោយសារគោលនយោបាយរបស់ខ្លួនតាមរយៈប្រភពផ្សេងៗ ប៉ុន្តែបក្សមិនបានធ្វើឲ្យមានការផ្លាស់ប្តូរដើម្បីអភិវឌ្ឍផ្នែកសុខាភិបាលដល់ប្រជាជនកម្ពុជាឡើយ ។*

*ភស្តុតាងទីបីដែលបង្ហាញថាគណៈមជ្ឈិមបក្សដឹងពីភាពធ្ងន់ធ្ងរនៃវិបត្តិផ្នែកសុខាភិបាលនៅក្នុងប្រទេសអាចត្រូវបានរកឃើញតាមរយៈការនាំចូលសម្ភារៈវេជ្ជសាស្ត្រពីប្រទេសជិតខាង ។ នៅឆ្នាំ១៩៧៧ គណៈមជ្ឈិមបានដឹងពីបរាជ័យនៃសារធាតុថ្នាំដែលផលិតនៅក្នុងស្រុកដើម្បីការពារប្រជាជននៅក្នុងប្រទេសមិនឲ្យកើតជំងឺគ្រុនចាញ់ និងការព្យាបាលអ្នកជំងឺ ។ ខណៈពេលដែលថ្នាំការពារ និងព្យាបាលជំងឺគ្រុនចាញ់ដែលត្រូវបាននាំចូលបន្ទាប់ពីឆ្នាំ១៩៧៧ ប្រហែលជាអាចព្យាបាលការរាតត្បាតនៃជំងឺគ្រុនចាញ់របស់ប្រជាជនរាប់ពាន់នាក់បានរងគ្រោះដោយសារជំងឺនេះនៅក្នុងប្រទេស ។ ជាងនេះទៅទៀត ការនាំចូលថ្នាំការពារជំងឺគ្រុនចាញ់គ្រាន់តែជាយុទ្ធសាស្ត្រដើម្បីបញ្ឈប់និងទប់ស្កាត់ប្រជាជនមិនឲ្យមានជំងឺដែលមិនអាចព្យាបាលបានប៉ុណ្ណោះ ។ មិនមានការប៉ុនប៉ងកែប្រែរចនាសម្ព័ន្ធផ្នែកវេជ្ជសាស្ត្ររបស់ប្រទេសទេ ដូច្នេះក៏មិនអាចបញ្ឈប់ការស្លាប់និងជំងឺរ៉ាំរ៉ៃដែលពេទ្យក្មេងខ្មែរក្រហមមិនអាចព្យាបាលឲ្យជាបានឡើយ ។*

*ភស្តុតាងដ៏ច្បាស់លាស់ដែលអាចបញ្ជាក់ថា គណៈមជ្ឈិមបក្សដឹង និងបដិសេធមិនឲ្យមានការថែទាំសុខភាព និងការប្រើប្រាស់ថ្នាំដែលផលិតនៅក្នុងស្រុកនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺបទពិសោធរបស់ប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅតាមតំបន់ផ្សេងៗ និងធ្លាប់ជួបបញ្ហាទាក់ទងនឹងការថែទាំសុខភាព ។ ទោះបីជាការចងចាំនេះមិនអាចផ្តល់ជាគំរូល្អបំផុតទាក់ទងនឹងការថែទាំសុខភាពនៅតាមខេត្តក្នុងអំឡុងរបបខ្មែរក្រហមក៏ដោយ ក៏វាអាចបង្ហាញថាបុរសនិងស្ត្រីទាំងអស់សុទ្ធតែរងនូវជំងឺ ដែលមិនអាចព្យាបាលបាន និងភាពភ័យខ្លាចទៅលើការចាក់ថ្នាំ និងថ្នាំដែលផលិតដោយខ្លួនឯង ។ មន្ទីរពេទ្យនៅភ្នំពេញត្រូវបានរុះរើដូចជាមន្ទីរពេទ្យនៅបាត់ដំបងដែរ ។ ក្មេងតូចៗត្រូវបានបង្ខំឲ្យធ្វើជាពេទ្យនៅតាមខេត្ត ហើយទទួលបានការបណ្តុះបណ្តាលក្នុងរយៈពេលដ៏ខ្លី ។ ប្រជាជនកម្ពុជានៅទូទាំងប្រទេសបានហៅថ្នាំដែលផលិតដោយខ្លួនឯងថាជា «ថ្នាំអាចម៍ទន្សាយ» និងទទួលបានការចាក់ថ្នាំនូវប្រភេទថ្នាំតែមួយដូចគ្នា ។*

*នៅពេលដែលអ្នកភៀសខ្លួនកម្ពុជារត់ទៅប្រទេសថៃនៅខែចុងក្រោយនៃរបបខ្មែរក្រហម អ្នកទាំងនោះសុទ្ធតែរំឭកពីរឿងរ៉ាវស្រដៀងគ្នាទាក់ទងនឹងការស្លាប់ និងជំងឺដែលបណ្តាលមកពីការខ្វះខាតថ្នាំ និងបុគ្គលិកពេទ្យដែលគ្មានជំនាញ ។ បន្ទាប់ពីចងក្រងនូវបទសម្ភាសន៍ជាមួយអ្នកភៀសខ្លួនកម្ពុជាទៅព្រំដែនកម្ពុជា-ថៃ នៅឆ្នាំ១៩៧៨ អ្នករាយការណ៍ឲ្យសារព័ត៌មាន ញូវយ៉កថែមស៍ បានសរសេរអំពីរឿងរ៉ាវដែលគាត់ដឹងពីប្រព័ន្ធសុខាភិបាលនៅក្នុងរបបខ្មែរក្រហមថា ៖*

> *ការព្យាបាលគឺធ្វើឡើងដោយពេទ្យខ្មែរក្រហមដែលត្រូវបានគេនិយាយថាមិនដែលទទួលការបណ្តុះបណ្តាលផ្នែកព្យាបាលទេ និងព្យាបាលតែកម្មាភិបាលនិងយោធាជាជាងប្រជាជន ។ ថ្នាំដែលអាចប្រើប្រាស់បានគឺថ្នាំបុរាណដែលធ្វើពីរុក្ខជាតិ ឫសឈើ និងសំបកឈើ ។ ជនភៀសខ្លួនម្នាក់បាននិយាយថា «អ្នកជំងឺស្នាក់នៅក្នុងខ្ទមរង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ» ។*

*ទោះបីជាលេខាភូមិភាគនៅទូទាំងប្រទេសបានអនុម័តឲ្យប្រើប្រាស់ថ្នាំដែលផលិតនៅក្នុងស្រុក និងបញ្ឈប់បុគ្គលិកពេទ្យដែលធ្លាប់ទទួលការបណ្តុះបណ្តាលតាមបែបវិទ្យាសាស្ត្រក៏ដោយ ក៏ទំនងជាអាចនិយាយបានថាបញ្ហាទាំងនោះគឺចេញមកពីគណៈមជ្ឈិមបក្សដែរ ។ គណៈកម្មាធិការដែលរួមមាន នួន ជា, ខៀវ*

សំផន, អៀង សារី និង អៀង ធីរិទ្ធ អាចត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនរាប់សែននាក់ដែលបណ្តាលមកពីគោលនយោបាយព្យាបាលរបស់អ្នកទាំងនោះ ។

## ៤) ការពិសោធថ្នាំ

### ក) ការពិសោធទៅលើប្រសិទ្ធភាពនៃថ្នាំ

បទបញ្ជារបស់ ប៉ុល ពត ឲ្យអនុវត្តការព្យាបាលរបៀប «ម្ចាស់ការលើខ្លួនឯង» មិនត្រឹមតែបង្កឲ្យមានការបោសសម្អាតបុគ្គលិកពេទ្យដែលមានជំនាញនិងការថែទាំសុខភាពប្រជាជនកម្ពុជាតាមបែបវិទ្យាសាស្ត្រប៉ុណ្ណោះទេ តែថែមទាំងបណ្តាលឲ្យមានការពិសោធទៅលើមនុស្សដើម្បីធ្វើតេស្តថ្នាំដែលផលិតដោយខ្មែរក្រហមនិងការធ្វើទារុណកម្មនៅមន្ទីរឃុំឃាំងផងដែរ ។ ជាមួយនឹងការធ្វើពិសោធទៅលើប្រសិទ្ធភាពនៃថ្នាំ វាទំនងជាថាការព្យាបាលនៅក្នុងរបបខ្មែរក្រហមបានឆ្លងកាត់ការពិសោធ ។ ពេទ្យខ្មែរក្រហមបានឲ្យថ្នាំអាចម៍ទន្សាយទៅឲ្យអ្នកជំងឺដោយមិនគិតពីរោគសញ្ញារបស់អ្នកទាំងនោះឡើយ ពេទ្យបានចាក់ថ្នាំដែលធ្វើពីទឹកដូងទៅឲ្យអ្នកជំងឺសម្រាប់ពិសោធទៅលើប្រសិទ្ធភាពរបស់ថ្នាំនោះនិងមិនបានវាស់វែងទៅលើចំនួននៃការផឹក ឬចំនួននៃសារធាតុធម្មជាតិដាក់លាក់នៅក្នុងថ្នាំដែលផលិតនៅក្នុងស្រុកនោះទេ ។

នៅក្នុងការថ្លែងសុន្ទរកថាពិធីរំឭកខួបលើកទីបីរបស់ខ្មែរក្រហមនៃទិវាជ័យជម្នះនៅថ្ងៃទី១៧ មេសា ១៩៧៥ ខៀវ សំផន បានទទួលស្គាល់ជាផ្លូវការនូវដំណើរការពិសោធទៅលើការព្យាបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាជាងភាពបរាជ័យនៃការព្យាបាល ៖

> *នៅក្នុងផ្នែកសុខាភិបាល និងកិច្ចការសង្គម អង្គភាពជាច្រើនបានបំពេញ ឬធ្វើលើសពីគម្រោងនៃការផលិតថ្នាំសម្រាប់ធ្វើឲ្យស្ថានភាពរស់នៅរបស់ប្រជាជនប្រសើរជាងមុន ។ សហករណ៍នីមួយៗមានមន្ទីរពេទ្យ និងកន្លែងផលិតថ្នាំ ។ យើងបានជំរុញឲ្យគ្រប់កម្លាំងទាំងអស់ចូលរួមយ៉ាងសកម្ម*



មន្ទីរពេទ្យនៅក្នុងសម័យខ្មែរក្រហម

*នៅក្នុងការផលិតថ្នាំ ។ ទោះបីជាយើងស្ថិតនៅក្នុងដំណាក់កាលផលិតដោយដៃក៏ដោយ ថ្នាំរបស់យើងបានបំពេញតម្រូវការរបស់ប្រជាជន ហើយប្រសិទ្ធភាពរបស់ថ្នាំមានការកើនឡើងជាលំដាប់ ។ មានតែធ្វើដូច្នេះទេទើបយើងអាចអនុវត្តតាមមាគ៌ាឯករាជ្យ អធិបតេយ្យភាព និងម្ចាស់ការក្នុងការផលិតថ្នាំនិងវិស័យផ្សេងទៀត ។*

ការពិសោធផ្នែកសុខាភិបាលរបស់ខ្មែរក្រហមគឺជាលទ្ធផលនៃការសង្កត់ធ្ងន់របស់បក្សទៅលើភាពម្ចាស់ការលើខ្លួនឯង និងការដាក់កំហិតទៅលើការប្រើប្រាស់ការថែទាំសុខភាពតាមបែបបស្ចិមប្រទេស ។ ដោយមិនមានលទ្ធភាពក្នុងការដើរតាមការផលិតថ្នាំ ដូច្នេះត្រូវតែមានការពិសោធថ្នាំទៅលើមនុស្ស ។

បន្ថែមទៅលើការពិសោធទូទៅទៅលើអ្នកជំងឺ ពេទ្យខ្មែរក្រហមក៏បានដឹកនាំការពិសោធទៅលើមនុស្សមានជីវិតដើម្បីសិក្សាពីសារពាង្គកាយ សរីរាង្គមនុស្ស និងថ្នាំ ។ ឧទាហរណ៍ នៅមន្ទីរពេទ្យកំពង់ចាម ក្រុមអ្នក «វះកាត់» ត្រូវបានខ្មែរក្រហមណែនាំឲ្យទៅដឹកនាំការសិក្សាពីវិធីដែលកោសិកាភ្ជាប់គ្នាដោយវះពោះមនុស្ស ។ ពោះវៀនតូចរបស់មនុស្សត្រូវបានកាត់ផ្ដាច់ហើយតភ្ជាប់ចូលគ្នាវិញ ដែលធ្វើឲ្យពេទ្យអាចសិក្សាពីដំណើរការរបស់ដិ្ឋតនោះបាន ។ នៅក្នុងរយៈពេលបីថ្ងៃ អ្នកជំងឺបានស្លាប់ ដោយសាររបួសនៅក្នុងពោះ ។ ក្រុមពេទ្យខ្មែរក្រហមទីពីរនៅមន្ទីរពេទ្យដដែលក៏បានវះដើមទ្រូងរបស់អ្នកជំងឺដើម្បីពិនិត្យទៅលើបេះដូងរបស់អ្នកជំងឺនោះដែលបណ្ដាលឲ្យអ្នកជំងឺនោះស្លាប់ភ្លាមមួយរំពេច ។ នៅក្នុងមន្ទីរពេទ្យយោធាជិតខេត្តបាត់ដំបង បុគ្គលិកពេទ្យខ្មែរក្រហមបានដឹកនាំការពិសោធការវះប្រមាត់របស់មនុស្សដែលនៅរស់មកប្រៀបធៀបនឹងប្រមាត់របស់អ្នកស្លាប់ ។ ការធ្វើតេស្តនេះមិនបានផ្ដល់ប្រយោជន៍អ្វីដល់ការព្យាបាលឡើយ ។



### ១) ការពិសោធគឺជាការធ្វើទារុណកម្មមួយនៅក្នុងមន្ទីរឃុំឃាំង ៖ ការសិក្សាទៅលើករណីទួលស្លែង

ពេទ្យខ្មែរក្រហមបានធ្វើការពិសោធជាបន្តបន្ទាប់ទៅលើអ្នកទោសដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខដែលត្រូវបានបង្កើតឡើងនៅក្នុងប្រទេស ។ ក៏ដូចជាពេទ្យរបបណាហ្ស៊ីដែលធ្វើការនៅជំរំសម្លាប់ដែរ ពេទ្យខ្មែរក្រហមបានធ្វើពិសោធទៅលើអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងក្នុងសណ្ឋានជាការធ្វើទារុណកម្ម និងដើម្បីធ្វើការពិសោធអំពីសារពាង្គកាយរបស់មនុស្ស ។ គ្មានកន្លែងធ្វើពិសោធទៅលើអ្នកទោសណាមានលក្ខណៈជាប្រព័ន្ធ និងធំជាងនៅទួលស្លែង (ស-២១) ទេ ដែលជាទីបញ្ជាការប៉ូលិសពិសេសជាកន្លែងធ្វើទារុណកម្មនិងសម្លាប់មនុស្សដែលត្រូវបានចោទប្រកាន់ថាក្បត់នឹងរបបបដិវត្តន៍ខ្មែរក្រហម ។

ស្ថានភាពទូទៅនៃការព្យាបាលនៅទួលស្លែងបានបង្កើតជាឱកាសឲ្យមានការធ្វើពិសោធទៅលើមនុស្ស ។ អ្នកធ្វើការនៅមន្ទីរឃុំឃាំងត្រូវបានបែងចែកជាបីក្រុម ៖ ក្រុមសួរចម្លើយ ក្រុមឯកសារ និងក្រុមការពារសន្តិសុខ ។ ក្រុមការពារដែលជាក្រុមធំជាងគេនៅ ស-២១ និងដឹកនាំដោយ ឃឹម វ៉ាក ហៅ ហ៊ី គឺជាកងរងដែលមានពេទ្យ១៥នាក់សម្រាប់ពិនិត្យទៅលើអ្នកស្លាប់ និងផ្ដល់សេវាសុខភាពទូទៅដល់អ្នកទោសដែលឈឺ និងមានរបួស ។ យោងទៅតាមចម្លើយសារភាពរបស់ពេទ្យម្នាក់ក្នុងចំណោមពេទ្យ

ទាំងនេះនៅ ស-២១ មានពេទ្យតែបីនាក់ប៉ុណ្ណោះដែលទទួលខុសត្រូវមើលអ្នកទោសរាប់ពាន់នាក់ ។ បុគ្គលិកពេទ្យជាច្រើនគឺជាក្មេងដែលមិនសូវដឹងពីថ្នាំ ។ ពេទ្យទាំងនេះគ្រាន់តែសួរអ្នកទោសដែលឈឺនិងមានជំងឺនូវសំណួរដដែល បន្ទាប់មកបើកថ្នាំដែលផលិតដោយខ្លួនឯងដូចជាថ្នាំអាចម៍ទន្សាយជាដើម ។ ជាលទ្ធផល យោងទៅតាមកំណត់ត្រារបស់អ្នកទោស មានអ្នកទោសរាប់ពាន់នាក់ស្លាប់ដោយជំងឺគ្រុនចាញ់ រាក «ឈឺស្គមស្គាំង» «ហត់នឿយ» និងមិនមានការព្យាបាលត្រឹមត្រូវ ។

ដោយសារតែទួលស្លែងគឺជាមន្ទីរឃុំឃាំងសម្ងាត់ ហើយមានតែគណៈមជ្ឈិមបក្សនិងអ្នកដែលធ្វើការនៅទីនោះប៉ុណ្ណោះទើបដឹងពីវត្តមានរបស់ ស-២១ ហេតុដូច្នេះទើបធ្វើឲ្យដឹងថាមានការពិសោធទៅលើអ្នកជំងឺតែផ្នែកណាមួយនៃរាងកាយអ្នកទោសខ្លះ ។ សៀវភៅកំណត់ហេតុស្តីពីការសិក្សាទៅលើការព្យាបាលមួយចំនួន ដែលត្រូវបានគេរកឃើញនៅស-២១ បន្ទាប់ពីមានការចូលមកដល់របស់វៀតណាមបានបង្ហាញថា បុគ្គលិកនៅស-២១ បានអនុវត្តការពិសោធដូចជាបង្ហូរឈាមអ្នកទោសរហូតស្លាប់ និងថាតើចំណាយពេលប៉ុន្មានដើម្បីធ្វើឲ្យសាកសពដែលស្លាប់ចាប់អណ្តែតនៅលើផ្ទៃទឹក ។ សៀវភៅកំណត់ហេតុបែបនេះដែលរកឃើញនៅជិតទួលស្លែងរួមមានប្រាំទំព័រដែលសរសេរអំពី «ការពិសោធមនុស្ស» និងនិយាយពីលទ្ធផលនៃការពិសោធដប់មួយដងទៅលើអ្នកទោស១៧នាក់ដែលនៅរស់និងស្លាប់ ៖

> អ្នកទាំងនោះបានចាប់ផ្តើមដោយ ១) ក្មេងស្រីអាយុ១៧ឆ្នាំដែលត្រូវបានអារ-ក និងវះពោះ ហើយទម្លាក់ទៅក្នុងទឹកពីម៉ោង៧:៥៥នាទីយប់ រហូតដល់ម៉ោង៩:២០នាទីព្រឹក ទើបសាកសពចាប់ផ្តើមអណ្តែតឡើងមកលើបន្តិចម្តងៗនៅម៉ោង១១ព្រឹក ។ ២) ក្មេងស្រីអាយុ ១៧ឆ្នាំត្រូវបានវាយរហូតស្លាប់ បន្ទាប់មកយកទៅទម្លាក់ក្នុងទឹកដូចពីមុននិងទុករយៈពេលដដែល ប៉ុន្តែសាកសពនោះអណ្តែតនៅម៉ោង១:១៧រសៀល ។ សេចក្តីលម្អិតស្រដៀងគ្នានេះក៏ត្រូវបានកត់ត្រាទុកដែរថា «ស្ត្រីដែលមានមាឌធំត្រូវបានចាក់កនិងវះពោះព្រមទាំងដកគ្រឿងក្នុងចេញ និងក្មេងប្រុសម្នាក់ដែលត្រូវបានវាយរហូតដល់ស្លាប់ និងក្មេងស្រីបួននាក់ដែលត្រូវបានចាក់ក និងក្មេងស្រីម្នាក់ដែលនៅរស់បន្ទាប់ពីត្រូវបានចងដៃ និងទម្លាក់នៅក្នុងទឹក» ។

ភស្តុតាងដ៏ច្បាស់លាស់ដែលថាបុគ្គលិកពេទ្យនៅទួលស្លែងបានដឹកនាំការពិសោធទៅលើមនុស្សគឺបានមកពីសក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ ហៅ (ឌុច) ប្រធានមន្ទីរ ស-២១ ពីឆ្នាំ១៩៧៦-១៩៧៩ ។ នៅក្នុងសក្ខីកម្មថ្ងៃទី១៦ មិថុនា ឆ្នាំ២០០៩ ឌុច បានសារភាពថាបានដឹងពីការពិសោធបួនយ៉ាងដែលធ្វើឡើងនៅទួលស្លែង ៖

> ទីមួយ អ្នកទោសដែលមានជីវិតត្រូវបានយកទៅវះកាត់ដើម្បីបង្រៀនហ្វឹកហាត់ ។ ទីពីរ ក៏មានការបូមឈាមដែរ ហើយនៅតែមានការអនុវត្តវិធីនេះដដែលរហូតដល់ពេលដែលខ្ញុំចូលមកធ្វើការនៅស-២១នេះ ហើយមានឯកសារ ស-២១ខ្លះដែលខ្ញុំបានណែនាំឲ្យគេធ្វើ ប៉ុន្តែវាក៏ជាបញ្ហាថ្នាក់លើដែលបញ្ជាឲ្យបូមឈាមដើម្បីព្យាបាលអ្នកដែលត្រូវការឈាម ។ ដូច្នេះ មានជនរងគ្រោះប្រមាណ១០០នាក់ បានស្លាប់ដោយការបូមឈាមនេះ ។ វាគឺជាករណីទីពីរ ។ ចំពោះករណីទីបី ថ្នាំដែលត្រូវបានរៀបចំតែងតែត្រូវបានយកទៅពិសោធទៅលើអ្នកទោស ពីព្រោះប្រសិនបើយកទៅពិសោធទៅលើខ្លួនឯង វាមិនមែនជាវិធីសាស្ត្រទេ ប៉ុន្តែគេពិសោធថ្នាំថ្មីទៅលើអ្នកទោស ។ ករណីទីបួន ពូ នួន ជា បានឲ្យថ្នាំខ្លះមកខ្ញុំដើម្បីពិសោធលើអ្នកទោស ទោះបីជាខ្ញុំដឹងច្បាស់ថាម្សៅនោះត្រូវបានប្រើប្រាស់ដើម្បីជំនួសឲ្យថ្នាំប៉ារ៉ាសេតាម៉ុល (ថ្នាំបំបាត់ការឈឺចាប់តិចតួច) ប៉ុន្តែវានៅតែត្រូវយកទៅពិសោធលើអ្នកទោស ទោះបីជាវាមិនមានជាតិពុលក៏ដោយ ។ ប៉ុន្តែអ្នកទោសសុទ្ធតែដឹងថា ថ្នាំនោះគឺជាការពិសោធ ។ ដូច្នេះ នេះគឺជាការពិសោធទៅលើការព្យាបាលទាំងបួនដែលធ្វើឡើងនៅស-២១ ។

ការពិសោធទីមួយដែលជាការវះកាត់ទៅលើអ្នកទោសដែលនៅរស់និងស្លាប់គឺត្រូវបានដឹកនាំដើម្បីសិក្សាទៅលើសរីរាង្គរបស់មនុស្ស និងដើម្បីបង្រៀនពេទ្យខ្មែរក្រហមអំពីបច្ចេកទេសវះកាត់ ។ ការពិសោធទៅលើមនុស្សដែលមានជីវិតត្រូវបានធ្វើឡើងដោយយោងទៅតាមហេតុផលនេះ ។ ឌុច បានផ្តល់សក្ខីកម្មថា

ការសិក្សាទៅលើសរីរាង្គរបស់មនុស្សត្រូវបានធ្វើឡើងទៅលើអ្នកទោសដែលមានជីវិត ឬអ្នកទោសដែលត្រូវបានសម្លាប់សម្រាប់យកទៅពិសោធ ពីព្រោះអ្នកដែលនៅរស់ងាយស្រួលក្នុងការពិសោធជាជាងអ្នកដែលស្លាប់ដោយការធ្វើទារុណកម្មឬមានជំងឺ ។ ការបូមឈាមដែលជាការពិសោធប្រភេទទីពីរនៅទួលស្លែងគឺជាការផ្តួចផ្តើមគំនិតរបស់ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលការផ្គត់ផ្គង់ឈាមសម្រាប់កម្មាភិបាលខ្មែរក្រហមដែលរងរបួសនៅមន្ទីរពេទ្យដូចជា ពេទ្យ៩៨ និង ពេទ្យមិត្តភាពខ្មែរ-សូវៀតនៅភ្នំពេញនឹងមានការបូមឈាមពីអ្នកទោសដែលត្រូវបានឃុំឃាំងដើម្បីយកទៅបញ្ចូលឲ្យយុទ្ធជន ។ អ្នកទោសនឹងត្រូវបាននាំទៅបន្ទប់ព្យាបាលនៅទួលស្លែង ហើយដាក់ឲ្យដេកនៅលើគ្រែដោយរុំភ្នែកនិងដាក់ខ្នោះ ។ ឈាមត្រូវបានគេបូមចេញតាមម្ជុលនិងបញ្ចូលទៅក្នុងថ្លោកមួយ ។

ដំបូងអ្នកទោសមិនត្រូវបានពិនិត្យរកជំងឺមុនពេលបូមឈាមចេញទេ ដូច្នេះយោធាខ្មែរក្រហមដែលទទួលបានឈាមតែងតែមានជំងឺស្បែកជានិច្ច ។ ឌុច បានអះអាងថា នៅទីបញ្ចប់គាត់បានអនុវត្តដំណើរការពិនិត្យជំងឺដែលតឹងរ៉ឹងជាមុន ដូច្នេះមានតែអ្នកទោស «ដែលមានសុខភាពល្អ» ទេ ទើបត្រូវបានគេបូមឈាម ។ ប៉ុន្តែ ឌុច ក៏បានសារភាពថា ដំណើរការបូមឈាមនៅ ស-២១ មិនមានភាពទៀងទាត់ទេដែលបណ្តាលឲ្យអ្នកទោសប្រមាណជា១០០នាក់ស្លាប់ដោយសារតែ «ឈាមត្រូវបានបូមចេញពីអ្នកទោសនោះអស់តែម្តង» ។ ប្រាក់ ខន អតីតអ្នកសួរចម្លើយនៅស-២១ បានផ្តល់ភ័ស្តុតាងបន្ថែមថាដំណើរការនៃការបូមឈាមមិនត្រូវបានគេត្រួតពិនិត្យត្រឹមត្រូវទេ ។ ប្រាក់ ខន បានអះអាងថា អ្នកទោសបួនដប់ត្រូវបានគេយកទៅបូមឈាមនៅពេលជាមួយគ្នានិងបូមទាល់តែ «អស់ឈាមរហូតស្លាប់» តែម្តង ។ នៅពេលដែលសួរថាតើការបូមឈាមគឺដើម្បីសម្លាប់អ្នកទោសឬ ប្រាក់ ខន បានឆ្លើយថា «តាមអ្វីដែលខ្ញុំបានឃើញផ្ទាល់ភ្នែក នៅពេលដែលឈាមត្រូវបានបូមចេញ គ្មានអ្នកទោសណាម្នាក់នៅរស់ទេពីព្រោះអ្នកទោសទាំងនោះបានស្លាប់នៅពេលកំពុងបូមឈាមទៅហើយ» ។

ការពិសោធវេជ្ជសាស្ត្រក៏មានកើតឡើងនៅទួលស្លែងដែរ គឺតាមរយៈការធ្វើតេស្តថ្នាំដែលផលិតដោយខ្លួនឯងទៅលើអ្នកទោសដែលមានរបួសជាជាងឲ្យថ្នាំដែលផលិតនៅបស្ចិមប្រទេសដល់អ្នកជំងឺ ។ ស្ថានភាពព្យាបាលដ៏គ្រោះថ្នាក់ដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមក៏មានកើតឡើងនៅទួលស្លែងដែរ ។ សេក ដន ពេទ្យក្មេងម្នាក់នៅទួលស្លែងចាប់ពីឆ្នាំ១៩៧៨ បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ចែកថ្នាំ និងលាងរបួសឲ្យអ្នកទោសនៅក្នុងគុកនោះ ។ នៅពេលដែល សេក ដន ធ្វើការនៅទួលស្លែង គាត់គឺជាមនុស្សដែលមិនចេះអក្សរ ហើយក៏មិនធ្លាប់ទទួលបានការបណ្តុះបណ្តាលអំពីការព្យាបាលមុនពេលត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅស-២១ ដូចក្មេងដទៃដែរ (ឌុច បានអះអាងថា ក្មេងប្រុសៗមកពីខេត្តត្រូវបានគេជ្រើសរើសឲ្យធ្វើជាពេទ្យនៅស-២១ ដោយសារតែការអប់រំ និង ការចងចាំដ៏តិចតួចរបស់អ្នកទាំងនោះ) ។ សេក ដន បានអះអាងថា អ្នកទោសភាគច្រើនដែលគាត់ ព្យាបាលមានជំងឺរាក ក្តៅខ្លួន ឬឈឺក្បាល និងមានរបួសនៅខ្នង ម្រាមដៃនិងម្រាមជើង បណ្តាលមកពីការធ្វើទារុណកម្ម ។ ប៉ុន្តែ សេក ដន «ដឹងច្បាស់ថាគ្មានថ្នាំអ្វីទេគឺមានតែថ្នាំអាចម៍ទន្សាយសម្រាប់យកទៅព្យាបាលអ្នកទោសទាំងនោះ ហើយមានតែទឹកអំបិលប៉ុណ្ណោះសម្រាប់លាងរបួស ។ ជាងនេះទៅទៀត អ្នកទោសត្រូវបានឲ្យថ្នាំគ្រប់គ្រាន់ដើម្បីទុកជីវិតសម្រាប់សួរចម្លើយ ហើយរបួសរបស់អ្នកទោសត្រូវបានគេព្យាបាលរយៈពេលខ្លីបន្ទាប់មកយកទៅធ្វើទារុណកម្មម្តងទៀត ។ បន្ទាប់ពីចៅក្រម ស៊ីលវៀ ខាតព្រ៉ាយត៍ និងចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បានស្នើឲ្យ សេក ដន រៀបរាប់ពីថ្នាំដែលគាត់ឲ្យអ្នកជំងឺ សេក ដន បាននិយាយថា ៖

> «ថ្នាំនោះត្រូវបានផលិតនៅក្នុងស្រុក ។ ថ្នាំនោះគឺជាថ្នាំអាចម៍ទន្សាយ ។ ថ្នាំនោះមានពណ៌ខ្មៅ ហើយត្រូវបានផលិតក្រោយឆ្នាំ១៩៧៥ ។ ថ្នាំនេះអាចព្យាបាលខ្លះជាសះស្បើយ ពីព្រោះថ្នាំខ្លះមានប្រសិទ្ធភាព ហើយថ្នាំខ្លះមិនមានប្រសិទ្ធភាពទេ ។ ខ្ញុំធ្លាប់បានផឹកថ្នាំនោះអស់ជាច្រើនដែរ ប៉ុន្តែវាមិនមានប្រសិទ្ធភាពអ្វីសោះ ។ ខ្ញុំផឹកថ្នាំនោះពីព្រោះខ្ញុំឃ្លាន» ។

ពេទ្យកុមារផ្សេងទៀតនៅទួលស្លែងបានអះអាងថា ខ្លួនមិនចេះអក្សរ និងបានទទួលការបណ្តុះបណ្តាលកម្រិតមូលដ្ឋាន

ព្រមទាំងអាចត្រឹមតែផ្តល់ថ្នាំដែលផលិតដោយខ្លួនឯងដល់អ្នកទោសដែលមានជំងឺ និងរបួសប៉ុណ្ណោះ ។ ណាំ ម៉ុន ពេទ្យនៅទួលស្លែង ដែលបានក្លាយទៅជាពេទ្យនៅពេលដែលគាត់មានអាយុ១៥ឆ្នាំ បាននិយាយថា មានការចែកថ្នាំបរទេសដូចជា ប៉ារ៉ាសេតាម៉ុល ដល់អ្នកទោសនៅដំណាក់កាលដំបូងនៃរបបខ្មែរក្រហម ។ ប៉ុន្តែនៅពេលដែលថ្នាំនេះអស់ពីស្តុក ក៏ចាប់ផ្តើមមានការប្រើ «ថ្នាំបុរាណ» សម្រាប់ព្យាបាលអ្នកជំងឺ ។ ណាំ ម៉ុន បានផ្តល់សក្ខីកម្មថាគាត់មិនដឹងថាមានអ្វីខ្លះទេនៅក្នុងថ្នាំនោះ ។ ខ្មែរក្រហមបានឲ្យថ្នាំទៅគាត់ ហើយប្រាប់គាត់ថាយកទៅឲ្យអ្នកទោស ។ គាត់បានបែងចែកថ្នាំនោះតាមរយៈការមើលផ្លាកនៅលើដបថ្នាំពីព្រោះគាត់មិនចេះអក្សរ ។

បន្ថែមពីលើការធ្វើពិសោធថ្នាំនៅទួលស្លែង ឌុច ហាក់ដូចជាបង្ហាញថាខ្លួនជាអ្នកអនុវត្តនូវការពិសោធថ្នាំទៅលើអ្នកជំងឺក្រោមបញ្ជារបស់ នួន ជា ។ នៅពេលដែលមានការសួរនៅក្នុងអង្គជំនុំជម្រះថាតើ ឌុច បានចូលរួមក្នុងការដឹកនាំពិសោធថ្នាំនៅ ស-២១ ដោយរបៀបណា ឌុច បានឆ្លើយថា ៖

> លោកប្រធាន ខ្ញុំជាអ្នកធ្វើដោយខ្លួនឯង ។ គ្មានអ្នកណាដឹងពីរឿងនេះទេ គឺមានតែមនុស្សពីរនាក់ប៉ុណ្ណោះដែលដឹង ។ នោះគឺខ្ញុំ និងពូ នួន ជា ។ ខ្ញុំអនុវត្តវាដោយផ្ទាល់ ។ ខ្ញុំបានឲ្យថ្នាំទៅមនុស្សបីនាក់ពីរគ្រាប់ក្នុងមួយថ្ងៃ គឺរយៈពេលបីថ្ងៃ ។ អ្នកដទៃបានឃើញខ្ញុំយកអ្នកទាំងបីនាក់នេះទៅស្នាក់នៅផ្នែកគូររូប និងថតរូប ។ នៅពេលថ្ងៃ ខ្ញុំបានយកថ្នាំទៅឲ្យអ្នកទាំងនេះដោយផ្ទាល់ ។ ដូច្នេះខ្ញុំធ្វើដោយខ្លួនឯង ហើយអ្នកដទៃដឹងថាវាគឺជាការពិសោធថ្នាំ ហើយជនរងគ្រោះផ្ទាល់ក៏ដឹងដែរ ។ នេះគឺជាសកម្មភាពឧក្រិដ្ឋមួយប្រភេទទៀតដែលខ្ញុំបានប្រព្រឹត្ត ។

បន្ទាប់មក ឌុច បានអះអាងថា គាត់បានផ្លាស់ប្តូរថ្នាំដែលមានជាតិពុលដោយជំនួសថ្នាំប៉ារ៉ាសេតាម៉ុលវិញ ហើយគ្មានការអនុញ្ញាតពី នួន ជា ទេ ៖ «ដោយថ្នាំនោះស្ថិតនៅក្នុងសំបក ខ្ញុំបានផ្លាស់ប្តូរសារធាតុនៅក្នុងនោះដោយជាតិប៉ារាសេតាម៉ុលវិញ ។ ខ្ញុំបានចាក់ថ្នាំនៅក្នុងសំបកនោះចោល ហើយដាក់ម្សៅថ្នាំប៉ារ៉ាសេតាម៉ុលជំនួសវិញ» ។ ឌុច បានអះអាងថា គាត់បានធ្វើដូច្នោះពីព្រោះគាត់ភ័យខ្លាចថាថ្នាំរបស់ នួន ជា អាចមានសារធាតុពុល ដូច្នេះប្រសិនបើអ្នកទោសស្លាប់ «នោះគឺស្ថិតនៅក្រោមស្នាដៃរបស់គាត់ដែលជាអ្នកឲ្យថ្នាំមានជាតិពុលដល់អ្នកទោស ។ នេះជាមូលហេតុដែលខ្ញុំព្យាយាមដកខ្លួនចេញពីការសម្លាប់មនុស្សដោយផ្ទាល់» ។

ការពិសោធថ្នាំបានបន្តនៅទួលស្លែងរហូតដល់ការផ្តួលរំលំខ្មែរក្រហមពីអំណាចដោយកងទ័ពវៀតណាម ។ ការបូមឈាមប្រហែលជាត្រូវបានបញ្ចប់នៅរយៈពេលប៉ុន្មានខែមុនពេលដែលពេទ្យនៅទួលស្លែង និងមន្ទីរពេទ្យនៅភ្នំពេញដែលត្រូវបានបង្រៀនឲ្យចេះពីរបៀបបូមឈាមនិងផ្លាស់ប្តូរឈាមត្រូវបានបញ្ចប់ ។ ឌុច និងបុគ្គលិកពេទ្យផ្សេងទៀតដែលនៅទួលស្លែងបន្តស្នាក់នៅក្នុងគុករហូតដល់ល្ងាចថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

## ៥) ការពិសោធថ្នាំ ៖ អ្វីដែលគណៈមជ្ឈិមបក្សដឹង

ដោយសារតែ ប៉ុល ពត បញ្ជាឲ្យមានការផ្លាស់ប្តូរថ្នាំបរទេសទៅជាថ្នាំដែលផលិតដោយខ្លួនឯងដើម្បីព្យាបាល គណៈមជ្ឈិមបក្សផ្សេងទៀតក៏ដឹងច្បាស់ពីការពិសោធថ្នាំរបស់ខ្មែរក្រហមដែរ ។ ទាំង ប៉ុល ពត និង ខៀវ សំផន និយាយដោយផ្ទាល់ និងជាសាធារណៈអំពីតម្រូវការនៃការប្រើប្រាស់ថ្នាំដែល «កំពុងស្ថិតនៅក្នុងដំណាក់កាលធ្វើដោយដៃ» ដែលមិនដឹងថាវាមានប្រសិទ្ធភាពឬក៏អត់ ។ ពាក្យសម្តីរបស់អ្នកទាំងពីរនេះមិនត្រឹមតែអាចបញ្ជាក់ថាអ្នកទាំងពីរបានដឹងពីការប្រើប្រាស់ថ្នាំដែលផលិតដោយខ្មែរក្រហមទេ ថែមទាំងដឹងពីការដាក់កំហិតឲ្យប្រើប្រាស់ទៀតផង ។

នួន ជា ក៏ហាក់ដូចជាបានដឹង និងយល់ស្របថា ថ្នាំរបស់កម្ពុជាគឺជាថ្នាំធម្មតា ។ ក្នុងសេចក្តីថ្លែងការណ៍មួយកាលពីខែកក្កដា ១៩៧៨ ទៅកាន់បក្សពលករកុម្មុយនីស្តដាណឺម៉ាក នួន ជា បានអះអាងថា ក្នុងការព្យាបាលអ្នកជំងឺ ការប្តេជ្ញាចិត្តរបស់កម្មាភិបាលពេទ្យក្នុងការប្រកាន់ជំហរបក្សមានសារសំខាន់ជាងការបណ្តុះបណ្តាល ។ នួន ជា បានអះអាងទៀតថា គួរតែបដិសេធជំនួយមនុស្សធម៌អន្តរជាតិ ទោះបីជាវាមានឥទ្ធិពលដល់សុខភាព និងស្ថានភាពរស់នៅរបស់ប្រជាជនក៏ដោយ ៖

> យើងបានព្យាយាមបង្រៀនប្រជាជនយើងឲ្យដឹងពីគោលការណ៍មួយនៃភាពម្ចាស់ការដើម្បីកុំឲ្យប្រទេសជាមិត្ត

*បរទេសលំបាកដល់យើង ។ ខណៈពេលដែលប្រទេសជាមិត្តអាចនឹងជួយយើង ប្រទេសទាំងនោះត្រូវតែធ្វើបដិវត្តដើម្បីខ្លួនឯងនិងធ្វើឲ្យជីវភាពរបស់ប្រជាជនខ្លួនរីកចម្រើនសិន ។ ដូច្នេះយើងបានព្យាយាមអស់ពីសមត្ថភាពដើម្បីបញ្ចៀសនូវជំនួយបរទេសដើម្បីជម្នះនូវការលំបាកទាំងអស់ដោយមិនចាំបាច់មានជំនួយប្រសិនបើមិនចាំបាច់ ។*

នៅទីបញ្ចប់ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងកិច្ចការសង្គម អៀង ធីរិទ្ធ គ្រប់គ្រងទៅលើការថែទាំសុខភាពនៅក្នុងប្រទេស ដូច្នេះគាត់គឺជាអ្នកដឹងពីការប្រើប្រាស់ថ្នាំដែលផលិតដោយខ្លួនឯងដើម្បីពិសោធ ។

មានភស្តុតាងសំខាន់ដែលអាចបង្ហាញថា គណៈមជ្ឈិមបក្សមានជាប់ពាក់ព័ន្ធនឹងការពិសោធដែលកើតឡើងនៅមន្ទីរឃុំឃាំងដូចជាទួលស្លែងជាដើម ។ ឌុច បានប្រាប់អ្នកកាសែតនៅដើមឆ្នាំ១៩៩៩ថា នួន ជា ដឹង និងមានជាប់ពាក់ព័ន្ធនឹងសកម្មភាពនៅទួលស្លែងច្រើន ដែលរួមមានការសម្លាប់ ការពិសោធថ្នាំនិងការបង្ខំឲ្យធ្វើចម្លើយសារភាព ។ នៅក្នុងសវនាការថ្ងៃទីមួយ ឌុច បានសារភាពថាគាត់ធ្វើការដោយផ្ទាល់ជាមួយ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិ និង នួន ជា ។ អ្នកទាំងពីរនេះត្រូវបានគេជឿថាជាអ្នកតំណាងឲ្យគណៈអចិន្ត្រៃយ៍ ។ នៅក្នុងសក្ខីកម្មថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០៩ ឌុច បាននិយាយថា នួន ជា ដឹងពីការពិសោធមនុស្សនៅទួលស្លែង ហើយបានបញ្ជាឲ្យ ឌុច ផ្តល់ថ្នាំពុលទៅឲ្យអ្នកជំងឺដើម្បីធ្វើពិសោធទៅលើប្រសិទ្ធភាពនៃថ្នាំនោះ ។ ការបញ្ជាឲ្យមានការស្រាវជ្រាវទៅលើថ្នាំពុលត្រូវបានគេជឿថាកើតចេញពីគណៈមជ្ឈិមបក្សដែលមាន នួន ជា ជាអ្នកមានទំនាក់ទំនងជាមួយ ឌុច ។

ចំពោះការពាក់ព័ន្ធទៅលើករណីពិសោធថ្នាំនៅទួលស្លែងរបស់ នួន ជា គឺជាករណីផ្ទាល់បំផុតដែលទាក់ទងនឹងបទឧក្រិដ្ឋចំពោះការពិសោធថ្នាំ ហើយ នួន ជា បានធ្វើការងារនេះដោយផ្ទាល់ជាងចុងចោទដទៃទៀតដែលកំពុងតែរង់ចាំការកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែដោយសារតែតួនាទីរបស់ខ្លួននៅគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមបក្ស ខៀវ សំផន និង អៀង សារី ក៏ទំនងជាដឹងពីការពិសោធដែលត្រូវបានអនុវត្តនៅស-២១នេះដែរ ។ របាយការណ៍សម្លាប់ និង សកម្មភាពផ្សេងទៀតនៅស-២១ត្រូវបាន នួន ជា និងមានចំណារទៅកាន់និងមកពី «បង» ឬក៏ពាក្យថា «អង្គការ» ដែលជាគណៈអចិន្ត្រៃយបក្សកុម្មុយនីស្តកម្ពុជាផង ។ របាយការណ៍ដែលបញ្ជូនទៅគណៈមជ្ឈិមបក្សបង្ហាញថា យ៉ាងហោចណាស់ក៏សមាជិកផ្សេងទៀតដឹងពីការសម្លាប់ និងការធ្វើទារុណកម្មនៅទួលស្លែងដែរ ប៉ុន្តែអ្នកទាំងនោះមិនបានធ្វើអ្វីមួយដើម្បីទប់ស្កាត់ឡើយ ។

## ៦) សេចក្តីសន្និដ្ឋាន

អត្ថបទនេះមានគោលបំណងចងក្រងនូវបទល្មើសនៃការព្យាបាលដែលប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ សេចក្តីសម្រេចមិនអនុញ្ញាតឲ្យប្រជាជនកម្ពុជាភាគច្រើនទទួលបានការព្យាបាល និងសេចក្តីសម្រេចធ្វើការពិសោធថ្នាំទៅលើមនុស្ស ។ ផ្នែកបញ្ចប់នៃអត្ថបទនេះនឹងវិភាគទៅលើលទ្ធភាពនៃការចោទប្រកាន់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទសម្លាប់ដែលបណ្តាលមកពីគោលនយោបាយសុខាភិបាល ។ ផ្លូវដែលអាចចោទប្រកាន់ពីបទល្មើសនេះគឺត្រូវអះអាងថាបទល្មើសនេះត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលជាយុត្តាធិការរបស់ អ.វ.ត.ក ។ ការចោទប្រកាន់ពេទ្យណាហ្ស៊ីនៅក្រោយសង្គ្រាមលោកលើកទីពីរពីបទការធ្វើពិសោធថ្នាំទៅលើអ្នកទោសជ្វីហ្វនៅតុលាការយោធានូរ៉ែមប៊ើកនៅក្រោមច្បាប់ទី១០ បានផ្តល់គំរូមួយសម្រាប់ចោទប្រកាន់ជនត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការបញ្ជា និងអនុញ្ញាតឲ្យមានការពិសោធមនុស្សដោយមិនមានការយល់ស្របពីជនរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែរដ្ឋាភិបាលមិនមានតួនាទីផ្តល់ការថែទាំសុខភាពដល់ប្រជាពលរដ្ឋ ដូច្នេះវាមានការលំបាកក្នុងការបង្ហាញថា មុនឆ្នាំ១៩៧៥ មានការចោទប្រកាន់ពីការបដិសេធមិនផ្តល់ការថែទាំសុខភាពថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ដូច្នេះ អត្ថបទនេះនឹងធ្វើការប្រៀបធៀបស្ថានភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ ទៅនឹងស្ថានភាពនៅមន្ទីរឃុំឃាំងរបស់រដ្ឋដែលមន្ត្រីរដ្ឋាភិបាលមានតួនាទីត្រូវផ្តល់ការព្យាបាលជំងឺ និងរបួសដល់ប្រជាជន ។ **ធ្យូរ៉ា ទីលីម**

# ការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍របស់សាលាក្តីខ្មែរក្រហម រំឭកដល់ជនរងគ្រោះនៅអូរត្រកួន

ដូចជាអ្នករងគ្រោះដោយរបបខ្មែរក្រហមដទៃទៀតដែរ ជនជាតិចាមបានទទួលរង់ចាំការចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមទាំងបួនរូបមាន អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, និង នួន ជា យ៉ាងអន្ទះសា ។ ការចោទប្រកាន់កាលពីថ្ងៃព្រហស្បតិ៍ទី ១៧ខែកញ្ញា បានបំពេញការប៉ងប្រាថ្នារបស់ជនជាតិចាមដែលមានតម្លៃជាប្រវត្តិសាស្ត្រនិងតាមផ្លូវច្បាប់ ។

ក្នុងចំណោមបទចោទប្រកាន់លើមេដឹកនាំទាំងបួនរូបដែលបានចែងក្នុងសន្និសីទកាសែត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមនិងជនជាតិវៀតណាមបានទាក់ទាញការចាប់អារម្មណ៍របស់ជនជាតិចាមយ៉ាងខ្លាំង ពីព្រោះការចោទប្រកាន់នេះមានសារសំខាន់ជាដុំកំភួននិងសមហេតុផល ។ រហូតមកដល់ពេលនេះ មេដឹកនាំខ្មែរក្រហមទាំងបួនរូបនៅមិនទាន់សារភាពកំហុសរបស់ខ្លួននៅឡើយ ។ ពីដំបូងឡើយ គោលនយោបាយរបស់ខ្មែរក្រហមបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនទូទៅ ប៉ុន្តែក្រោយមកជនជាតិចាមត្រូវបានសម្រាំងទុកសម្រាប់ការសម្លាប់នៅអូរត្រកួនដោយសារហេតុផលជាតិពន្ធុនិងសាសនានៅក្រោមរបបខ្មែរក្រហម ។

ជាក់ស្តែង បើយោងតាមសាច់រឿងរបស់ ម៉ាន ជនជាតិចាមរាប់រយគ្រួសារដែលបានបញ្ជូនមកពីទីតាំងផ្សេងៗជាពិសេសមកពីខេត្តកំពង់ចាមត្រូវបានសម្រាំងទុក ហើយបញ្ជូនទៅសម្លាប់នៅអូរត្រកួន ខេត្តកំពង់ចាម ដែលស្ថិតនៅក្នុងវត្តអូរត្រកួនក្នុងអំឡុងឆ្នាំ១៩៧៧ ។ មានតែ ម៉ាន និងប្រពន្ធរបស់ខ្លួនប៉ុណ្ណោះដែលបានរស់រានមានជីវិត ដោយសារគាត់អាចលាក់ខ្លួននិងពួនសម្ងំនៅក្នុងអូរប្រឡាយអស់ជារយៈពេលច្រើនថ្ងៃច្រើនយប់ ។ គាត់បានស្នើឲ្យសាលាក្តីខ្មែរក្រហមកាត់ទោសអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្មសាហាវបែបនេះមកលើគាត់និងប្រជាជនទាំងអស់ ។



អ្នកភូមិនៅក្នុងវេទិកាពិភាក្សាពីអំពើប្រល័យពូជសាសន៍

យូសុះ មូហាំម៉ាត់ ដែលជាហាកិមភូមិសាច់សូរបានរីករាយនៅពេលទទួលដំណឹងអំពីការចោទប្រកាន់នេះ ដោយសារគាត់បាត់បង់សាច់ញាតិជាច្រើននៅក្នុងការសម្លាប់នៅអូរត្រកួន។ គាត់បានបញ្ជាក់ថា បន្ថែមទៅនឹងទីតាំងសម្លាប់នៅអូរត្រកួន ការធ្វើទុក្ខបុកម្នេញរបស់ខ្មែរក្រហមទៅលើជនជាតិចាម ដោយរួមមានការហាមប្រាមមិនឲ្យប្រណិប័តន៍ខាងផ្នែកសាសនានិងប្រពៃណីនៅតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយខ្មែរក្រហម គឺអាចដាក់បន្ទុកការទទួលខុសត្រូវលើមេដឹកនាំខ្មែរក្រហមបន្ថែមទៀត។

ជនជាតិចាមជាច្រើន ទាំងអ្នកដាក់ពាក្យបណ្ដឹងជាដើមបណ្ដឹងរដ្ឋប្បវេណីនិងអ្នកដាក់ពាក្យបណ្ដឹងធម្មតា ព្រមទាំងជនជាតិចាមទូទៅបានរៀបចំខ្លួនជាស្រេចសម្រាប់សវនាការលើសំណុំរឿង០០២ និងចូលរួមឲ្យបានសកម្មដាងការចូលរួមក្នុងសំណុំរឿង០០១។

អាំមីណាស់ ដែលបានបាត់បង់ឪពុកនិងប្អូនប្រុសនៅក្នុងការបះបោរនៅភូមិស្វាយឃ្លាំងបានដាក់ពាក្យបណ្ដឹងទៅផ្នែកគាំពារជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងឆ្នាំ២០០៨។ គាត់បានមានប្រសាសន៍ថា គាត់មានការពេញចិត្តនឹងការចោទប្រកាន់របស់អង្គជំនុំជម្រះវិសាមញ្ញ ហើយរៀបចំខ្លួនដើម្បីចូលបំភ្លឺ ប្រសិនបើតុលាការអញ្ជើញរូបគាត់។ គាត់បានរៀបរាប់ថា «ការចោទប្រកាន់ពីបទប្រល័យពូជសាសន៍គឺជារឿងត្រឹមត្រូវ។ ពួកខ្ញុំរង់ចាំឲ្យវាកើតឡើង។ ខ្ញុំមានរឿងដើម្បីនិយាយប្រាប់តុលាការ។ ខ្ញុំជឿថា អ្នកដទៃទៀតក៏មានរឿងជាច្រើនដើម្បីនិយាយប្រាប់តុលាការដែរ។ យើងចង់បានយុត្តិធម៌»។

របបខ្មែរក្រហមបានប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនកម្ពុជាស្ទើរគ្រប់រូប ហើយការចោទប្រកាន់ពីបទប្រល័យពូជសាសន៍របស់សាលាក្ដីខ្មែរក្រហមមិនមែនមានន័យថា ជនជាតិចាមរងគ្រោះជាងគេទេ ប៉ុន្តែជាការរកយុត្តិធម៌ទៅលើទង្វើដែលមេដឹកនាំខ្មែរក្រហមប្រព្រឹត្តយ៉ាងធ្ងន់ធ្ងរមកលើជនជាតិភាគតិចក្នុងអំឡុងនៃការគ្រប់គ្រងរបស់ខ្លួន។

បើពិនិត្យមើលទៅលើការចង់ចូលរួមរបស់សហគមន៍ចាមនៅក្នុងដំណើរការតុលាការ អ្វីដែលសាលាក្ដីខ្មែរក្រហមត្រូវធ្វើគឺត្រូវធានាឲ្យបាននូវសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមយ៉ាងពេញលេញក្នុងដំណើរការផ្លូវច្បាប់។ សំខាន់ដូចគ្នាដែរ សាលាក្ដីខ្មែរក្រហមត្រូវពន្លឿនសវនាការដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះឲ្យបានទាន់ពេលវេលានិងប្រកបដោយអត្ថន័យខ្ពស់។ **ស្វ ហ្វារីណា**


ព្រះវិហារអ៊ីស្លាម

# ការឈានទៅរកការកាត់ទោសខ្មែរក្រហម ៖ ដីកាដំណោះស្រាយនៅក្នុង សំណុំរឿង០០២ មុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ក) សេចក្តីផ្តើម

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជូនដីកាដំណោះស្រាយសម្រាប់សំណុំរឿងលេខ០០២ ដោយធ្វើការចោទប្រកាន់ជនជាប់ចោទទាំងបួនពីបទឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ។ ជនជាប់ចោទទាំងបួនដែលជាប់ឃុំឃាំងបណ្តោះអាសន្ននៅអង្គបុរេជំនុំជម្រះចាប់តាំងពីឆ្នាំ២០០៧ នេះគឺជាសមាជិករបស់គណៈកម្មការមជ្ឈិមខ្មែរក្រហម ឬគណៈកម្មការកណ្តាលដែលនៅរស់រានមានជីវិត ។

ដីកាដំណោះស្រាយចាប់ផ្តើមធ្វើឡើងភ្លាមបន្ទាប់ពីសាលក្រមលើកទីមួយត្រូវបានប្រកាសដាក់ទោសប្រធានមន្ទីរស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយសាលាក្តីខ្មែរក្រហមកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ ដីកាដំណោះស្រាយបានផ្តល់សិទ្ធិអំណាចឲ្យសហព្រះរាជអាជ្ញាចាប់ផ្តើមធ្វើការស៊ើបអង្កេតជនជាប់ចោទទាំងបួននាក់នេះពីបទចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ រឿងក្តីនេះនឹងគ្របដណ្តប់ព្រឹត្តិការណ៍ច្រើនជាងរឿងក្តី ឌុច ដែលមានតែឧក្រិដ្ឋកម្មមួយចំនួនដែលប្រព្រឹត្តនៅមន្ទីរឃុំឃាំងស-២១ ឬគុកទួលស្លែង ។ ដោយសារតែលក្ខណៈធំធេងនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយខ្មែរក្រហម នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរកាលពីឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតផ្តោតការស៊ើបអង្កេតលើឧក្រិដ្ឋកម្មមួយចំនួននៅតាមតំបន់ជាក់លាក់មួយចំនួន ។ ទ្រឹស្តីដ៏មានឥទ្ធិពលនៃរឿងក្តីរបស់ជនជាប់ចោទទាំងបួននាក់នេះគឺថា ខ្មែរក្រហមបានប្រើប្រាស់ជនល្មើសដើម្បីអនុវត្តគម្រោងបដិវត្តន៍របស់ខ្លួន ។ សហចៅក្រមស៊ើបអង្កេតបានបញ្ចប់ការស៊ើបអង្កេតនេះកាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ដោយចេញជាដីកាដំណោះស្រាយចំនួន៧៣៩ទំព័រ ដែលនេះគឺជាប្រធានបទសម្រាប់អត្ថបទមួយនេះ ។ អង្គជំនុំជម្រះត្រូវបានសន្មតថានឹងចាប់ផ្តើមដំណើរការនៅខែមករា ឆ្នាំ២០១១នេះ ។

### ២) ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់

វិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហមចែងថាបទដ្ឋានភ័ស្តុតាងដើម្បីបញ្ជូនជនល្មើសមកជំនុំជម្រះក្តីគឺជា «ភ័ស្តុតាងដែលគ្រប់គ្រាន់ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់» ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ។ សម្រាប់ការអនុវត្តបទដ្ឋានវិភាគនេះត្រូវបានរក្សាទុកជា «ឆន្ទានុសិទ្ធិសេរី» របស់ចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថាជនជាប់ចោទអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មទាំងអស់ដែលឋិតនៅក្នុងយុត្តាធិការតាមសាច់រឿងរបស់សាលាក្តីខ្មែរក្រហមដែលស្ថិតនៅក្រោមការទទួលខុសត្រូវច្រើនទម្រង់ ។

#### ក) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទឧក្រិដ្ឋស្រដៀងគ្នាមួយប្រភេទដែលត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិនៅពេលដែលឧក្រិដ្ឋកម្មនេះត្រូវបានប្រព្រឹត្តឡើងនៅក្នុងបរិបទជាការវាយប្រហារជាប្រព័ន្ធ ឬជាទ្រង់ទ្រាយធំមកលើប្រជាជនស៊ីវិលដោយមានការទទួលដឹងឮពីការវាយប្រហារនោះ ។ អត្ថបទរបស់លក្ខន្តិកៈសាលាក្តីខ្មែរក្រហមផ្តល់និយមន័យឲ្យបទឧក្រិដ្ឋកម្មនេះខុសពីនិយមន័យរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយរួមបញ្ចូលលក្ខខណ្ឌដែលថា ការវាយប្រហារនោះត្រូវតែធ្វើឡើងដោយ «មូលដ្ឋានជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា....» ។ យោងតាមដីកាដំណោះស្រាយ ការវាយប្រហារសំដៅមកលើប្រជាជនស៊ីវិលរួមមាន ការគាបសង្កត់ដោយ «ការគ្រប់គ្រងជាលក្ខណៈផ្តាច់ការលើប្រជាជនកម្ពុជាទាំងអស់ដោយស្របទៅតាមគោលដៅរបស់ខ្មែរក្រហម ដើម្បីបង្កើត

បដិវត្តន៍សង្គមនិយមដ៏លឿនមួយនៅក្នុងប្រទេសកម្ពុជានិងដើម្បីកម្ចាត់ខ្មាំងខាងក្នុង និងខាងក្រៅបក្ស ។ សហចៅក្រមស៊ើបអង្កេតបានអះអាងថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាការចោទប្រកាន់បន្ទាប់បន្សំមួយដើម្បីដោះស្រាយបញ្ហា ៖ ការជម្លៀសប្រជាជនស៊ីវិលទូទាំងប្រទេសម្តងហើយម្តងទៀត ការបង្ខំឲ្យរស់នៅតាមសហករណ៍ក្រោមស្ថានភាពលំបាកជាទ្រង់ទ្រាយធំ ការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ការកម្ចាត់សមាសធាតុក្បត់ និងការបង្ខំឲ្យមានការរៀបការ ។ ដីកាដំណោះស្រាយកត់សម្គាល់ឃើញថា ៖ បើទោះបីជាការបង្កើតឡើងនូវគម្រោងមនោគមន៍វិជ្ជាមួយមិនអាចត្រូវបានចាត់ទុកថាជាសមាធាតុនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្របច្បាប់ក៏ដោយ ក៏ការអនុវត្តគម្រោងដែលត្រូវបានអនុម័តដោយការប្រើប្រាស់ជនល្មើសឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មតាមបញ្ជារបស់ខ្មែរក្រហមនេះឆ្លុះបង្ហាញពីលក្ខណៈនៃការវាយប្រហារជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ។


នួន ជា

ការអនុវត្តគម្រោងនេះបានទាមទារឲ្យមានការរៀបចំគម្រោងមជ្ឈិមកម្រិតខ្ពស់ដែលមាន «លក្ខណៈផ្តាច់ការចាប់ពីថ្នាក់លើរហូតមកដល់ថ្នាក់ក្រោម...» ។ ដីកាដំណោះស្រាយអះអាងថា «ទ្រង់ទ្រាយធំនៃការវាយប្រហារត្រូវបានដឹកនាំដោយជនជាប់ចោទនិងជនដែលដល់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ ដោយសារតែការចេញបញ្ជាពីកម្មាភិបាលបក្សនិងបុគ្គលដែលទទួលខុសត្រូវការអនុវត្តគោលនយោបាយ ។

សហចៅក្រមស៊ើបអង្កេតបានសម្រេចថាជនជាប់ចោទទាំងបួននាក់នេះគួរតែត្រូវបានកាត់ទោសសម្រាប់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅ ៖ ការសម្លាប់បំផុតពូជ ឃាតកម្ម ការដាក់ឲ្យធ្វើជាទាសករ ការជម្លៀស ការឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ការរំលោភផ្លូវភេទ និងសកម្មភាពព្រៃផ្សៃផ្សេងៗទៀត ។ បទចោទប្រកាន់ពីអំពើឃាតកម្មនិងការសម្លាប់បំផុតពូជបណ្តាលមកពីការធ្វើបន្សុតកម្មខ្មាំងរបស់ខ្មែរក្រហម (មកលើសមាជិកនៃរបបមុន) និងការសម្លាប់ដែលប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខនិងតាមទីតាំងសម្លាប់ផ្សេងៗ ។ ចាប់តាំងពីឆ្នាំ១៩៧៧ ការសម្លាប់សមាជិករបស់សហគមន៍ជនជាតិវៀតណាមនិងចាម បានកើនដល់កម្រិតខ្ពស់ដែលមានលក្ខណៈស្មើនឹងការសម្លាប់បំផុតពូជដែរ ។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតបានបង្ហាញថាជនជាប់ចោទទាំងបួននាក់នេះអាចនឹងត្រូវបានចោទប្រកាន់ពីបទសម្លាប់បំផុតពូជសម្រាប់ចំនួនមនុស្សស្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ដែលបណ្តាលមកពីការជម្លៀសប្រជាជនជាទ្រង់ទ្រាយធំ និងដោយសារស្ថានភាពរស់នៅតាមមន្ទីរសន្តិសុខ ។ បទចោទប្រកាន់ពីការដាក់ឲ្យធ្វើជាទាសករ ការឃុំឃាំង និងការធ្វើទារុណកម្មគឺបណ្តាលមកពីអំពើហិង្សាដែលកើតមាននៅតាមកសិដ្ឋានការងារសហករណ៍ និងមន្ទីរសន្តិសុខដែលសមាជិកខ្មែរក្រហមបានអនុវត្ត «ការគ្រប់គ្រងផ្តាច់ការលើសិទ្ធិរបស់បុគ្គលទាក់ទងនឹងកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ប្រជាជនដែលរស់នៅតាមទីកន្លែងទាំងអស់នោះ» ។ សកម្មភាពរំលោភបំពានលើសិទ្ធិសេរីភាពនៅតាមកសិដ្ឋានការងារនិងសហករណ៍ក៏ត្រូវបានចាត់ទុកជាការឃុំឃាំងផងដែរ ។ បទចោទប្រកាន់ពីការជម្លៀសគឺពាក់ព័ន្ធនឹងជនជាតិវៀតណាមដែលត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសកម្ពុជាក្រោយពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ។

លើសពីនេះ សហចៅក្រមស៊ើបអង្កេតបានរកឃើញថាការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ (មកលើបញ្ញាជន និងជនដែលជាប់ពាក់ព័ន្ធនឹងរបបមុន) ផ្នែកសាសនា (មកលើសមាជិករបស់សហគមន៍ចាម និងអ្នកប្រកាន់ខ្ជាប់សាសនាព្រះពុទ្ធ) និងផ្នែកពូជសាសន៍ (មកលើប្រជាជនវៀតណាម) មានចំនួនស្មើនឹងការរំលោភធ្ងន់ធ្ងរលើសិទ្ធិមូលដ្ឋានរបស់មនុស្សដែលត្រូវបានទទួលស្គាល់ដោយច្បាប់អនុសញ្ញាអន្តរជាតិនិងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ បទចោទប្រកាន់លើការប្រព្រឹត្តអំពើព្រៃផ្សៃផ្សេងទៀតតាមរយៈការវាយប្រហារលើតម្លៃរបស់មនុស្សគឺរួមបញ្ចូលការបង្អត់អាហារ ទីកន្លែងរស់នៅ ការថែទាំសុខភាព និងអនាម័យក្នុងការរស់នៅដែលកើតមាននៅក្នុងអំឡុងពេលជម្លៀសប្រជាជន

ឲ្យទៅរស់នៅក្នុងស្ថានភាពដែលលំបាកនៅតាមសហករណ៍ការងារ ។ បទចោទប្រកាន់ពីការរំលោភផ្លូវភេទគឺបណ្តាលមកពីការរៀបការដោយបង្ខំនិងចំណងស្នេហាទាំងបង្ខំដែលត្រូវបានចោទប្រកាន់ថាជាអំពើព្រៃផ្សៃដែរ ។

**ខ) ឧក្រិដ្ឋកម្មសង្គ្រាម**

ជាមួយគ្នានេះ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ជនជាប់ចោទទាំងបួននាក់ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ៖ ការសម្លាប់មនុស្សដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗ ការបង្កឲ្យមានរបួសធ្ងន់ធ្ងរ ឬឈឺចាប់ខ្លាំងផ្សារលើរូបរាងកាយ និងសុខភាពដោយចេតនា និងការនិរទេស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ។ ទង្វើជាច្រើននៅក្នុងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមនេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសកម្មភាពដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ។ បទចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមក៏រួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាមកលើប្រជាជនវៀតណាមនិងការខូចខាតទ្រព្យសម្បត្តិរបស់ប្រជាជនដោយសារតែការរត់ភៀសខ្លួនចូលប្រទេសវៀតណាម ។


អៀង សារី

បទចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមគឺផ្អែកលើការកកើតមាននូវជម្លោះប្រដាប់អាវុធរបស់ប្រទេស និងទំនាក់ទំនងរវាងសកម្មភាពដែលត្រូវបានចោទប្រកាន់ និងជម្លោះប្រដាប់អាវុធ ។ សហចៅក្រមស៊ើបអង្កេតបានអះអាងថា ភ្លាមៗក្រោយពេលដែលកងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ស្ថានភាពជម្លោះប្រដាប់អាវុធជាអន្តរជាតិបានកើតមានឡើងរវាងប្រទេសកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម បើទោះបីជាជម្លោះប្រដាប់អាវុធនេះមិនត្រូវបានទទួលស្គាល់រហូតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ក៏ដោយ ។ ជម្លោះប្រដាប់អាវុធនេះបានបន្តរហូតដល់វៀតណាមបានវាយបែកទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ការចោទប្រកាន់ទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការវិនិច្ឆ័យទោស ឌុច ថាជម្លោះនៅតាមព្រំដែន និងការវាយលុកចូលទឹកដីរបស់ប្រទេសកម្ពុជា និងវៀតណាមក្នុងឆ្នាំ១៩៧៥ - ១៩៧៩ បានចាត់ទុកថាជាជម្លោះប្រដាប់អាវុធអន្តរជាតិ ។

**គ) អំពើប្រល័យពូជសាសន៍**

សំណួរដែលសួរថាតើខ្មែរក្រហមពិតជាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មែនដែរឬទេនោះបានក្លាយជាការពិភាក្សាវែកញែកដ៏តានតឹងទាំងនៅក្នុងនិងក្រៅប្រទេសកម្ពុជា ។ ជាក់ស្តែង ប្រទេសកម្ពុជាមានលក្ខណៈខុសប្លែកពីប្រទេសដែលត្រូវបានចាត់ទុកថាជាប្រទេសដែលទទួលរងអំពើប្រល័យពូជសាសន៍ក្រោយអំពើប្រល័យពូជសាសន៍ដំបូងបង្អស់បានកើតមានឡើងរួចមកហើយ អំពើហិង្សាដែលប្រព្រឹត្តដោយខ្មែរក្រហមមិនត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍យោងតាមអនុសញ្ញាអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ឡើយ ។ នេះគឺដោយសារតែហេតុថាក្រុមជនដៃដល់ និងក្រុមជនរងគ្រោះមានសញ្ជាតិជាតិពន្ធុ ពូជសាសន៍ និងសាសនាដូចគ្នា ។ ផ្ទុយទៅវិញ ជនរងគ្រោះបានទទួលរងអំពើប្រល័យពូជសាសន៍ដោយសារតែពួកគេជាសមាជិករបស់ក្រុមនយោបាយ សង្គម និងក្រុមសេដ្ឋកិច្ចដែលប្រឆាំងនឹងគោលនយោបាយរបស់ខ្មែរក្រហម ។ បន្ទាប់ពីការវិភាគវែកញែក និងកិច្ចព្រមព្រៀងត្រូវបានសម្រេចធ្វើឡើងរួចមក អ្នកចេញសេចក្តីព្រាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បានច្រានចោលការការពារលើក្រុមនយោបាយ ក្រុមសង្គម ក្រុមសេដ្ឋកិច្ច និងក្រុមស្រដៀងគ្នាផ្សេងទៀត ។ បើទោះបីជាអំណះអំណាងយោងតាមទ្រឹស្តីបានថែងថា ការវាយប្រហារមកលើក្រុមខាងលើនេះអាចចូលនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានអនុវត្តវិធីសាស្ត្រស្របតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយធ្វើការចោទប្រកាន់តែពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តមកលើក្រុមជនជាតិភាគតិច ចាម និងវៀតណាមតែប៉ុណ្ណោះ ។

យោងតាមសហចៅក្រមស៊ើបអង្កេត គោលដៅបដិវត្តន៍របស់ខ្មែរក្រហម គឺដើម្បីបង្កើតជាសង្គមតែមួយដោយគ្មានការបែងចែកវណ្ណៈ ដោយលុបបំបាត់ភាពខុសគ្នានៃវប្បធម៌ វណ្ណៈ ពូជសាសន៍ សាសនា ជាតិ និងជាតិពន្ធុ ។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឯកសារនៅក្នុងភ័ស្តុតាងដែលអះអាងថាការលុបបំបាត់ចោល ឬការប្រព្រឹត្តអំពើប្រហាក់ប្រហែលគ្នានេះមកលើក្រុមជនជាតិភាគតិចត្រូវបានសម្រេចជាស្ថាពរ ។ កម្មាភិបាលខ្មែរក្រហមបាននិរទេសសមាជិករបស់សហគមន៍ជនជាតិភាគតិចចាម និងគាបសង្កត់លើវប្បធម៌របស់ជនជាតិចាម ។ ការធ្វើទុក្ខបុកម្នេញនេះត្រូវបានធ្វើឡើងបន្ទាប់ពីការសម្លាប់ជនជាតិចាមជាទ្រង់ទ្រាយធំកាលពីដើមឆ្នាំ១៩៧៧ ហើយបានបណ្តាលឲ្យប្រជាជនចាមប្រមាណ៣៦ភាគរយបានបាត់បង់ជីវិត យោងតាមរបាយការណ៍ប្រជាសាស្ត្រដែលត្រូវបានកត់ត្រាទុក ។ សម្រាប់ប្រជាជនវៀតណាមដែលសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថាជាក្រុមជាតិពន្ធុ ក្រុមជាតិ ឬក្រុមពូជសាសន៍វិញត្រូវបានរងគ្រោះដោយសារការជម្លៀសដោយបង្ខំ ។ បន្ទាប់មកទៀត ខ្មែរក្រហមបានចេញសេចក្តីប្រកាសតាមរយៈទស្សនាវដ្តីទង់បដិវត្តន៍ និងតាមរយៈវគ្គបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហមថាឲ្យសម្លាប់សមាជិករបស់សហគមន៍វៀតណាមដែលនៅសេសសល់ក្នុងប្រទេសកម្ពុជាទាំងអស់ ។ បើទោះបីជាចំនួនជនរងគ្រោះមិនសូវគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាការសម្លាប់នេះជាអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានសម្រេចថាភ័ស្តុតាងនៅក្នុងសំណុំរឿងបានបង្ហាញឲ្យឃើញថា ចំនួនប្រជាជនដែលត្រូវបានសម្លាប់នោះគឺជាភ័ស្តុតាងដ៏ចម្បងមួយស្តីពីគោលបំណងរបស់ខ្មែរក្រហមក្នុងការបំផ្លិចបំផ្លាញក្រុមណាមួយទាំងស្រុង ឬដោយផ្នែក ។ ជាក់ស្តែង យោងតាមរបាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ប្រជាជនវៀតណាមដែលនៅសេសសល់ក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមស្ទើរតែទាំងអស់ត្រូវបានសម្លាប់ចោល ។


អៀង ធីរិទ្ធ

## ឃ) ខក្រិដ្ឋកម្មក្នុងស្រុក

ដូចគ្នានឹងលក្ខន្តិកៈរបស់តុលាការកូនកាត់ផ្សេងៗជាច្រើនទៀត លក្ខន្តិកៈរបស់សាលាក្តីខ្មែរក្រហមអនុញ្ញាតឲ្យមានការកាត់ទោសពីបទឧក្រិដ្ឋកម្មក្នុងស្រុកស្របគ្នានឹងឧក្រិដ្ឋកម្មអន្តរជាតិផងដែរ ។ ក្នុងករណីនេះ បទចោទប្រកាន់ពីឧក្រិដ្ឋកម្មក្នុងស្រុកនេះអាចនឹងធ្វើការកាត់ទោសយោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៤៩ ដែលក្រមនេះមិនត្រូវបានទុកជាមោឃៈដោយខ្មែរក្រហមបានឡើយ ។ នៅក្នុងរឿងក្តី ឌុច សហចៅក្រមស៊ើបអង្កេតបានបដិសេធមិនធ្វើបទចោទប្រកាន់នេះយោងតាមច្បាប់ក្នុងស្រុកដោយផ្អែកលើទ្រឹស្តីដែលថាឧក្រិដ្ឋកម្មនេះអាចត្រូវបានចោទប្រកាន់យោងតាមលក្ខខណ្ឌផ្លូវច្បាប់ខ្ពស់ ។ បណ្តឹងឧទ្ធរណ៍ចេញដោយសហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យមានបទចោទប្រកាន់បន្ថែម ហើយបូកបន្ថែមឧក្រិដ្ឋកម្មក្នុងស្រុកស្តីពីការធ្វើទារុណកម្ម និងសម្លាប់ចូលទៅក្នុងដីកាដំណោះស្រាយរបស់រឿងក្តី ឌុច ។ យ៉ាងណាមិញ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយថាតើលក្ខន្តិកៈដែលជាប់ពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យលើកម្រិតទោសបានបញ្ឈប់ការកាត់ទោសពីបទឧក្រិដ្ឋកម្មបែបនេះឬយ៉ាងណា ។ ដូច្នេះហើយបានជាអង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចថាតើ ឌុច មានទោស ឬមិនមានទោសពីបទឧក្រិដ្ឋកម្មក្នុងស្រុកនេះ ។ នៅក្នុងសំណុំរឿងលេខ ០០២ សហចៅក្រមស៊ើបអង្កេតបានសម្រេចធ្វើការចោទប្រកាន់ជនជាប់ចោទទាំងបួនពីបទមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើផ្នែកសាសនានិងទុកភារកិច្ចឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថាតើបទចោទប្រកាន់ខាងលើនេះត្រឹមត្រូវឬក៏យ៉ាងណា ។

## ង) ទ្រឹស្តីស្តីពីការទទួលខុសត្រូវ

ដីកាដំណោះស្រាយចែងថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌគ្រប់កម្រិតទាំងអស់ដែលត្រូវបានកំណត់ដោយច្បាប់របស់សាលាក្តីខ្មែរក្រហមគឺជាផ្នែករបស់ច្បាប់អន្តរជាតិក្នុងអំឡុងរបបខ្មែរក្រហម

រួមមានទ្រឹស្តីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមផងដែរ ។ ជាក់ស្តែង ទម្រង់បែបបទរបស់ទ្រឹស្តីស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមបានព្រាងចេញជាដីកាដំណោះស្រាយនេះឡើង ។ យោងតាមសហចៅក្រមស៊ើបអង្កេត គោលដៅរួមនៃទស្សនវិស័យដឹកនាំរបស់ខ្មែរក្រហមគឺដើម្បីនាំមកនូវ «បដិវត្តន៍សង្គមនិយមដ៏លឿន» មួយនៅក្នុងប្រទេសកម្ពុជាតាមរយៈវិធានការ «មហាលោតផ្លោះ» និងការពារបក្សប្រឆាំងនឹងខ្មាំងខាងក្នុងនិងខាងក្រៅបក្សគ្រប់មធ្យោបាយទាំងអស់» ។ ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ជនជាប់ចោទនិងជនដទៃទៀតបានអនុវត្តកិច្ចការរបស់ខ្លួនដើម្បីសម្រេចគោលដៅរួមនេះតាមរយៈការធ្វើសកម្មភាពនិងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ បន្ថែមលើនេះ ដីកាដំណោះស្រាយធ្វើការចោទប្រកាន់ជនជាប់ចោទពីការរៀបចំគម្រោងការញុះញង់ ការឧបត្ថម្ភ និងជំរុញឲ្យមានអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ម្យ៉ាងវិញទៀត ជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រូវបានចោទប្រកាន់ពីការមានទំនួលខុសត្រូវខ្ពស់សម្រាប់ឧក្រិដ្ឋកម្មទាំងនេះអស់ ។ យ៉ាងណាមិញ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា អៀង ធីរិទ្ធ មិនមានអំណាចគ្រប់គ្រងលើជនដៃដល់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះដែលនឹងត្រូវទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មនោះក្នុងនាមជាថ្នាក់ដឹកនាំម្នាក់នោះទេ ដោយសារតែមានភ័ស្តុតាងមិនគ្រប់គ្រាន់ ។



ខៀវ សំផន

## ៣) សេចក្តីសន្និដ្ឋាន

វាគ្មានអ្វីគួរឲ្យឆ្ងល់ទេដែលថាជនជាប់ចោទទាំងបួននាក់នេះគឺជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែលមានការទទួលខុសត្រូវលើការបង្កើតជាគម្រោងបដិវត្តន៍ដែលនាំមកនូវសេចក្តីវិនាសអន្តរាយដ៏ធំធេង ។ សំណុំរឿង០០២នឹងសម្រេចឲ្យបានថាតើជនជាប់ចោទទាំងនេះត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអ្វីខ្លះដែលបានប្រព្រឹត្តឡើងនៅក្នុងការអនុវត្តគម្រោងបដិវត្តន៍ទូទាំងប្រទេសកម្ពុជា ដោយសារតែកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាលមិនមានការប្រុងប្រយ័ត្ននៅក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ។ រហូតមកដល់បច្ចុប្បន្ននេះ ជនជាប់ចោទទាំងបួននាក់នេះបានប្រកាសមិនទទួលស្គាល់ការចូលរួមពាក់ព័ន្ធនៅក្នុងបទល្មើសដែលអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្តឡើយ ហើយបានទុកការទទួលខុសត្រូវពីបទឧក្រិដ្ឋទាំងនេះលើអ្នកស្មោះស្ម័គ្រនឹងបក្សដែលបានស្លាប់ទៅហើយនោះ ជាពិសេសគឺ ប៉ុល ពត ជាដើម ។

ដោយសារតែដីកាដំណោះស្រាយសម្រាប់សំណុំរឿង០០២ត្រូវបានចេញប្រកាសហើយនោះ សហចៅក្រមស៊ើបអង្កេតអាចប្តូរទៅផ្តោតការយកចិត្តទុកដាក់លើសំណុំរឿងលេខ០០៣ និង០០៤វិញម្តង ដែលនឹងរួមបញ្ចូលជនជាប់ចោទថ្នាក់ក្រោមចំនួនប្រាំនាក់ទៀត ។ អត្តសញ្ញាណរបស់ជនជាប់ចោទទាំងប្រាំនាក់នេះមិនទាន់ត្រូវបានបង្ហាញឲ្យដឹងនៅឡើយទេ ប៉ុន្តែលទ្ធភាពនៃការចោទប្រកាន់បន្ថែមទៀតត្រូវបានរារាំងដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលចង់ឲ្យសាលាក្តីខ្មែរក្រហមបញ្ចប់ត្រឹមសំណុំរឿង០០២នេះ ហើយបិទដំណើរការកាត់ទោសតទៅទៀត ។ ជាក់ស្តែង សេចក្តីសម្រេចក្នុងការកាត់ទោសរឿងក្តីបន្ថែមទៀតនេះបានធ្វើឲ្យមានការបែកបាក់គ្នានៅក្នុងតុលាការកូនកាត់នេះ ដោយសហព្រះរាជអាជ្ញាជាតិនិងសហចៅក្រមស៊ើបអង្កេតជាតិបានប្រឆាំងនឹងសេចក្តីសម្រេចនេះ ចំណែកឯខាងក្រុមអន្តរជាតិវិញគាំទ្រសេចក្តីសម្រេចនេះ ។

បញ្ហានេះបានទាមទារឲ្យមានសេចក្តីសម្រេចចេញពីអង្គបុរេជំនុំជម្រះដើម្បីជំរុញឲ្យមានការកាត់ទោសរឿងក្តីពីរនេះបន្ថែមទៀត ។ បើទោះបីជារឿងក្តីរបស់ ឌុច បានដំណើរការយ៉ាងរលូនក៏ដោយ ក៏សំណុំរឿង០០២នេះនឹងបណ្តាលឲ្យសាលាក្តីខ្មែរក្រហមប្រឈមមុខនឹងបញ្ហាថ្មីៗជាច្រើនទៀតដោយសារតែភាពស្មុគស្មាញរបស់រឿងក្តីនេះនិងដោយសារតែមានដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់បានចូលរួមដាក់ពាក្យបណ្តឹង ។

**ប៉ែត ម៉ាន់ស្អាក់**

# វិញ្ញាណចងចាំ

**(តចប់)**

ខ្ញុំខឹងនឹងក្មួយខ្លាំងណាស់ រួចហើយមួលសាច់វាកុំឲ្យធ្វើដូច្នោះទៀត ។ គិតទៅក្មេងអាយុ៦ឆ្នាំចេះរកពាក្យភូតកុហកនិងលួចដើម្បីដោះសាយករួចខ្លួននេះក៏ព្រោះតែវាអត់មានអាហារហូប ។

## ស្ត្រីកំណាច

គ្រួសារខ្ញុំខំធ្វើការណាស់ ព្រោះខ្លាចអ្នកស្រុករាយការណ៍ទៅអង្គការថ្នាក់លើ ហើយយកទៅសម្លាប់ ជាពិសេសម៉ាក់ខ្ញុំព្រោះគាត់ធ្លាប់ជាកូនអ្នកចម្ការ គាត់ធ្លាប់ធ្វើការងារលំបាក ។ ថ្ងៃមួយបងស្រីខ្ញុំទៅស្ទូងស្រូវបានទាស់សម្តីជាមួយនឹងអ្នកស្រុកក្នុងភូមិនោះឈ្មោះ មីតាំ ជាស្ត្រីកាចនិងឆ្នាសណាស់ ហើយចេះតែរករឿងនិងបង្កជម្លោះជាមួយបងស្រីខ្ញុំជាហូរហែច្រើនលើកច្រើនដង



ថៃ ច័ន្ទរិទ្ធ

ហើយដោយសារបងស្រីខ្ញុំទ្រាំពុំបាន គាត់ក៏ប្រកែកតវ៉ានឹងវា ។ ម្តាយខ្ញុំព្រួយបារម្ភខ្លាំងណាស់ចំពោះរឿងបងស្រី ។ នៅពេលនោះឆ្នាំ១៩៧៧ ខ្មែរក្រហមមានផែនការថ្មី ដោយយកអ្នកណាដែលគេគិតថាជាខ្មាំងអង្គការ ឬដឹងថាមានខ្សែស្រឡាយជាយួនអ្នករាជការ ឬអ្នកជំនួញទៅសម្លាប់ចោល ។ ក្នុងឆ្នាំដដែលនោះ ចែថា នឹងដៀប និងកូនតូចៗទាំងបីរបស់គាត់ត្រូវក្រុម មីតាំ រាយការណ៍ឲ្យអង្គការយកគ្រួសារគាត់ទៅសម្លាប់ចោលទាំងអស់ ព្រោះពេលព្រលប់ថ្ងៃនោះ ឈ្លបបានបើកកាណូតមកដឹកគ្រួសារបងខ្ញុំចេញទៅដោយកុហកថា គាត់និងគ្រួសារត្រូវប្តូរទីលំនៅថ្មី ។ ប៉ុន្តែចាប់តាំងពីថ្ងៃនោះមក ខ្ញុំមិនដែលបានជួបមុខបងខ្ញុំ ឬឮដំណឹងពីគ្រួសារគាត់ឡើយ ។ អ្វីដែលធ្វើឲ្យខ្ញុំខ្លោចផ្សាក្នុងចិត្តនោះគឺ ក្មួយតូចៗរបស់ខ្ញុំទាំងបីនាក់ដែលមិនមានកំហុស និងមិនទាន់យល់អ្វីទាំងអស់ត្រូវកងឈ្លបយកទៅសម្លាប់ចោលទៀត ហើយតើពេលនោះបងខ្ញុំតក់ស្លុតយ៉ាងណាពេលឃើញឈ្លបវាយសម្លាប់កូនរបស់គាត់មុននៅចំពោះមុខគាត់ ។

## អាហារពិសេស

ឥឡូវនេះគ្រួសារខ្ញុំសល់មនុស្សតែប្រាំបីនាក់ប៉ុណ្ណោះ ដែលពីមុនមានសមាជិក១៨នាក់ពេលចេញពីផ្ទះ កុងសីន់ មកគឺ ប៉ា ម៉ាក់ ចែស្រី បងមុំ បងពៅ រូបខ្ញុំ និងប្អូនខ្ញុំអាញ៉ា និងបងជីដូនមួយ រិត ។ ចែស្រី និង បងរិត ជាមនុស្សពេញវ័យ ម្ល៉ោះហើយត្រូវគេបំបែកឲ្យទៅកងចល័តនៅស្រុកផ្សេង ។ ពេលយប់មួយនោះមិនដឹងជាប៉ាបានឆ្មាពីណាមកទេឲ្យខ្ញុំយកទៅច្រកការុងហើយបោះទៅក្នុងទឹកស្ទឹង រួចឲ្យខ្ញុំនៅរង់ចាំរហូតដល់វាឈ្លក់ទឹកងាប់ទើបយកមកឲ្យគាត់វិញ ។ ប៉ាយកឆ្មានោះទៅព្រលះយកសាច់ធ្វើម្ហូប ហើយពេលនោះដោយសារសេចក្តីស្រេកឃ្លានខ្លាំងពេកយើងហូបគ្មានសល់អ្វីឡើយ ។ យើងហូបឆ្អែតតែមួយពេលប៉ុណ្ណោះ ក្រោយមក ខ្ញុំដើរទៅមើលក្នុងថ្លុកក្របីចាប់កូនស្ទើនយកមកស្ងោរហូបសូម្បីតែអំបិលក៏គ្មានបង់ដែរ ។ ថ្ងៃមួយនោះមានក្មេងម្នាក់អាយុស្របាលនឹងខ្ញុំវាចាប់ឈ្លើងមួយដែលទើបនឹងជ្រុះចេញពីក្របី (ព្រោះឈ្លើងនោះទាមក្របីយូរហើយ) ហើយខ្លួនរបស់វាឡើងប៉ោងប៉ុនកដៃយកទៅបោះចូលក្នុងគុកភ្លើងផ្ទុះលាន់សូរភូស បន្ទាប់មកវាយកមកខាំទាញស៊ីយ៉ាងឆ្ងាញ់ធ្វើឲ្យក្មេងដែលឈរមើលវាស្រឡាំងកាំងគ្រប់គ្នា ។

ក្នុងឆ្នាំ១៩៧៧ មានមនុស្សស្លាប់បន្តបន្ទាប់រហូតឡើងស្វាត់ក្នុងភូមិដោយសារការអត់ឃ្លាន ។ ខ្ញុំឃើញតែមនុស្សសែង

ខ្មោចចេញក្រៅភូមិយកទៅកប់នៅទីទួលខាងក្រោយ ហើយសាកសពភាគច្រើនត្រូវគេជីកកប់រាក់ៗប៉ុណ្ណោះព្រោះអ្នកសែងខ្មោចនោះក៏គ្មានកម្លាំងកំហែងដើម្បីជីកដីដែរ ។ ជួនកាលពេលព្រឹកឡើង យើងឃើញឆ្កែចចកកាយយកសកសពហែកស៊ីក៏មានដែរ ។

## ឈ្លបយកពុកទៅទុកនៅទួលភ្នង

ខ្ញុំមានវិប្បដិសារីចំពោះកំហុសដែលខ្ញុំធ្វើមិនគប្បីចំពោះប៉ា ។ ថ្ងៃមួយ ខ្ញុំ និងប្អូនខ្ញុំ អាញ៉ យកមុងនីឡុងធ្វើជាមងអូសកូនត្រី និងកំពឹសនៅខាងក្រោយភូមិដើម្បីយកមកស្ងហូបបន្ថែមលើរបបដែលចុងភៅចែកឲ្យ ។ នៅពេលនោះ យើងទាំងអស់គ្នាមានការពិបាកក្នុងការស្វែងរកម្ហូបណាស់ ព្រោះមនុស្សម្នាក់ៗអត់ឃ្លាន ហើយខិតខំដើរស្វែងរកអាហារគ្រប់គ្នាដែរ ។ ពីរនាក់បងប្អូនខ្ញុំខំប្រឹងអូសមងទាំងខ្លួនស្គមកំព្រឹង ពេលនោះខ្ញុំមើលមុខប្អូនខ្ញុំ អាញ៉ ដែលត្រាំទឹកយូរទៅខ្លួនវាឡើងស្លាំងរកឈាមគ្មាន ហើយទម្រង់មុខរបស់វាស្រដៀងទៅនឹងក្បាលខ្មោចដូច្នេះដែរ ខ្ញុំស្តូកក្នុងចិត្តខ្លាំងណាស់ព្រោះអាណិតប្អូន ។ ចៃដន្យល្អ មានកង្កែបមួយគូយ៉ាងធំចូលក្នុងមងយើង ខ្ញុំលើកមងឡើងផុតពីទឹករួចក្តោបយកឡើងលើគោក បន្ទាប់មកយើងប្រញាប់ប្រញាល់យកវាមកឲ្យប៉ាម៉ាក់ចាត់ចែងស្ល ។ ខ្ញុំ និង អាញ៉ សុំយកស្បែកកង្កែបម្នាក់មួយទៅដាក់ហាលថ្ងៃដើម្បីទុកហូបទៀត ។ ស្អែកឡើង ពេលខ្ញុំត្រឡប់មកពីកងកុមារវិញ ឃើញបាត់ស្បែកកង្កែបមួយ ចំណែកប៉ាប្រាប់ថាគាត់យកពិសាអស់ហើយ ពេលនោះខ្ញុំខឹងនឹងប៉ាជាខ្លាំង រួចហើយរអ៊ូរទាំរហូតធ្វើឲ្យប៉ាមួម៉ៅរត់ដេញវាយខ្ញុំ ។ បន្ទាប់មក ប៉ាបានរអិលជើងដួលផ្កាប់មុខទៅនឹងដី ធ្វើឲ្យគាត់ឈឺចាប់យ៉ាងខ្លាំង ។ នៅក្នុងឆ្នាំដដែលនោះ ខ្ញុំលែងបានជួបមុខប៉ារហូត ព្រោះពេលល្ងាចមួយនោះ ប្រធានក្រុមបានមកប្រាប់ឲ្យប៉ារៀបចំខ្លួនដើម្បីទៅដាំដំឡូង ។ ខ្ញុំឃើញផ្ទាល់ភ្នែក នៅពេលនោះប៉ាបានពាក់មួកស្លឹកត្នោត លីចបកាប់មួយ និងស្ពាយបង្វេចខោអាវ រួចដើរចេញទៅបាត់ ។ ក្រោយមក ក្មេងៗក្នុងភូមិវាចំអកឲ្យខ្ញុំថា «ឪអ្អែងគេយកទៅដាំដំឡូងនៅទួលភ្នង» ព្រោះទួលភ្នងជាកន្លែងដែលខ្មែរក្រហមយកមនុស្សទៅសម្លាប់ ហើយក៏ជាកន្លែងដែលឈ្លបយកបងខ្ញុំ និងក្មួយៗខ្ញុំទាំងបីនាក់ទៅសម្លាប់នៅទីនោះដែរ ។

## ព្រលឹងវិលវល់

បងប្អូនខ្ញុំទាំងអស់បានក្លាយទៅជាក្មេងកំព្រាឪពុកចាប់តាំងពីពេលនោះមក ។ ពេលនោះ នៅក្នុងភូមិខ្ញុំលែងឃើញមនុស្សប្រុសជម្លៀសមកពីទីក្រុងទៀតហើយ ព្រោះខ្លះបានស្លាប់ដោយអត់បាយ និងខ្លះទៀតត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ ។ គ្រួសារខ្ញុំនៅសល់តែគ្នា៦នាក់ប៉ុណ្ណោះក្នុងចំណោម១៤នាក់ពេលដែលចេញមកពីភ្នំពេញ ។ ចំណែកបងជីដូនមួយ បងរិតត្រូវកងទ័ពខ្មែរក្រហមចាប់បានយកទៅសម្លាប់ចោល ព្រោះគាត់



ក្រុមគ្រួសាររបស់ ថៃ ច័ន្ទរិទ្ធ

រត់គេចចេញពីកងចល័តក្នុងគោលបំណងភៀសខ្លួនទៅទល់ដែនដើម្បីគេចចេញពីការអត់ឃ្លាន និងការងារធ្ងន់ធ្ងរ ។ បងរិត បានមកពន្យល់សប្តិម៉ាក់ ឲ្យម៉ាក់ទៅជួយគាត់ផង ព្រោះគាត់ត្រូវគេអារសាច់ វះពោះឈឺផ្សាខ្លាំងណាស់ ។ ក្រោយមក យើងមិនដែលបានទទួលដំណឹងពីគាត់ទេ ។ ក្នុងឆ្នាំនោះ ជីវិតរបស់យើងខ្លោចផ្សាខ្លាំងណាស់ ម្នាក់ៗខំត្រដររស់យ៉ាងវេទនាជាទីបំផុត ។ ម៉ាក់ប្រាប់ខ្ញុំឲ្យដើរបេះស្មៅពុកមាត់បង្កងយកមកស្ងោរហូបដោយ

សូម្បីតែអំបិលក៏គ្មានបង់ក្នុងសម្លដែរ ។ ម៉ាក់ដឹងពីការរស់នៅស្រុកចម្ការនិងបេះស្លឹទ្រាំខ្លាំងណាស់ព្រោះគាត់ជាកូនកសិករធ្លាប់រស់នៅចម្ការ ដូច្នេះគាត់អាចទ្រាំទ្រការអត់ឃ្លាននិងការងារលំបាកបានច្រើន ។ ជួនកាលក្រោយពេលធ្វើការងារចប់ ម៉ាក់បាននាំទៅគោះស្រងែយកមកលីងឲ្យស្រួយ ហើយបុកឲ្យម៉ដ្ឋទំពាហូបគ្រាន់បានឆ្អែតមួយពេល ។ ចំណែកបបររបស់ចុងភៅវិញរកគ្រាប់អង្ករមិនឃើញទេ ព្រោះក្នុងមួយខ្ទះធ្លោតគេដាក់អង្ករតែបីកំប៉ុងទឹកដោះគោ



ប៉ុណ្ណោះសម្រាប់មនុស្ស៣៥នាក់ ។ ដូច្នេះ អ្នកដែលអត់ឃ្លានខ្លាំងត្រូវដើរបេះស្លឹកឈើបុស្មៅស្លាបទាមកហូបបន្ថែមទៀត ។

តាំងពីតូចមកខ្ញុំដូចជាមានគ្រូបាធ្យាយតាមថែរក្សាខ្ញុំ ព្រោះរាល់ពេលដែលមានរឿងគ្រោះថ្នាក់កើតឡើង ខ្ញុំតែងយល់សប្តិឃើញមុនជានិច្ច ។ នៅពេលយប់មួយនោះ ពេលដេកលក់ ខ្ញុំបានយល់សប្តិឃើញថាបានហែលកាត់ស្ទឹងស្មោងដែលស្ថិតនៅចំពីមុខផ្ទះខ្ញុំ ប៉ុន្តែនៅពេលខ្ញុំហែលដល់ពាក់កណ្តាលស្ទឹងក៏ទន់ដៃជើងរកកលនឹងលង់ ស្រាប់តែពេលនោះមានបាច់ត្រកួនមួយយ៉ាងធំអណ្តែតមក ខ្ញុំស្រវាចាប់តោង ហើយបណ្តែតខ្លួនមកដល់ត្រើយម្ខាង ។ ចាប់តាំងពីពេលខ្ញុំយល់សប្តិមក ក្រុមចុងភៅបានចាត់តាំងមនុស្សទៅដកត្រកួនពីស្រែក្រោមមកស្លឲ្យអ្នកនៅក្នុងភូមិហូបជារៀងរាល់ថ្ងៃ ។ នៅទីនោះចុងភៅបេះយកតែខាងចុងខ្ចីៗប៉ុណ្ណោះ ចំណែកខាងគល់រឹង និងមានឫស គេបោះចោល ។ ខ្ញុំក៏ទៅរើសយកមកឲ្យម៉ាក់កាត់ជាកង់តូចៗ រួចហើយស្ងោរទុកលាយជាមួយនឹងបបរហូប ។ ក្នុងឆ្នាំនោះ ខ្ញុំនិងបងប្អូនហូបតែគល់ត្រកួនប៉ុណ្ណោះ ប៉ុន្តែអាចរស់ជីវិតរហូតដល់រដូវច្រូតកាត់ស្រូវវិញ ។

## ខែខ្មីតកើតទុក្ខ

រំពឹកពីក្មេងៗកូនអ្នកស្រុកស្អប់ខ្ញុំ និងរង់ចាំឱកាសធ្វើបាបខ្ញុំ ពេលខ្ញុំបាក់កម្លាំងដោយសារអត់អាហារ ។ នៅយប់ខែភ្លឺមួយ ខ្ញុំដេកមិនលក់សោះហាក់ដូចជាមានអ្វីមកប្រាប់ឲ្យខ្ញុំចុះក្រោមផ្ទះ ហើយដើរសំដៅទៅមាត់ស្ទឹងនៅខាងមុខផ្ទះ ។ ពេលនោះខ្ញុំគ្មានអារម្មណ៍ភ័យខ្លាចទេ ខ្ញុំក៏អង្គុយលើឫសដើមអម្ពិលដូរដែលដុះលយទៅមាត់ស្ទឹងដើម្បីសម្លឹងមើលទឹកស្ទឹងដែលចាំងផ្លាតដោយសារពន្លឺព្រះខែ ។ នៅពេលនោះ ស្រាប់តែខ្ញុំឮសំឡេងក្មេងប្រុសម្នាក់ស្រែកសួរពីខាងក្រោមផ្ទះថា «អាតួ! នៅទេឲ្យវាចុះដីមក» ។ ខ្ញុំក្រឡេកទៅឃើញអាម្នាក់ដែលស្រែកសួរនោះឡើងលើកាំជណ្តើរទៅរកម្តាយខ្ញុំ ចំណែកខាងក្រោមផ្ទះមានក្មេងពីរបីនាក់ទៀតពួននៅតាមដើមសសរ ។ ឮដូច្នេះ ម្តាយខ្ញុំក៏ប្រាប់វាថា «វាចេញទៅក្រៅបាត់ហើយ» ។ យប់នោះ ខ្ញុំនៅឆ្ងល់ថាពេលនោះខែភ្លឺច្បាស់ហេតុអ្វីវាមើលមិនឃើញខ្ញុំអង្គុយនៅនឹងគល់អម្ពិលចម្ងាយប្រមាណតែ២០ម៉ែត្រប៉ុណ្ណោះពីមុខផ្ទះ ។ ក្រោយមក មានក្មេងម្នាក់មកចំអកឲ្យខ្ញុំ ថាខ្ញុំ «អាតួ! អែ្ហងហេងហើយ កុំអីថ្ងៃមុនអែ្ហងទៅដាំដំឡូងនៅទួលភ្លូងជាមួយឪអែ្ហងមិនខាន» ។ ក្រោយមក ពេលខ្ញុំចេញទៅវាលស្រែខាងក្រោយផ្ទះ ស្រាប់តែមានក្មេងម្នាក់បេះតែដើរតាមខ្ញុំពីក្រោយ ខ្ញុំនឹកក្នុងចិត្តថាវាមុខជាមានបំណងអ្វីមិនល្អមកលើខ្ញុំហើយ ។ ខ្ញុំដើរបណ្តើរ ងាកក្រោយបណ្តើរខ្លាចក្រែងវាលបវាយខ្ញុំពីក្រោយ ហើយពេលខ្ញុំដើរគេ្លចខ្លួនមួយភ្លែតស្រាប់តែនៅក្បាលខ្ញុំផ្នែកខាងក្រោយឮសូរផសខ្ញុំងាកក្រោយយកដៃស្ទាបក្បាលដឹងថា វាយកចម្ពាមបាញ់ក្បាល

ខ្ញុំ ។ ខ្ញុំទប់ស្មារតីរួចរត់ដេញវាពីក្រោយ ប៉ុន្តែខ្ញុំដេញវាពុំទាន់ទេ ព្រោះខ្ញុំមិនមានកម្លាំង ។ ពេលនោះ ក្បាលខ្ញុំឡើងហើម និងឈឺចាប់ដោយសារត្រូវនឹងគ្រាប់ដីលញ់ ។

ជីវិតខ្ញុំពេលនោះកាន់តែលំបាក ព្រោះប្រធានកងបានបំបែកខ្ញុំចេញពីម្តាយឲ្យទៅរស់នៅជាមួយកងកុមារ ។ ពេលខ្ញុំមកដល់ដំបូង ក្មេងៗអ្នកស្រុកមិនហ៊ានគស៊ូជាមួយខ្ញុំទេ ឥឡូវនេះក្រុមវាធ្វើបាបខ្ញុំស្ទើររាល់ព្រឹក ដោយចាប់ខ្ញុំសែង រួចបោះទៅក្នុងទឹកស្រះធ្វើឲ្យខ្ញុំរងាញ័រញាក់ពេលខែរងា ។ ប៉ុន្តែ ខ្ញុំមិនហ៊ានតបតនឹងវាទេ ព្រោះខ្លាចគេធ្វើបាបកាន់តែខ្លាំង ។ ថ្ងៃមួយ ពេលរដូវស្រូវដាក់គ្រាប់ ប្រធានកងឲ្យខ្ញុំដើរតាមភ្លឺស្រែមើលចាបកុំឲ្យស៊ីស្រូវដោយសារតែសេចក្តីស្រេកឃ្លានខ្ញុំយកដៃបូតស្រូវដែលទើបនឹងដាក់ទឹកដោះប្រមាណដប់គ្រាប់ស្រាប់តែក្មេងអ្នកមូលដ្ឋានឃើញក៏ទៅប្រាប់ឈ្លបមកចាប់ខ្ញុំចងស្លាបសេក រួចវាយទាត់ធាក់រហូតដួលផ្កាប់មុខ ទើបយកខ្ញុំទៅដាក់ឃុំក្នុងវត្តក្រសាររង់ចាំដល់ពេលយប់នឹងយកខ្ញុំទៅសម្លាប់ ។ ប៉ុន្តែសំណាងល្អ ពេលឈ្លបកំពុងបណ្តើរខ្ញុំ ស្រាប់តែពូម្នាក់ឈ្មោះ ឌុត ឃើញ ខ្ញុំ ហើយគាត់ក៏ទៅនិយាយជាមួយនឹងឈ្លបសុំយកខ្ញុំឲ្យទៅជួយរែកទឹកស្រោចបន្លែសម្រាប់ផ្គត់ផ្គង់ចុងភៅ ទើបខ្ញុំបានរួចរស់ជីវិតចាប់ពីពេលនោះមក ។

## ទឹកត្នោតខែប្រាំង

ពេលរដូវដាំបន្លែកន្លងផុតទៅ ប្រធានកងដាំបន្លែបញ្ជូនខ្ញុំមកឲ្យរែកទឹកចាក់ខ្ទះដាំឲ្យពួកអ្នកភូមិហូប ។ ខ្ញុំត្រូវរែកទឹកឡើងប្រាំងពីស្ទឹងមកចាក់ខ្ទះ និងពាងមួយថ្ងៃៗរាប់រយដើងដែលពេលនោះខ្ញុំមានវ័យ១៨ឆ្នាំប៉ុណ្ណោះ ដែលជាវ័យត្រូវចូលសាលារៀន ។ ប៉ុន្តែទោះបីខ្ញុំធ្វើការងារធ្ងន់ធ្ងរបែបនោះក៏ដោយ ក៏ខ្ញុំហាក់មានសំណាងជាងអ្នកភូមិដទៃដែរព្រោះខ្ញុំបានហូបឆ្អែត ។

ក្រោយមក នៅខែប្រាំង ពូសាម ប្រធានកងបានបន្ថែមការងារឲ្យខ្ញុំជួយរែកទឹកត្នោតយកទៅចាក់ខ្ទះរម្ងាស់ស្ករដែលធ្វើឲ្យខ្ញុំកាន់តែមានឱកាសល្អ និងមានកម្លាំងខ្លាំង ដោយសារមានជាតិស្ករក្នុងខ្លួនដែលកន្លងមកខ្ញុំពុំដែលបានស្គាល់សោះឡើយ ។ ថ្ងៃមួយ ខ្ញុំរែកស្ករកាត់វត្តក៏ជួបនឹងបែស្រីដែលមានដំបៅជើងត្រូវប្រធានភូមិបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យស្ថិតនៅក្នុងបរិវេណវត្ត ហើយខ្ញុំក៏លួចឲ្យគាត់ដឹកខ្លះដើម្បីឲ្យគាត់មានកម្លាំងកំហែងឡើងវិញ ។ តាមពិតទៅពេលនោះ ពូសាម ដឹងពីរឿងនោះដែរ ប៉ុន្តែដោយសារគាត់ជាមនុស្សមានចិត្តធម៌ក៏ចេះតែធ្វេចភ្នែកធ្វើមិនដឹងមិនឮទៅ ។

រាល់ថ្ងៃ ក្រៅពីរែកទឹកចាក់ខ្ទះចុងភៅនិងរែកទឹកត្នោតផងខ្ញុំក៏ជួយរែកទឹកដាក់ផ្ទះ ពូសាម ដែរ ព្រោះខ្ញុំនៅជាមួយនឹងគាត់ ។ យប់មួយពេលខ្ញុំដេករៀបលក់ទៅហើយ ស្រាប់តែឮ ពូសាម និយាយប្រាប់ប្រពន្ធគាត់ថា បងអាណិត អាមុំ (បងខ្ញុំ) ណាស់ព្រោះកាលពីថ្ងៃមុនត្រូវកងឈ្លបវាយដំធ្វើបាប និងបម្រុងយកទៅសម្លាប់ចោល ដោយចោទវាថាលួចគ្រាប់គនៅពេលយប់ហើយបងក៏ទៅជួយនិយាយសុំលើកទោសឲ្យវាដែរ កុំអីឈ្លបយកទៅសម្លាប់បាត់ហើយ ។ ពេលនោះ ប្រពន្ធ ពូសាម លាន់មាត់ថា «អើ! បងជួយ អាមុំ ផងទៅ» ។ ខ្ញុំគិតក្នុងចិត្តថា ពូសាម និងប្រពន្ធគាត់យកចិត្តទុកដាក់ និងអាណិតអាសូរបងប្អូនខ្ញុំ ដូច្នេះខ្ញុំបានរស់នៅជាមួយគាត់តទៅទៀត ។

## ខ្ញុំមានកំហុសអ្វី?

ខ្ញុំបានហូបឆ្អែតតែមួយរយៈពេលប៉ុណ្ណោះ ស្រាប់តែថ្ងៃមួយ ពូសាម មកប្រាប់ខ្ញុំឲ្យទៅនៅជាមួយម្តាយវិញចុះ ធ្វើខ្ញុំស្លុតចិត្ត ហើយភ័យខ្លួន ដោយមិនដឹងថាតើខ្ញុំធ្វើអ្វីខុសបានជាគាត់មិនឲ្យខ្ញុំនៅតទៅទៀត ។ ពូសាម បានយក អាជា (វាធ្លាប់វាយជាមួយខ្ញុំកាលពីមកដល់ស្ពានដំបូង ហើយខ្ញុំវាយសង្កត់កវារហូតយំ) មកនៅនិងធ្វើការជំនួសខ្ញុំវិញ ។ ខ្ញុំពុំដឹងពីមូលហេតុអ្វីបានជាពូសាម ដេញខ្ញុំចេញទេ ។ ជីវិតខ្ញុំត្រូវលំបាក និងជួបឧបសគ្គថ្មីទៀតជាមិនខាន ។ មិនយូរប៉ុន្មាន ខ្ញុំត្រូវជួបការស្រេកឃ្លានយ៉ាងខ្លាំងរហូតស្ទើរតែដើរមិនរួច ហើយស្ទើរដើរទាក់នឹងស្មៅចិញ្ចៀនក៏ខ្ញុំដួលផ្កាប់មុខទៅនឹងដីយ៉ាងងាយស្រួលដែរ ។ អ្វីក៏ដោយឲ្យតែស៊ីកើត ខ្ញុំស៊ីទាំងអស់សូម្បីតែស្លឹកឈើស្មៅក៏ខ្ញុំបេះស៊ីដែរ ។ ថ្ងៃមួយ ខ្ញុំរើសបានដំឡូងមីមួយដុំប៉ុនមេជើង ខ្ញុំអរណាស់យកទៅដុតនៅលើផ្នុះស្រាប់តែចៃដន្យអាក្រក់ខ្ញុំរបូតជ្រុះពីដៃធ្លាក់ទៅដី ។ ពេលនោះមាន់ចឹកពាំយកទៅ ខ្ញុំខំដេញមាន់ដើម្បីដណ្តើមយកមកវិញ ប៉ុន្តែវាមិនព្រមទម្លាក់ចោលសោះ ហើយរត់គេចយ៉ាងលឿនខ្ញុំរើសដុំឈើមួយដុំគប់តម្រង់វាទើបវាទម្លាក់ចោល ។ ខ្ញុំអរណាស់

ហើយទៅរើសយកដំឡូងនោះលាងទឹកហូបវិញ ។ ក្រោយពីប៉ា និងបងប្អូនខ្ញុំស្លាប់ទៅ ម៉ាក់ខំធ្វើការទាំងឈឺទាំងជា ដើម្បីកុំឲ្យប្រធានភូមិរាយការណ៍យកទៅសម្លាប់ ។ ក្រោយពីធ្វើការចប់ ម៉ាក់ខំដើរស្វែងរកស្លឹកឈើ ឬក៏បន្លែអ្វីដែលអាចហូបបានដូចជា គល់ល្ហុងដែលអ្នកស្រុកគេបោះចោល ។ ថ្ងៃមួយ ពេលម៉ាក់បានគល់ចេកមួយដុំមកទុកស្ងោរលាយជាមួយនឹងទឹកបបរ ខ្ញុំក៏លួចចិតមួយដុំមកដុតហូប ពេលនោះម៉ាក់ឃើញក៏យកផ្តៅវាយត្រូវខ្នងដៃខ្ញុំរបកស្បែកចេញឈាមសម្លាករហូតដល់សព្វថ្ងៃនេះ ។

## អារ៉ូឡើងធំ

ខែវស្សាកន្លងទៅចូលដល់រដូវច្រូតកាត់ដំបូង ខ្ញុំខំដើររកមើលអ្វីដែលអាចហូបបានរហូតដល់មន្ទីរធ្វើការរបស់កម្មាភិបាលខ្មែរក្រហម ក៏ឃើញរទេះដឹកស្រូវមួយដែលដឹកស្រូវមកចាក់លើកម្រាលកន្ទេលនៅក្បែរនោះ ។ គ្រាប់ស្រូវខ្លះធ្លាក់កប់ក្នុងដី ដែលមើលទៅហាក់ពុំមានឃើញមានគ្រាប់ស្រូវទេ ហើយចៃដន្យខ្ញុំឃើញ អារ៉ូ ជាកូនរបស់មីង សរ ម្ចាស់ផ្ទះដែលខ្ញុំនៅជាមួយនៅទីនោះ ។ ពេលមុននោះ អារ៉ូ ជាមនុស្សស្លូតបូតទេ ប៉ុន្តែក្រោយពីខ្មែរក្រហមយកវាទៅអប់រំ អារ៉ូ ក៏ក្លាយជាមនុស្សផ្សេងទៅវិញ ព្រោះពេលវាឃើញខ្ញុំកើបដីក្បែរនោះមកផ្លុំចេញដើម្បីស្រង់យកគ្រាប់ស្រូវ វាបានយល់ព្រមឲ្យខ្ញុំកើបដី ។ ប៉ុន្តែពេលខ្ញុំប្រមូលបានគ្រាប់ស្រូវប្រមាណមួយហោប៉ៅអាវស្រាប់តែវាចោទខ្ញុំថា «ខ្មាំងលួចស្រូវរបស់អង្គការ រួចក៏ចាប់ខ្ញុំយកទៅដាក់ទណ្ឌកម្មដោយឲ្យបែនស្រូវនៅក្នុងមន្ទីរនោះ» ។ នៅពេលកំពុងបែនស្រូវ កូនអ្នកស្រុកម្នាក់ដែលពីពេលមុនតែងតែចង់ធ្វើបាបខ្ញុំ ក្រឡេកឃើញខ្ញុំក៏លាន់មាត់ថា «អូ! អាត្លួ» រួចវាដើរមកវាយខ្ញុំ ធ្វើឲ្យខ្ញុំគេចផង រត់ផង ប៉ុន្តែវាយខ្ញុំពុំត្រូវ ។ ខ្ញុំគិតក្នុងចិត្តថា បើមិនបណ្តោយឲ្យវាវាយត្រូវទេមុខជាខឹងខ្ញុំខ្លាំងមិនខាន ។ ពេលនោះ ខ្ញុំក៏ងើយមុខឲ្យវាវាយ ប៉ុន្តែចៃដន្យអាក្រក់ដៃវាវាយមកត្រូវនឹងធ្មេញខ្ញុំចេញឈាម ចំណែកវាក៏ឈឺដៃដែរ ។ វាខឹងខ្ញុំខ្លាំងណាស់ រួចក៏ស្ទុះចេញទៅក្រៅ ហើយឮសូរម៉ាស៊ីនរោទ៍ឡើង ធ្វើឲ្យខ្ញុំនឹកឃើញភ្លាមថាវាទៅបញ្ឆេះម៉ាស៊ីនភ្លើងដើម្បីឆក់ខ្ញុំ ភ្លាមនោះខ្ញុំក៏គេចខ្លួន ។ ពេលមកដល់មាត់ទ្វារក្រោយក៏ជួបនឹងមីងម្នាក់ជាកូនចៅចិនដែលមកពីទីក្រុងភ្នំពេញដែរបានឃាត់ខ្ញុំថា «គេចទៅ បើគេចាប់បាន គេនឹងយកទៅសម្លាប់ហើយ» ។ ខ្ញុំគិតភ្លាមថា «ទោះបីមិនគេច ក៏គង់តែយប់នោះក្រុមវានឹងយកខ្ញុំទៅវាយចោលជាមិនខាន» ។ គុណបុណ្យទឹកដោះម្តាយថ្លៃ ខ្ញុំក៏ចុះទៅទឹកក្នុងស្ទឹងដែលស្ថិតនៅខាងក្រោយមន្ទីរ ហើយខ្ញុំត្រាំក្នុងទឹកស្ទឹងក្រោមគុម្ពព្រៃរហូតដល់ព្រលប់ ទើបលូនតាមមាត់ស្ទឹងស្មោងដើម្បីគេចពីទីនោះ ។ ពេលនោះ ខ្ញុំឮសំឡេងកងឈ្លបស្រែកថា «បាត់ខ្មាំងម្នាក់ហើយ រ៉ៃយជួយរកគ្នា» ខ្ញុំភ័យខ្លាំង ណាស់រួចក៏ខំសម្ងំក្នុងស្ទឹងមិនហ៊ានកម្រើកទេ ទោះបីជារងាញ័រញាក់យ៉ាងណាក៏ដោយ ។ ខ្ញុំឮសំឡេងកងឈ្លបជិះសេះតាមរកខ្ញុំ ។ បន្ទាប់ពីកងឈ្លបចេញទៅផុតអស់ ខ្ញុំបានរត់ទៅរកចៃស្រី ។ ពេលឃើញប្អូនភិតភ័យដូច្នេះ គាត់ក៏រំលែកបបរដែលកងចល័តចែកឲ្យមកខ្ញុំហូបខ្លះ ។ ស្អែកឡើង ទើបខ្ញុំលួចមកកងកុមារវិញ ។

## បងស្លាប់អត់បាយ

អ្វីដែលធ្វើឲ្យខ្ញុំខ្លោចផ្សាក្នុងចិត្តទៀតនោះ គឺបងស្រីទីបី ឈ្មោះ បងពៅ ដោយសារកាយសម្បទាមិនល្អ សុខភាពមិនមាំទាំ ធ្វើឲ្យគាត់ឈឺបាក់កម្លាំងដើរមិនរួច ។ ថ្ងៃមួយខ្ញុំឃើញ បងពៅ លាក់លៀមនឹងយើង ពេលម៉ាក់ឈ្លេចសួរទើបដឹងថា គាត់លបចាប់បានជីងចក់មួយមូរក្នុងចង្កេះសំពត់បម្រុងនឹងដុតហូប ដោយសារគាត់ឃ្លានខ្លាំងពេក ។ ក្រោយមកទៀត បងពៅ យកព្រ័ត្រស្បែកក្របីដែលពុំដឹងជាសល់ពីឆ្នាំណាមកដាក់ស្ងោរស៊ី ប៉ុន្តែម៉ាក់ហាមឃាត់ព្រោះស្បែកក្របីនោះស្ងោរមិនផុយទេ ។ ខ្ញុំដឹងថាបងខ្ញុំឃ្លានខ្លាំងណាស់ ។ ដល់រដូវច្រូតកាត់ទៅហើយ បងពៅ ឈឺកាន់តែធ្ងន់ទៅៗ ពេលនោះម៉ាក់បានស្រូវមួយកំប៉ុងមកបុកនឹងត្បាល់ដើម្បីដាំបាយឲ្យកូនហូប ។ ប៉ុន្តែអនិច្ចា បងពៅ បានត្រឹមតែឃ្លានប៉ុណ្ណោះ ព្រោះពេលនោះគាត់ខ្សោយណាស់ទៅហើយ ។ បងពៅ ក៏ដណ្តប់ភួយសម្ងំដេកទៅ ។ រហូតព្រឹកឡើង ពេល ម៉ាក់ដាស់គាត់ឲ្យក្រោកឡើងទើបដឹងថាកូនស្លាប់បាត់ទៅហើយ ហើយក៏មិនដឹងស្លាប់ចាប់តាំងពីថ្មើរណាដែរ ព្រោះសាកសពឡើងរឹងទៅហើយ ។ ពេលនោះ ប្រធានភូមិបានហៅម៉ាក់ឲ្យទៅច្រូតស្រូវនៅវាលខាងក្រោយភូមិ ទោះបីម៉ាក់សុំយកកូនទៅកប់ក៏គេមិនយល់ព្រមដែរ ។ ម៉ាក់ដើរបណ្តើរសម្លឹងមើលខ្មែរក្រហមសែងបងស្រីខ្ញុំយកទៅកប់បណ្តើរ ហើយគាត់ក៏ប្រាប់ឲ្យខ្ញុំទៅតាមមើលខ្មោចបង

តើគេយកទៅកប់ឯណា ។ ខ្ញុំដើរតាមមើលខ្មែរក្រហមយកទៅកប់ នៅក្រោយភូមិក្រោមដើមត្រសេកមួយដើម ដោយគេជីកដី ជម្រៅត្រឹមជង្គង់ល្មមតែដាក់សពចុះប៉ុណ្ណោះ ។ ខ្ញុំបានត្រឹមតែ ឈរមើល ប៉ុន្តែពុំអាចធ្វើអ្វីបានឡើយ ទោះបីដឹងថារណ្តៅនោះ រាក់អាចឲ្យឆ្កែចចកកាយស៊ីក៏ដោយ ។ មួយថ្ងៃក្រោយមក ខ្ញុំដើរ កាត់ផ្លូវបងស្រី ខ្ញុំក៏ឃើញផ្លូវឡើងប៉ោងនិងធុំក្លិនជះមកក្រៅព្រោះ កប់រាក់ពេកនៅទីទួលមួយក្រោយភូមិដែលពោរពេញដោយ រណ្តៅកប់សពត្រូវឆ្កែចចកកាយយកសពហែកស៊ីទាញចេញមក ក្រៅដោយសារខ្មែរក្រហមកប់សពរាក់ពេក ។ នៅពេលនឹកឃើញ រឿងនេះឡើង ខ្ញុំនឹកអាណិតអាសូរ បងពៅ ខ្លាំងណាស់ ។

### ខ្មោចតាប៉ូលង

ដោយសារស្រេកឃ្លានខ្លាំងពេក ខ្ញុំដើរគ្រប់ទីកន្លែងដើម្បី រកអ្វីដែលអាចស៊ីបានទោះយប់ថ្មើរណាក៏ដោយ ។ ខ្ញុំដើរកាត់ទីទួល កប់ខ្មោចពេលយប់តែម្នាក់ឯង តែខ្ញុំហាក់ដូចជាពុំមានអារម្មណ៍ ខ្លាចខ្មោចឡើយ ។ ថ្ងៃមួយម៉ោងប្រមាណជាប្រាំបួនយប់ទៅហើយ ខ្ញុំដើរកាត់វាលស្រែរួចឆ្លងកាត់ទួលដើមពោធិ៍ដែលឈ្លបខ្មែរ ក្រហមទើបយកខ្មោចទៅកប់ថ្មីៗដើម្បីឆ្លងមកក្រោយភូមិ ស្រាប់ តែមកជិតដល់ភូមិ ខ្ញុំឃើញឆ្មាមួយពណ៌សធំប៉ុនឆ្កែកម្ពស់ត្រឹមភ្លៅ មនុស្សរួចរាស់រត់កាត់មុខខ្ញុំចូលទៅក្រោមដើមក្រសាំង រួចស្រែក ម៉េវយ៉ាងខ្លាំង ហើយក៏បាត់ស្រមោលនៅក្រោមដើមក្រសាំង នោះទៅ ។ ខ្ញុំក៏បេះតែដើរមកទៀត មកដល់កាំជណ្តើរមុខផ្ទះ ខ្ញុំហាក់ដូចជាមានអារម្មណ៍ព្រឺសម្បុរ រួចគិតក្នុងចិត្តថា ក្នុងភូមិនេះ ពុំដែលឃើញមានឆ្មាអ្នកស្រុកណាទេព្រោះតាមដឹងត្រូវប្រជាជន ចាប់ស៊ីអស់ហើយ ហើយប្រសិនបើជាឆ្មាមែន ក៏ពុំមានប៉ុនឆ្កែដែរ ហើយក៏ពុំមានឆ្មាណាសម្បុរសអ៊ីចឹងដែរ ។ ពេលនេះខ្ញុំក៏ចាប់ផ្តើម ភ័យញ័រ រួចស្ទុះឡើងកាំជណ្តើររត់ទៅរកម៉ាក់ ហើយឃ្មុំភួយយ៉ាង ជិតសម្ងំដេកទៅ ។ ស្អែកឡើង ទើបខ្ញុំនឹកឃើញថា ពិតជាខ្មោច តាប៉ូ លងខ្ញុំហើយ ព្រោះអីកាលពីប៉ុន្មានខែមុននេះ តាប៉ូ ត្រូវ ឈ្លបខ្មែរក្រហមយកទៅដុតនៅក្រោមដើមក្រសាំងនោះ ។

### រងគ្រោះព្រោះគំនុំ

ជីវិតខ្ញុំបេះតែទៅមុខយ៉ាងលំបាក ពេលល្ងាចថ្ងៃមួយខ្ញុំពុំ បានទៅកងកុមារទេ ។ ខ្ញុំបានយកកូនធុងមួយទៅវាលស្រែរកបាច ត្រី ពេលនោះខ្ញុំបានប្រទះឃើញថ្លុកស្រែមួយមានត្រីច្រើនក៏ចុះ ទៅចាប់បានកូនត្រី និងកំពឹសច្រើនណាស់ ។ ខ្ញុំត្រេកអរខ្លាំងណាស់ រួចក៏ប្រញាប់ត្រឡប់មកផ្ទះវិញ ។ ម៉ោងប្រមាណជាប្រាំល្ងាចទៅ ហើយ ម៉ាក់ដាក់បបរជាមួយនឹងកូនត្រីនិងកំពឹសដែលខ្ញុំចាប់បាន ។ ខ្ញុំឃ្លានខ្លាំងណាស់នឹកថានឹងបានឆ្ងាញ់មាត់ម្តងហើយ ព្រោះមួយ ឆ្នាំហើយពុំដែលបានរសជាតិត្រីស្រស់បែបនេះហូបទេ ។ ពេល បបរឆ្អិន ម៉ាក់លើកដាក់មកលើរនាបរួចយកចានដួសចែកឲ្យកូន (ខ្ញុំពុំចាំពេលនោះមានអ្នកណានៅជាមួយខ្លះទេ) ហើយខ្ញុំយក ស្លាបព្រាដួសបបរមកផ្លុំបម្រុងនឹងដាក់ចូលទៅក្នុងមាត់ទៅហើយ ស្រាប់តែមានក្មេងៗពីរបីនាក់មកដល់មុខផ្ទះ រួចស្រែកហៅខ្ញុំឲ្យចុះ ក្រោម ។ ពេលចុះមកដល់ដីស្រាប់តែវាវាត់ខ្ញុំជាមួយនឹងខ្សែតី សម្រាប់វាយគោ និងទាត់ធាក់ខ្ញុំនៅនឹងមុខម្តាយខ្ញុំ រួចហើយវា អូសខ្ញុំយកទៅចងស្លាបសេកនៅពីមុខចន្ទល់រទេះគោ ។ នៅខាង មុខរទេះនោះក៏មានកូនរបស់ប្រជាជនថ្មីពីរបីនាក់ទៀត ដែលក្មេង មូលដ្ឋានទាំងនោះចាប់យកមកពីភូមិផ្សេងដែរ ។ ក្មេងៗមូលដ្ឋាន ទាំងនោះវាយខ្ញុំឲ្យរត់ពីមុខរទេះគោ ។ ខ្ញុំមិនដឹងថាពេលនោះក្នុង ចិត្តម្តាយខ្ញុំខ្លាចផ្សាយ៉ាងណានោះទេ ពេលគាត់ឃើញកូនត្រូវគេ វាយទាត់ធាក់ធ្វើបាបនៅនឹងមុខគាត់ ហើយគាត់ពុំអាចជួយបាន នោះ ។

មកដល់កន្លែងកងកុមារ ក្មេងៗទាំងនោះស្រាយយើងពី ចំណង ហើយវាឲ្យយើងបីនាក់វាយគ្នា បើអ្នកណាឈ្នះនឹងបានរួច ខ្លួន ខ្ញុំខិតខំប្រមូលកម្លាំងដើម្បីតស៊ូជាមួយនឹងក្មេងរងគ្រោះពីរ នាក់ទៀត ហើយទីបំផុតខ្ញុំបានផ្តួលក្មេងពីរនាក់នោះឲ្យចុះចាញ់ទាំង អស់ ។ តាមពិត ក្មេងមូលដ្ឋានទាំងនោះចង់ធ្វើបាបខ្ញុំជាងគេ ព្រោះ ខ្ញុំល្បីតាំងពីមកដល់ភូមិនេះដំបូងម្ល៉េះ ។ មិនដូចអ្វីដែលក្រុមវាបាន ប្រាប់ខ្ញុំទេ ព្រោះនៅពេលដែលខ្ញុំផ្តួលក្មេងពីរនាក់នោះរួចហើយ ស្រាប់តែក្រុមវានាំគ្នាឈរជារង្វង់ហើយលោតធាក់ខ្ញុំពីម្ខាង ទៅម្ខាង ដោយពេលនោះមានមេកងវាម្នាក់អង្គុយសើចយ៉ាង សប្បាយ ។ ខ្ញុំឈឺចុកចាប់ខ្លាំងណាស់ ព្រោះក្រុមវាទាត់ធាក់តាម អំពើចិត្ត រួចហើយវាយកធ្យូងបាតខ្ទះមកលាបមុខខ្ញុំថែមទៀត រហូតទាល់ តែម៉ាក់មកសំពះអង្វរវាទើបលែងធ្វើបាបខ្ញុំ ។

### ផែនការលួចស្រូវ

យើងរស់នៅវេទនាខ្លោចផ្សាខ្លាំងណាស់ ម្នាក់ៗស្គមសល់តែស្បែកដណ្តប់ឆ្អឹង ខ្លះក៏ហើមមុខ មាត់ ដៃ ជើង បាក់កម្លាំងស្លាប់ជារៀងរាល់ថ្ងៃ ។ មួយរសៀលក្នុងផុតទៅចូលដល់រដូវរំហើយ ស្រូវចាប់ផ្តើមទុំ ខ្ញុំនិងក្មេងៗក្នុងភូមិបាននាំគ្នាទៅលួចបូតស្រូវក្នុងស្រែក្រោយភូមិ ។ ពេលកំពុងបូតស្រូវ ស្រាប់តែមានទាហានខ្មែរក្រហមម្នាក់ដែលពួនឃ្លាំមើលនៅលើចុងត្នោតចុះមកចាប់យើងបានទាំងបួននាក់ ហើយឲ្យយើងអង្គុយជាជួរ រួចហើយសួរចម្លើយម្នាក់ម្តងៗ ។ ក្នុងចំណោមក្មេងៗទាំងនោះ មានតែខ្ញុំម្នាក់ប៉ុណ្ណោះជាកូនប្រជាជនថ្មី ក្រៅពីនោះកូនអ្នកមូលដ្ឋានទាំងអស់ ។ ភាសាអ្នកស្រុកនៅទីនោះរងឹនមិនដូចអ្នកនៅភ្នំពេញទេ ម៉្លោះហើយបើវាដឹងថាខ្ញុំជាអ្នកថ្មីវាមុខជាសម្លាប់ខ្ញុំជាមិនខាន ។ ដោយហេតុតែទេពកោសល្យពីកំណើត ខ្ញុំខិតខំនិយាយតាមរបៀបកូនអ្នកស្រុកម៉្លោះហើយធ្វើឲ្យទាហានខ្មែរក្រហមម្នាក់នោះ មិនអាចបែងចែកថាខ្ញុំជាកូនអ្នកថ្មីបានទេ ។ នៅទីបំផុត វាឲ្យខ្ញុំឱនរួចហើយវាយកដែកចុងកាំភ្លើងវាយយើងម្នាក់ៗប្រាំដងទើបព្រមដោះលែងឲ្យយើងត្រឡប់មកផ្ទះវិញ ។

ក្រោយមកទៀត ខ្ញុំនិងកូនអ្នកស្រុកបីនាក់ក៏បានរៀបចំផែនការលួចប្រូតស្រូវពេលយប់ ។ ពេលយប់ងងឹតមើលគ្នាពុំស្គាល់ យើងក៏នាំគ្នាចេញទៅដោយខ្ញុំដើរក្រោយគេបង្អស់ ចំណែកខាងមុខមាន អាខន នាំមុខ។ ទៅដល់ស្រែ យើងក៏ដើរតាមភ្លឺស្ងាបៗមិនមានអ្នកណាហ៊ានមាត់ឡើយ ដើរបានបន្តិចស្រាប់តែអាខន ឈប់រួចរាដៃមកក្រោយធ្វើជាសញ្ញាឲ្យឈប់ដោយនាំគ្នាក្រាបចុះទៅកៀនភ្លឺស្រែដើម្បីរង់ចាំស្តាប់មនុស្ស មួយសន្ទុះក្រោយមក ខ្ញុំបានឮសំឡេងមនុស្សប្រុសពីរនាក់ជជែកគ្នា នោះគឺជាទាហានខ្មែរក្រហមដែលទើបបញ្ជូនមកថ្មី ។ ពេលក្រុមវាដើរមកដល់កន្លែងយើងក្រាប ស្រាប់តែវាជាន់ចំកណ្តៀវរបស់ អាអៀបដែលវាភ្លេចយកចេញពីភ្លឺស្រែ ។ ទាហានម្នាក់នោះក៏លាន់មាត់ថា «ជាន់ដែកអ្វី» រួចហើយក៏ឈ្ងោកមើលការុងពណ៌សដែលខ្ញុំយកទៅដាក់ស្រូវ រួចហើយស្រែកបន្តទៀតថា «ស្អីគេសៗ» ប៉ុន្តែសំណាងល្អវាមិនឃើញមនុស្ស ហើយទាហានទាំងនោះក៏ដើរហួសទៅ ។ យើងម្នាក់ៗព្រលឹងចុងសក់ព្រោះនឹកថា បើវាចាប់បានមុខជាយកយើងទៅសម្លាប់ចោលជាមិនខាន ។

ខ្ញុំជឿជាក់ទៅលើព្រេងសំណាងរបស់ខ្ញុំ តាមពិតជីវិតខ្ញុំត្រូវអស់ច្រើនលើកច្រើនសាមកហើយ ព្រោះបើសិនក្រុមវាចុចពិលមើលតែបន្តិចពួកយើងមុខជាស្លាប់ ។ យើងក្រាបនៅជាប់នឹងភ្លឺស្រែ ហើយវាដើរជាន់លើកណ្តៀវនិងឈ្ងោកមើលការុងពណ៌ស ប៉ុន្តែមើលមិនឃើញមនុស្សក្រាបជង្គែគ្នានោះទេ ។ ក្នុងឆ្នាំនោះ អ្នកមូលដ្ឋានពុំសូវធ្វើបាបពួកអ្នកថ្មីទេ ព្រោះមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងចាស់ ដោយយកទាហានមកពីខេត្តផ្សេងមកនៅតំបន់នេះវិញ ចំណែកអ្នកចាស់មួយចំនួនក៏ត្រូវគេសម្លាប់ដោយចោទថា «ចូលដៃនឹងពួកខ្មាំង» ។

## មេក្របី

ក្រោយមក ខ្ញុំត្រូវប្រធានភូមិបញ្ជូនឲ្យទៅឃ្វាលក្របីនិងជួយបែនស្រូវនៅស្រែក្រោម ។ ពេលនោះ យើងហាក់ដូចជាមានអារម្មណ៍ថាស្ថានភាពស្រុកទេសមានការប្រែប្រួល ព្រោះអ្នកមូលដ្ឋានចេះតែខ្សឹបខ្សៀវគ្នាពីការផ្លាស់ប្តូរ ។ មិនយូរប៉ុន្មានខ្ញុំបានឮស្នូរគ្រាប់កាំភ្លើងធំក្តុងៗពីចម្ងាយ ធ្វើឲ្យម្នាក់ៗមានសេចក្តីត្រេកអរខ្លាំងណាស់ ប៉ុន្តែពុំមានអ្នកណាហ៊ានមាត់កឡើយ ។ ប៉ុន្មានថ្ងៃក្រោយមកស្រាប់តែប្រជាជននាំគ្នាឡើងពីស្រែមកកាន់រោងស្នាក់នៅ រួចនាំគ្នារៀបចំអីវ៉ាន់ត្រឡប់ទៅភូមិវិញ ។ ពេលនោះខ្ញុំមិនយល់ពីហេតុការណ៍និងរឿងប្រទេសជាតិអ្វីទេ ដោយខ្ញុំចេះតែដើរតាមចាស់ៗ ហើយពេលនោះខ្ញុំមានមេក្របីមួយក្បាលដែលអង្គការឲ្យមើលថែ ខ្ញុំក៏ជិះលើខ្នងក្របីត្រឡប់មកភូមិវិញដែរ ។ ពេលនោះ ថ្ងៃជ្រេទៅហើយ យើងត្រូវធ្វើដំណើរទាំងយប់ ហើយដោយអស់កម្លាំងនិងហេវហត់ខ្លាំង ខ្ញុំក្រាបដេកនៅលើខ្នងក្របីមួយយប់ទើសភ្លឺទើបបានមកដល់ភូមិវិញ ។ តាមពិតខ្ញុំមានសំណាងជាងអ្នកដទៃ ព្រោះបានជិះក្របីរហូតមកដល់ភូមិ ។ មកដល់ផ្ទះពេលខ្ញុំឃើញម្តាយខ្ញុំបានរៀបចំបង្កើចអង្ករសម្រាប់ហូបតាមផ្លូវ ខ្ញុំរើសបានកង់ម៉ូតូពីរ រួចហើយក៏រៀបចំធ្វើរទេះសម្រាប់ដាក់អីវ៉ាន់អូសត្រឡប់ទៅភូមិកំណើតគាត់វិញ ។

## សល់តែសម្បកខ្លួន

ម្តាយខ្ញុំ និងកូន៨នាក់ ដែលមានបងស្រី២នាក់ ខ្ញុំ និងប្អូនប្រុស អាញ៉ូ បានរៀបចំរទេះឈេ ទី ពេលនោះដោយសារម្តាយខ្ញុំជាកូនអ្នកចម្ការ ម៉្លោះហើយគាត់មានទេពកោសល្យក្នុងការផ្សារ

មួយចំនួនដែលមនុស្សប្រុសធ្វើបាន ។ ខ្ញុំនិងម៉ាក់យកឈើនិងខ្នងកង់រួចដឹកឡើងជារទេះដាក់ស្រូវអង្ករខ្លះទុកសម្រាប់ហូបតាមផ្លូវ ។ យើងចេញដំណើរភ្លាមៗ ព្រោះមិនចង់ឃើញភូមិនេះទៀតទេ ។ យើងធ្វើដំណើរតាំងពីពេលព្រឹកព្រលឹម រហូតពេលល្ងាចទើបយើងឈប់សម្រាក និងដាំបាយហូប ។

យើងដើរអស់រយៈពេល១៥ថ្ងៃទើបដល់កំពង់ធំ ។ ខ្ញុំមានការសោកស្ដាយចំពោះកំហុសខ្លះដែលខ្ញុំបានធ្វើចំពោះម៉ាក់ក្នុងពេលធ្វើដំណើរ ព្រោះពេលខ្ញុំខឹងម៉ាក់ម្ដងៗ ខ្ញុំបានយកដែកក្ងៀរទេះទៅជាមួយដើម្បីកុំឲ្យគាត់ធ្វើដំណើរទៅមុខ ។ តាមពិតទៅចរិតក្មេងពុំមានការគិតគូរអំពីខុសត្រូវ ហើយធ្វើតាមតែចិត្តនឹកឃើញប៉ុណ្ណោះ ។ មកដល់ក្រុងកំពង់ធំយើងត្រូវសម្រាកនៅទីនោះជាច្រើនយប់ទៀត ដើម្បីរង់ចាំរថយន្តរបស់កងទ័ពវៀតណាមដឹកជញ្ជូនត្រឡប់ទៅខេត្តកំពង់ចាមវិញ ។ យើងបានឡើងឡានរួចមកចុះនៅក្រុងកំពង់ចាម ។

អស់រយៈពេលប្រាំមួយឆ្នាំ ទើបខ្ញុំបានមកឃើញផ្ទះដែលខ្ញុំបានកើតនិងរស់នៅពីតូចកន្លងមក ដោយខ្មែរក្រហមគាស់យកក្ដារឈើអស់រលីងនៅសល់តែគ្រោងផ្ទះប៉ុណ្ណោះ ។ ម្ដាយខ្ញុំពុំដឹងជាមានអារម្មណ៍បែបណាទេនៅពេលដែលបាត់បង់ជីវិតប៉ាខ្ញុំនិងបងស្រី ហើយបាត់ផ្ទះដែលគាត់ខិតខំសន្សំលុយ កាក់ទម្រាំបានទិញ ។ យើងត្រូវដេកនៅក្រោមសំយាបផ្ទះខ្លួនឯង ។ ម្ដាយខ្ញុំមិនដឹងគិតយ៉ាងដូចម្ដេចទេ ណាមួយកូននៅតូចៗ ចំណែកខ្លួនជាស្ត្រីមេម៉ាយ ។ ម៉ាក់ក៏សម្រេចចិត្តថា ត្រឡប់ទៅនៅផ្ទះ កុងស៊ីន់ ចាំគិតគតទៅទៀត ។ នៅពេលនោះ ស្រាប់តែឮដំណឹងមកថា មនុស្សទាំងអស់ដែលនៅក្នុងផ្ទះ កុងស៊ីន់ ត្រូវគេសម្លាប់អស់ហើយ ។

ម្ដាយខ្ញុំមិនជឿព័ត៌មាននេះទេ តែគាត់តក់ស្លុតក្នុងចិត្តខ្លាំងណាស់ ។ ខ្ញុំមិនដឹងថាក្នុងចិត្តរបស់គាត់ឈឺចាប់ប៉ុនណាទេនៅពេលដែលព្រាត់ប្រាស់គ្រួសារស្ទើរតែអស់ទៅហើយនោះ ។ ពេលនោះ ខ្ញុំមិនចាំថាត្រូវធ្វើដំណើរអស់ប៉ុន្មានថ្ងៃទើបមកដល់ផ្ទះកុងស៊ីន់ ទេ ។ ពេលចូលមកដល់ក្នុងរបងផ្ទះភ្លាម ម៉ាក់ទ្រហោយំព្រោះអ្នកដែលចេញមកទទួលគាត់នោះគឺជាប្អូនជីដូនមួយគាត់ដែលនៅរស់ ហើយមករស់នៅផ្ទះកុងខ្ញុំ ព្រោះម៉ាក់នឹកថាមនុស្សក្នុងគ្រួសារកុងស្លាប់គ្មានសល់ម្នាក់ទេ ។ ក្រោយមកទើបដឹងថាបងប្អូនម៉ាក់នៅរស់បងប្រុសម្នាក់និងប្អូនប្រុសបីនាក់ដែលនៅភូមិផ្សេងពីនោះ ចំណែកប្អូនស្រីគាត់ពីរនាក់ដែលនៅទីនេះត្រូវខ្មែរក្រហមសម្លាប់ចោលទាំងគ្រួសារតែម្ដង ។ ប្អូនប្រុសពៅម៉ាក់ម្នាក់ដែលនៅរស់ពីការសម្លាប់នេះបានរត់ចូលព្រៃ ប៉ុន្តែក្រោយមកក៏ចាញ់យោសនាកងទ័ពព្រៃ ហើយត្រូវទាហានវៀតណាមបាញ់គ្រាប់បែកសម្លាប់នៅក្បែរភូមិនោះដែរ ។ ពេលទទួលដំណឹងថាប្អូនពៅស្លាប់ ម្ដាយខ្ញុំទ្រហោយំផង សើចផងហាក់បីដូចជាមនុស្សឆ្កួត ព្រោះម៉ាក់ទើបបានជួបប្អូនពៅប៉ុន្មានថ្ងៃមុនប៉ុណ្ណោះ មិននឹកស្មានថា គាត់ស្លាប់ដូច្នេះសោះ ។ ពេលនោះ ខ្ញុំមិនអាចរៀបរាប់ពីអារម្មណ៍ឈឺចាប់របស់ម្ដាយខ្ញុំបាននោះទេ ខ្ញុំបានត្រឹមតែអង្គុយយំជាមួយគាត់ប៉ុណ្ណោះ ។

ក្រោយមក ម៉ាក់ឃើញប្រជាជនធ្វើដំណើរទៅភ្នំពេញហើយបានអង្ករត្រឡប់មកភូមិវិញ គាត់ក៏សម្រេចចិត្តនាំកូនៗដើរទៅភ្នំពេញដែរ ដើម្បីទៅមើលថាតើយើងអាចរស់នៅកន្លែងនោះទេ ។ ម៉ាក់និងខ្ញុំដើរបីថ្ងៃបីយប់ទើបដល់ភ្នំពេញ នៅពេលនោះមនុស្សប្រុសៗដែលមានកម្លាំងបានចូលទៅក្នុងក្រុងយកបានកង់និងរបស់ផ្សេងៗល្អៗយកមកដូរអង្ករបានច្រើនណាស់ ។ ចំណែកម៉ាក់និងខ្ញុំពុំស្គាល់កន្លែងទុកសម្ភារទេ និងមានកម្លាំងខ្សោយ ដូច្នេះរើសបានតែសំបកដបយកទៅដូរអង្ករបានតែបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយសារគ្មានបងប្អូននៅភ្នំពេញ ហើយពិបាកក្នុងការស្នាក់នៅនិងការហូបចុកផង ម៉ាក់ក៏សម្រេចចិត្តត្រឡប់មកផ្ទះនៅភូមិអូរឡោងវិញ ។ ជីវិតខ្ញុំរសាត់អណ្ដែតគ្មានកោះត្រើយនិងត្រូវជួបបញ្ហាជាច្រើនទៀតក្នុងជីវិតយុវវ័យរបស់ខ្ញុំ ។

រឿងរ៉ាវដែលកើតឡើងនៅក្នុងភូមិចក សង្កាត់កំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ បានធ្វើឲ្យម្ដាយខ្ញុំ បងប្អូនខ្ញុំចងចាំនូវការឈឺចាប់ ទុក្ខសោក និងការបាត់បង់គ្រួសារដែលមិនអាចបំភ្លេចបាន ។ គ្រួសារនីមួយៗនៅសល់តែមនុស្សស្រីនិងក្មេងៗប៉ុណ្ណោះ ចំណែកមនុស្សប្រុសបានស្លាប់ស្ទើរទាំងអស់ ដោយការធ្វើការហួសកម្លាំង ការអត់អាហារ ជំងឺ និងត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ គ្រួសារខ្លះទៀតស្លាប់ទាំងអស់តែម្ដងដូចជាគ្រួសារបងស្រីខ្ញុំប្រាំនាក់ប៉ា បងមុំ និងគ្រួសារសាច់ញាតិខ្ញុំជាច្រើននាក់ទៀត ។ **ថៃ ច័ន្ទរិទ្ធ**

# ការឈឺចាប់បានរសាយ

ចាប់តាំងពីតុលាការខ្មែរក្រហមបានប្រកាសសាលក្រមកាត់ទោស ឌុច ដែលជាប្រធានគុកទួលស្លែងឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំមក ឪពុករបស់ខ្ញុំមានអារម្មណ៍ធូរស្បើយយ៉ាងខ្លាំងពីព្រោះគាត់យល់ថាតុលាការនេះពិតជាអាចរកយុត្តិធម៌ជូនជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសបានផ្សះផ្សារបួសផ្លូវចិត្តរបស់អ្នកដែលបានឆ្លងកាត់របបនេះ ។

ឪពុករបស់ខ្ញុំឈ្មោះ ស៊ិន វ៉ាត និងម្តាយឈ្មោះ តាំង មួយចេង សព្វថ្ងៃរស់នៅភូមិក្រូចឆ្មារ ឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ មុនឆ្នាំ១៩៧៥ គ្រួសាររបស់ឪពុកខ្ញុំរស់នៅស្រុកសំពៅមាសខេត្តពោធិ៍សាត់ ។ នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងនៅក្នុងស្រុកនេះ គ្រួសាររបស់ឪពុកខ្ញុំដែលមានសមាជិកទាំងអស់ដប់ពីរនាក់ និងគ្រួសារដទៃទៀតត្រូវបានជម្លៀសឲ្យទៅរស់នៅស្រុកភ្នំក្រវាញ ។ តាមផ្លូវធ្វើដំណើរ ឪពុករបស់ខ្ញុំបានឃើញទាហានខ្មែរក្រហមឈរចាំឆែកឆេរអីវ៉ាន់របស់ប្រជាជនដើម្បីដាក់ជាកម្មសិទ្ធិរបស់អង្គការ ។ ធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ គ្រួសារឪពុកខ្ញុំក៏បានមកដល់ភូមិតាដេះ ឃុំសំរោង ។ នៅទីនោះ អង្គការបានបែងចែកឲ្យពួកគាត់ធ្វើការទៅតាមកងផ្សេងៗពីគ្នា ។

ដោយសារតែអង្គការស៊ើបដឹងថា ក្រុមគ្រួសាររបស់ឪពុកខ្ញុំធ្លាប់ធ្វើជាគ្រូបង្រៀន អង្គការបានបែងចែកឲ្យពួកគាត់រស់នៅដាច់ដោយឡែកពីប្រជាជនចាស់ ហើយថែមទាំងដាក់គ្រួសាររបស់គាត់នៅក្នុងការតាមដានទៀត ។ បន្ទាប់មក ឪពុកខ្ញុំដែលមានអាយុទើបតែ១៨ឆ្នាំត្រូវបានបង្ខំឲ្យចូលកងចល័តយុវជនដែលមានសមាកជិកប្រហែល២០០នាក់ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ នាង ដែលជាជនជាតិចាម ។ អង្គការបានបង្ខំឲ្យឪពុករបស់ខ្ញុំជីកប្រឡាយ លើកទំនប់ និង ដាំកប្បាស ។ ដោយសារតែប្រធានកងនោះកាចនិងតែងតែបង្ខំឲ្យប្រជាជនធ្វើការឲ្យទាន់តាមផែនការរបស់អង្គការ ដូច្នេះទោះបីជាឪពុកខ្ញុំធ្វើការហេវហត់អស់កម្លាំងនិងឈឺយ៉ាងណាក៏ដោយ ក៏គាត់មិនដែលហ៊ានសុំច្បាប់ឈប់សម្រាកឡើយ ដើម្បីកុំឲ្យអង្គការស្តីបន្ទោស ។ ឪពុកខ្ញុំរៀបរាប់ឲ្យដឹងថា ថ្ងៃមួយអង្គការបានផ្លាស់ការងារគាត់ឲ្យទៅបញ្ជាន់ស្រូវនៅក្នុងសហករណ៍មួយឆ្ងាយពីភូមិ ។ នៅពេលនោះគាត់ក៏បានជួបជាមួយឪពុករបស់គាត់ រួចគាត់បានហុចសំបុត្រមួយច្បាប់ឲ្យឪពុកខ្ញុំដែលបានរៀបរាប់ថា «កូន! ពេលនេះបងស្រីរបស់កូនកំពុងតែមានជំងឺធ្ងន់ណាស់ ឪពុកមិនបានទៅសួរសុខទុក្ខទេពីព្រោះឪពុកកំពុងតែមានជំងឺហើម ដូច្នេះសូមកូនទៅមើលបងជំនួសឪពុកផង» ។ ក្រោយពីឪពុកខ្ញុំមើលសំបុត្រនេះរួច គាត់ក៏ប្រញាប់ប្រញាល់ធ្វើដំណើរត្រឡប់ទៅកាន់សហករណ៍វិញភ្លាម ។

មួយឆ្នាំក្រោយមក ជីដូនឪពុកខ្ញុំឈ្មោះ សៀន ក៏បានស្លាប់ដោយសារអត់អាហារនិងជំងឺរាកមួល ។ មិនយូរប៉ុន្មាន បងស្រីរបស់ឪពុកខ្ញុំឈ្មោះ ស៊ិន រស្មី ក៏មានជំងឺគ្រុនញាក់យ៉ាងខ្លាំងរហូតអង្គការបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកំពង់ជីរស្ថិតនៅឃុំសំរោង ស្រុកភ្នំក្រវាញ ។ នៅទីនោះដោយសារតែគ្មានគ្រូពេទ្យពិនិត្យជំងឺឲ្យបានដិតដល់ មួយរយៈក្រោយមកបងស្រីឪពុកខ្ញុំក៏ស្លាប់ទៅ ។ មួយថ្ងៃក្រោយមក នៅពេលដែលឪពុកខ្ញុំត្រឡប់ទៅកាន់សហករណ៍របស់គាត់ អ្នកជិតខាងម្នាក់បាននិយាយប្រាប់ឪពុករបស់ខ្ញុំថា «បងស្រីរបស់ក្មួយបានស្លាប់ទៅហើយ» ។

ចំណែកលោកយាយរបស់ខ្ញុំវិញឈ្មោះ ព្រំ សៀម នៅពេលដែលបានឮដំណឹងថាកូនស្រីស្លាប់ គាត់បានសុំការអនុញ្ញាតពីប្រធានសហករណ៍ដើម្បីមកមើលកូន ។ បន្ទាប់មក លោកយាយខ្ញុំបានសុំឲ្យអ្នកនៅកងជាមួយគាត់ដែលចេះអុំទូកជីកសាកសពកូនយកទៅកប់ ។ លោកយាយខ្ញុំបានយំសោកស្តាយអាណិតកូនជាខ្លាំងព្រោះមិនបាននៅមើលថែទាំជាលើកចុងក្រោយ ។ ក្រោយពីកប់សាកសពកូននៅក្នុងព្រៃរួចមក មិនយូរប៉ុន្មានប្អូនប្រុសឪពុកខ្ញុំឈ្មោះ ស៊ិន សុខា ហៅ (ម៉ាប់) ក៏ត្រូវស្លាប់ទៀតដោយសារតែមានជំងឺហើមនិងគ្រុនចាញ់ ។

ថ្ងៃមួយ នៅពេលអង្គការដឹងថាឪពុកខ្ញុំជាកុមារកងចល័ត

ប្រធានកងឈ្មោះ ឆន បានបង្អត់បាយឪពុករបស់ខ្ញុំ ។ ខ្មែរក្រហមមិនត្រឹមតែមិនឲ្យគាត់ហូបបាយប៉ុណ្ណោះទេ ថែមទាំងកំណត់ឲ្យឪពុកខ្ញុំនិងសមាជិកកងរបស់គាត់កាប់ដីដែលមានទទឹងប្រាំម៉ែត្រនិងបណ្ដោយហាសិបម៉ែត្រឲ្យហើយក្នុងមួយថ្ងៃ បើមិនអីចឹងទេនឹងត្រូវទទួលទណ្ឌកម្មជាមិនខាន ។ ដូច្នេះហើយឪពុកខ្ញុំនិងសមាជិកកងរបស់គាត់បាននាំគ្នាក្រោកពីព្រលឹមដើម្បីធ្វើការឲ្យទាន់ផែនការរបស់អង្គការ ។ ប៉ុន្តែ ទោះបីជាឪពុកខ្ញុំធ្វើការទាន់ផែនការហើយក៏ដោយ ក៏អង្គការនៅតែបន្ថែមការងារឲ្យគាត់ទៀតដដែល ។ ដោយសារការខិតខំប្រឹងប្រែងធ្វើការខ្លាំងពេក មួយរយៈក្រោយមកឪពុករបស់ខ្ញុំកើតជំងឺគ្រុនញាក់ថែមទាំងមិនអនុញ្ញាតឲ្យឈប់សម្រាកទៀតផង ។

មិនយូរប៉ុន្មាននៅពេលដែលកងទ័ពខាងតំបន់និរតីបានចូលគ្រប់គ្រងនៅក្នុងតំបន់នេះ ការរស់នៅកាន់តែមានការរឹតបន្តឹងជាងមុនទៅទៀត ដោយអង្គការបានយកប្រជាជនដែលមកពីខេត្តស្វាយរៀង អ្នកមានសញ្ជាតិវៀតណាម និងអ្នកជាប់និន្នាការជាទាហានទៅសម្លាប់ចោលទាំងអស់ ។ ឪពុកខ្ញុំនិយាយថា ពេលនោះនារីម្នាក់ដែលធ្លាប់រៀនជាមួយគាត់កាលពីមុនត្រូវបានអង្គការយកទៅសម្លាប់ក្រោយពីស៊ើបដឹងថានារីនោះមានសញ្ជាតិវៀតណាម ។

ចំណែកមិត្តភក្តិរបស់ឪពុកខ្ញុំម្នាក់ ឈ្មោះ ផល បានចងកសម្លាប់ខ្លួននៅគុម្ពឫស្សីដែរ ព្រោះតែខ្លាចអង្គការយកគាត់ទៅសម្លាប់នៅពេលស៊ើបដឹងថាគាត់ធ្វើជាទាហាន ។ ក្រោយមកអង្គការបានចាត់តាំងឪពុករបស់ខ្ញុំឲ្យឃ្វាលក្របីនៅឆ្ងាយពីភូមិរយៈពេលប្រាំខែ ។ នៅទីនោះ ឪពុកខ្ញុំតែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះគាត់តែងតែឃើញ ពូនាង ដែលជាប្រធានកងឈ្លបសំលៀងកាំបិតជាញឹកញាប់ដោយប្រាប់ថាយកទៅសម្លាប់សត្វឈ្លូស ប៉ុន្តែតាមពិត ពូនាង បានសម្លាប់មនុស្សរួចហើយដោយគាត់ឃើញកាំបិតមានស្នាមឈាមប្រឡាក់ហើយ ។

ក្រោយពេលដែលវៀតណាមបានចូលមករំដោះនៅក្នុង ១៩៧៩ ឪពុករបស់ខ្ញុំបានជួបជុំជាមួយក្រុមគ្រួសាររបស់គាត់វិញ ។ ទោះបីជារបបនេះបានកន្លងផុតទៅអស់រយៈពេលជាង៣១ឆ្នាំហើយក៏ដោយ ក៏ឪពុករបស់ខ្ញុំមិនដែលភ្លេចនូវបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅក្នុងរបបនេះដែរ ។ បន្ទាប់ពីជួបជុំគ្នាបានមួយរយៈ ជីតាខ្ញុំឈ្មោះ ស៊ិន មុត បានទទួលអនិច្ចកម្មដោយសារជំងឺ ។ នៅក្នុងឆ្នាំ១៩៨៥ ឪពុកខ្ញុំក៏បានរៀបការជាមួយម្ដាយខ្ញុំនិងប្រកបរបររកស៊ីបន្តិចបន្តួចដើម្បីចិញ្ចឹមកូនចំនួនបីនាក់រហូតមកដល់សព្វថ្ងៃនេះ ។ **ស៊ិន សុធីតា**



ក្រុមគ្រួសាររបស់ ស៊ិន សុធីតា

# ការរួចរស់ជីវិតពីសង្គ្រាម

ឪពុករបស់ខ្ញុំឈ្មោះ ស ឈឺន អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិព្រែកនរិន្ទ ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ សព្វថ្ងៃនេះ គាត់រស់នៅភូមិឃុំនេះដដែល ។

នៅឆ្នាំ១៩៦០ ឪពុករបស់ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាក្តាំងផា (ខេត្តបាត់ដំបង) ។ ក្រោយមក ដោយសារតែជីវភាពគ្រួសារខ្វះខាតពេក ឪពុកខ្ញុំបានសម្រេចចិត្តឈប់រៀនត្រឹមថ្នាក់ទី៦ (ចាស់) ដើម្បីមកជួយធ្វើស្រែឪពុកម្តាយ ។ ប៉ុន្តែប្រហែលកន្លះឆ្នាំក្រោយមក គាត់ក៏ត្រឡប់មកចូលរៀនវិញដើម្បីបង្កើនចំណេះដឹងបន្ថែមទៀត ។ នៅឆ្នាំ១៩៦៨ ជីតារបស់ខ្ញុំបានឲ្យគាត់ទៅបួសជាព្រះសង្ឃនៅវត្តឯករង្សីស្ថិតនៅភូមិព្រែកនរិន្ទ ដើម្បីតបស្នងសងគុណឪពុកម្តាយ និងបន្តការសិក្សានៅទីក្រុងបាងកកប្រទេសថៃ ។ នៅទីនោះ ដោយសារតែឪពុករបស់ខ្ញុំរៀនពូកែទាំងអក្សរខ្មែរ និងធម៌អាថ៌ផង ព្រះចៅអធិការវត្តឈ្មោះ តាទូច ក៏បានឲ្យគាត់ជួយបង្រៀនព្រះសង្ឃចំនួន៣០អង្គនៅវិទ្យាល័យពុទ្ធិកៈបន្ថែមទៀត ។ លោកតា ទូច តែងតែប្រាប់គាត់ថា «ឈឺន ឯងចេះប៉ុណ្ណឹងបានហើយ មិនចាំបាច់ទៅរៀនទៀតទេ» ។ ឮដូច្នេះ គាត់នៅស្ងៀមមិនហ៊ានប្រកែកជាមួយព្រះចៅអធិការឡើយ ។ បង្រៀននៅទីនោះបានរយៈពេល១ឆ្នាំ គាត់ក៏សុំព្រះចៅអធិការសឹក ដោយប្រាប់ថា «ខ្ញុំចង់ទៅរៀនបន្ថែមទៀត» ។ បន្ទាប់ពីលាចាកសិក្ខាបទ គាត់បានទៅរៀនគ្រូរគៀមនៅសាលាវិទ្យាល័យមុនីវង្សប្រហែលកន្លះឆ្នាំ ដើម្បីត្រៀមចូលថ្នាក់ទី៥ (ចាស់) ។ ទន្ទឹមពេលជាមួយគ្នានោះដែរ គាត់ក៏បានដាក់ពាក្យចូលធ្វើការនៅរោងចក្រក្រចៅ និងរោងចក្រកិនស្រូវក្នុងខេត្តបាត់ដំបង ។ ប្រហែលមួយសប្តាហ៍ រោងចក្រទាំងពីរនោះបានហៅគាត់ឲ្យចូលបម្រើការងារជាបន្ទាន់ ។ ពេលនោះ គាត់សម្រេចចិត្តបោះបង់ការសិក្សា ហើយចូលបម្រើការងារនៅរោងចក្រកិនស្រូវតែអាន ដើម្បីបានលុយខ្លះមកផ្គត់ផ្គង់គ្រួសារ ។ នៅទីនោះ ថៅកែគាត់បានចាត់តាំងឲ្យធ្វើជាអ្នកជជុះបាវ ប្រហែលមួយសប្តាហ៍ដំឡើងឋានៈជាអ្នកប៉ាន់ស្រូវ និងរយៈពេល២ឆ្នាំក្រោយមកជាអ្នកត្រួតពិនិត្យបញ្ជីរោងចក្រ ។



ឪពុកម្តាយ ស សេងតា

នៅឆ្នាំ១៩៧២ ដោយសារតែឪពុករបស់ខ្ញុំធ្វើការបានល្អ ថៅកែរោងចក្របានផ្សំផ្គុំក្មួយស្រីរបស់គាត់ឈ្មោះ លឹម គីមអ៊ាង ត្រូវជាម្តាយបង្កើតរបស់ខ្ញុំឲ្យរៀបការជាមួយគាត់ ។ នៅឆ្នាំ១៩៧៣ គាត់ត្រូវបានដំឡើងតួនាទីជាអ្នកគ្រប់គ្រងទូទៅ និងឆ្នាំ១៩៧៤ ជាអនុប្រធានរោងចក្រ ។

នៅឆ្នាំ១៩៧៥ ក្រោយពីខ្មែរក្រហមបានឡើងកាន់កាប់អំណាច ប្រធានសហករណ៍ឈ្មោះ យុត ធឿន បានជម្លៀសម្តាយខ្ញុំឲ្យដើរទៅស្រុកថ្មគោល ។ ពេលដឹងថាម្តាយខ្ញុំចេញទៅតែម្នាក់ឯង ឪពុកខ្ញុំបានរៀបចំអីវ៉ាន់យ៉ាងប្រញាប់ប្រញាល់ចាកចេញ

ដោយនាំបងស្រីទីពីរឈ្មោះ ស៊ីណាង អាយុប្រហែល២ឆ្នាំ និង បងស្រីទីមួយឈ្មោះ ស៊ីនួន មានអាយុប្រហែល៥ឆ្នាំទៅជាមួយ ។ ធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ឪពុកខ្ញុំក៏បានជួបជាមួយម្តាយខ្ញុំវិញ ។ ពេលដើរមកដល់ភូមិវាលទ្រាតាមបណ្តោយផ្លូវជាតិលេខ៥ ខ្មែរក្រហមបានបំបែកឪពុកខ្ញុំឲ្យភ្ជួរស្រែនៅទីនោះ ចំណែកម្តាយនិងបងស្រីរបស់ខ្ញុំទាំងពីរជម្លៀសឲ្យទៅនៅក្នុងព្រៃបឹងខ្មៅ ដែលជាតំបន់គ្រុនចាញ់ ។ នៅឆ្នាំ១៩៧៦ ប្រធានសហករណ៍បានដាក់ផែនការឲ្យគាត់ថាជានាយទុន ដោយសារកម្មករដែលបានធ្វើការនៅក្នុងរោងចក្រកិនស្រូវជាមួយគាត់ពីរនាក់ឈ្មោះ ឆុង និង គុជ បានមកប្រាប់ ធឿន ដែលជាប្រធានសហករណ៍ថាគាត់ធ្លាប់ធ្វើជាអនុប្រធានរោងចក្រកិនស្រូវ ។ នៅពេលនោះ ធឿន ស្រាប់តែមានបំណងចង់យកគាត់ទៅកសាង ។ ប៉ុន្តែព្រោះតែគាត់បានដឹងខ្លួនមុន គាត់ក៏សុំឲ្យបញ្ជូនគាត់ទៅធ្វើការឆ្ងាយពីភូមិ ។ ក្រោយពីប្រធានកងអនុញ្ញាត អង្គការបានដាក់គាត់ឲ្យនៅកម្លាំងជួរមុខ រួចបញ្ជូនទៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។ នៅទីនោះបានមួយរយៈ គាត់បានឮដំណឹងតាមរយៈប្អូនជីដូនមួយរបស់គាត់ឈ្មោះ បិល សំបូរ ដែលធ្វើជាគ្រូបង្រៀននៅមុខវត្តឯករង្សីបានប្រាប់គាត់ថា «សារ៉ាត់ ដែលជាឪពុកមារបស់គាត់ត្រូវខ្មែរក្រហមសម្លាប់បាត់ហើយ ដោយសារតែគាត់ចេះតែប្រឆាំងជាមួយអង្គការជាច្រើនលើកច្រើនសា ដោយអាងថា មានអ្នកភូមិស្រឡាញ់រាប់អានគាត់ច្រើន ព្រោះគាត់មើលជំងឺឲ្យអ្នកជិតខាងទាំងនោះបានជាសះស្បើយជាច្រើននាក់ ។ សំបូរ បានរៀបរាប់ពីព្រឹត្តិការណ៍នោះថា «ខ្មែរក្រហមបីនាក់មាន យុត ធឿន (បច្ចុប្បន្ននៅរស់) ដែលជាប្រធានសហករណ៍ ដោក យឿន ប្រធានឃុំ និង អេន ជាប្រធានឈ្លបបាននាំគ្នាមកចាប់គាត់ចងស្លាបសេក ហើយបណ្តើរទៅដល់មុខវត្តឯករង្សីក៏បាញ់សម្លាប់» ។ សារ៉ាត់ មិនទាន់ដាច់ខ្យល់ស្លាប់ផង គេក៏យកពូថៅមកពុះចំខ្នងពីក្រោយ រួចខ្វេះយកថ្លើមចេញមកខាងក្រៅ ដោយស្រែកថា «យកថ្លើមអាខ្មាំងទៅឆាស៊ី» ។ គ្រាន់តែឮភ្លាម គាត់ភ័យតក់ស្លុតជាខ្លាំងរហូតដល់សន្លប់បាត់ស្មារតី ។ សំបូរ បន្តថា «ពេលដែលគេចង់ចាប់ សារ៉ាត់ គាត់ក៏បានដឹងមុនដែរ តែគាត់មិនព្រមគេចខ្លួនទេ ដោយសារអង្គការគំរាមកំហែងក្រុមគ្រួសារគាត់ថា «បើសិនជាហ៊ានរត់គេចខ្លួននឹងចុះទៅចាប់សាច់ញាតិដែលពាក់ព័ន្ធទៅកម្ទេចចោលទាំងពូជ» ។ ដូច្នេះហើយទើប សារ៉ាត់ មិនព្រមរត់គេចទៅកន្លែងណាទេ ។

នៅឆ្នាំ១៩៧៧ ក្រោយពីឪពុកខ្ញុំត្រឡប់មកពីស្រុកគាស់ក្រឡ អង្គការបានតាមចាប់ខ្លួនរបស់គាត់ ។ ដោយសារតែគាត់បានដឹងខ្លួនមុន គាត់ក៏រត់គេចខ្លួន ។ ពេលនោះ អង្គការខឹងនឹងគាត់ជាខ្លាំង រហូតដាក់ផែនការគាត់ថា «អាខ្មាំងឲ្យតែឃើញពេលណាចាប់យកទៅកសាងពេលហ្នឹង» ។ លើសពីនេះទៅទៀត ពេលគាត់លួចចូលភូមិម្តងៗ ប្រធានសហករណ៍ចេះតែនាំគ្នាមកប្រជុំគ្នានៅផ្ទះគាត់ រួចប្រកាសប្រាប់ថា «នេះជាផ្ទះរបស់អាខ្មាំង» ។ ដោយសារតែភ័យខ្លាចខ្លាំងពេក ឪពុកខ្ញុំមិនដែលហ៊ានលួចមកជួបគ្រួសារទេ គឺតែងតែរត់ទៅលាក់ខ្លួននៅតាមវាលស្រែ និងព្រៃរហូត ។ នៅឆ្នាំ១៩៧៨ ឪពុកខ្ញុំត្រឡប់មកផ្ទះជួបជុំគ្រួសារបានពីរទៅបីថ្ងៃ មិត្ត ធឿន ក៏ជម្លៀសប្រជាជននៅក្នុងភូមិទាំងអស់ឲ្យទៅរស់នៅស្រុកថ្មគោល ចំណែកឪពុកម្តាយខ្ញុំត្រូវបានបញ្ជូនបន្តទៀតទៅដល់ស្រុកបវេល ។

រស់នៅទីនោះបានមួយរយៈ កងទ័ពវៀតណាមក៏ចូលមករំដោះ ។ នៅពេលត្រឡប់មកដល់ផ្ទះ ឪពុកខ្ញុំបានចេញទៅរកត្រីនៅភូមិមកដោះដូរអង្ករអ្នកស្រុកដើម្បីយកមកដាំបាយហូប ។ ក្រោយមក ដោយសារតែជីវភាពនៅតែមានការខ្វះខាតដដែល គាត់ក៏បានសម្រេចចិត្តបបួល ពូហាត និងគ្រូអាង (ស្លាប់) ចាកចេញពីផ្ទះទៅបើកអង្ករនៅជំរំព្រំប្រទល់ប្រទេសថៃ ។ ការចាកចេញនេះពិតជាត្រូវប្រថុយនឹងគ្រោះថ្នាក់ជាច្រើននៅតាមផ្លូវ ដោយត្រូវចំណាយពេលប្រហែល១សប្តាហ៍ ប៉ុន្តែបានអង្ករត្រឡប់មកវិញតែម្នាក់ចំនួន២០ទៅ៣០គីឡូក្រាមប៉ុណ្ណោះ ។ រយៈពេលជិតមួយឆ្នាំ ឪពុកខ្ញុំសន្សំប្រាក់ដែលបានពីការដូរអង្ករបន្តិចបន្តួចនេះទិញបានមេគោមួយក្បាល ។

នៅឆ្នាំ១៩៨៦ ប្រធានភូមិឈ្មោះ ចាត បានប្រមូលអ្នកភូមិមកប្រជុំ ហើយបានប្រកាសឲ្យឪពុកខ្ញុំធ្វើជាប្រធានយោធាភូមិ ។ ដោយសារតែឪពុកខ្ញុំនៅតែមានគំនិតចង់សងសឹកនឹងអ្នកដែលយកឪពុកមារបស់គាត់ទៅសម្លាប់ គាត់ក៏បានយល់ព្រមបំពេញតួនាទីនេះ ។ ក្រោយមក គាត់បានបញ្ឈប់គំនិតទាំងនេះចោល ដោយគិតឃើញថា «អ្នកទាំងនេះក៏ធ្វើតាមបញ្ជាគេដែរ

ម្យ៉ាងទៀតប្រសិនបើសង្រ្គាមប្អូនរបស់គាត់មិនរស់ឡើងវិញឡើយ ។ ដូច្នេះហើយគាត់បានតាំងចិត្តខិតខំដឹកនាំកូនក្រុមការពារសន្តិសុខភូមិយ៉ាងយកចិត្តទុកដាក់វិញប្រសើរជាង» ។

នៅឆ្នាំ១៩៨៧ ក្រោយពីឪពុកខ្ញុំត្រូវបានតែងតាំងជាប្រធានភូមិ ថ្នាក់លើបានកេណ្ឌកម្លាំងចំនួន៧៥នាក់ រួមទាំងឪពុកខ្ញុំឲ្យទៅសមរភូមិប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមដែលនៅសេសសល់ក្នុងក្រុងប៉ៃលិនចំនួនមួយខែកន្លះ ។ ប៉ុន្តែ ពេលចេញទៅតាមផ្លូវដល់ភ្នំសំពៅ កងទ័ពខ្មែរក្រហមស្រាប់តែមកវាយស្ទាក់ឡានរបស់គាត់ រហូតដល់ឃុំត្រែង ស្រុករតនៈមណ្ឌល ។ ដើម្បីទប់ទល់នឹងខ្មាំង ប្រធានកងពលលេខ៤បានតែងតាំងគាត់ខ្ញុំឲ្យធ្វើជាប្រធាន «ង» ដែលមានកូនទាហានចំនួន៧៥នាក់ ។ នៅទីនោះ មានការប្រយុទ្ធយ៉ាងក្តៅគគុករវាងគូបដិបក្ខរហូតបណ្តាលឲ្យមនុស្សស្លាប់ជាច្រើន ដោយក្នុងនោះក្រុមរបស់គាត់ចំនួន៥៥នាក់បានស្លាប់ និងរបួស១៣នាក់ នៅសល់តែឪពុកខ្ញុំ និង តាវឿន ជាប្រធានប៉ុណ្ណោះ ។ ដោយសារតែសាកសពច្រើនពេក និងសភាពការណ៍បន្ទាន់ផង ឪពុកខ្ញុំនាំគ្នារត់កាត់គ្រាប់សែងសាកសពអ្នកដែលស្លាប់ទាំងនោះដាក់ជាគំនរ ហើយដុត រួចខ្ចប់ឆ្អឹងជាកញ្ចប់ៗដាក់ចូលក្នុងសាក់កាដូរបស់គាត់ទុកយកមកផ្ញើគ្រួសារជនរងគ្រោះនៅស្រុកវិញ ។ មួយថ្ងៃៗមនុស្សស្លាប់និងរបួសកាន់តែច្រើនឡើងៗ ថ្នាក់លើក៏ចាត់ឲ្យគាត់ទាំងពីរនាក់បញ្ជូនអ្នករបួសទាំងនោះដាក់ឡានមកមន្ទីរពេទ្យខេត្តវិញ ។

ពេលត្រឡប់មកដល់ផ្ទះបានពីរ-បីថ្ងៃ ប្រធានសេនាជនឈ្មោះ ស៊ិន តុក បានតែងតាំងឪពុកខ្ញុំឲ្យធ្វើជាប្រធានយោធាស្រុកឯកភ្នំបណ្តោះអាសន្ន ។ ប្រហែលកន្លះខែក្រោយមក ប្រធានសេនាជនស្រុកបានចាត់តាំងឲ្យឪពុកខ្ញុំទៅជាមួយគាត់ប្រយុទ្ធជាមួយកងកម្លាំងខ្មែរក្រហមនៅភូមិក្បាលចោរ ដើម្បីការពារសន្តិសុខភូមិ ។ ពេលទៅដល់សមរភូមិ ស្រាប់តែកងកម្លាំងការពាររបស់គាត់បានបាក់ទ័ពត្រូវទាហានខ្មែរក្រហមបាញ់របួសនិងស្លាប់ជាច្រើន ។ ចំណែក ស៊ិន តុក និង ឪពុកខ្ញុំដែលកំពុងតែជិះនៅលើកាណូតនៅកណ្តាលព្រែកនៅក្នុងព្រៃក៏ស្ថិតនៅក្រោមការឡោមព័ទ្ធរបស់ទាហានខ្មែរក្រហមដែរ ។ ដោយសារតែស្ថានភាពច្របូកច្របល់ ស៊ិន តុក បានយកកាំភ្លើងភ្ជង់ឪពុកខ្ញុំ និងសំឡុតថា «អ្អែង! លោតចុះទឹក ហើយមុជរាវរកខ្មោចយកកាំភ្លើងឲ្យលឿនឡើង» ។ ពេលនោះ ឪពុកខ្ញុំតបវិញថា «មុជយ៉ាងម៉េចកើតបើខ្មាំងកំពុងតែបាញ់សន្ធប់យ៉ាងនេះ» ។ ស៊ិន តុក មិនត្រឹមតែមិនស្តាប់សម្តីរបស់ឪពុកខ្ញុំទេ ថែមទាំងគំរាមថា «បើមិនលោតចុះទេ អញបាញ់សម្លាប់ចោលឥឡូវហើយ» ។ ទោះជាស្ថានភាពគ្រោះថ្នាក់យ៉ាងណាក៏ដោយ ក៏ឪពុកខ្ញុំមិនព្រមធ្វើតាមបញ្ជាដែរ រួចក៏លើកគ្រាប់បេសាវ៉ែនតម្រង់ទៅ តុក ហើយនិយាយថា «លោកឯងមិនងើបឡើងបាញ់ទៅវិញដើម្បីរកផ្លូវរត់សិនទៅ នៅក្រាបក្បាលទូកធ្វើអីទៀត ងើបឡើងប្រយ័ត្នស្លាប់ទាំងអស់គ្នា» ។ ពេលនោះ ខ្មាំងបាញ់សន្ធប់ចេះតែខ្លាំងឡើងៗ គាប់ជួនមេឃងងឹតផង ហើយនៅសងខាងព្រែកនោះមានព្រៃដុះជុំវិញ ឪពុកខ្ញុំនឹកឃើញកាលគាត់នៅក្នុងសមរភូមិជួបជាមួយកងទ័ពវៀតណាមក៏ស្រែកសន្ធប់សំឡុតថា «ខាងជើងឡើង ខាងកើតព័ទ្ធ កុំបាញ់ ចាប់រស់ៗ» ។ ពេលនោះ កងទ័ពខ្មែរក្រហមបាក់ស្បាតភ័យស្មាន់ស្មោក៏នាំគ្នាដកទ័ពថយទៅវិញ ។ ឪពុករបស់ខ្ញុំមិនខឹងនឹងខ្មែរក្រហមប៉ុន្មានទេ ខឹងខ្លាំងជាងគេគឺអ្នកដែលគាំទ្រខ្មែរក្រហមទៅវិញព្រោះបានបន្សល់ទុកនូវពិការភាព ក្មេងកំព្រា និងព្រមទាំងខូចខាតហេដ្ឋារចនាសម្ព័ន្ធយ៉ាងសម្បើមដូចជា សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ និងអគារផ្សេងៗជាច្រើនទៀត ។ ឪពុកខ្ញុំរៀបរាប់ថា «ខ្ញុំមិនចង់សង្រ្គាមទៀតទេ ព្រោះប្អូនប្រុសរបស់ខ្ញុំមិនរស់ឡើងវិញឡើយ ។ ចុងក្រោយ ខ្ញុំសំណូមពរឲ្យអ្នកដែលគាំទ្រខ្មែរក្រហមនោះជួយកសាងសមិទ្ធផលឲ្យបានច្រើនឡើងវិញផង» ។

**ស សេងគា**

# គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# ជីតារបស់ខ្ញុំបន្ទត់បាយខ្លួនឯង

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនថាប្រជាជនឬកម្មាភិបាលខ្មែរក្រហមដែលបម្រើឲ្យរបបនេះទេតែងតែធ្វើតាមបញ្ជារបស់អង្គការជានិច្ចដើម្បីរក្សាជីវិតរបស់ខ្លួនឲ្យគង់វង្ស ។ ផ្ទុយស្រឡះពីអ្នកទាំងនេះ ជីតារបស់ ហេង ពៅ បែរជាសុខចិត្តសម្លាប់ខ្លួន ដោយការបន្ទត់បាយរបស់ខ្លួនឯងទៅវិញ ។

ពៅ បានរៀបរាប់ថា គ្រួសាររបស់គាត់មានស្រុកកំណើតនៅភូមិមហារាជ ឃុំបឹងត្រាញ់ត្បូង ស្រុកសំរោង ខេត្តតាកែវ ។ នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងភូមិនេះនៅឆ្នាំ១៩៧៣ គ្រួសាររបស់គាត់និងគ្រួសារដទៃទៀតនៅក្នុងភូមិមានការភ័យខ្លាចជាខ្លាំង ព្រោះខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនទាំងអស់រៀបចំអីវ៉ាន់ចាកចេញពីផ្ទះរបស់ខ្លួន រួចធ្វើដំណើរទៅឃុំជើងគួន ស្រុកសំរោង។ មួយសប្តាហ៍ក្រោយពីស្ថានភាពស្ងប់ស្ងាត់ ខ្មែរក្រហមក៏ប្រកាសឲ្យប្រជាជនដែលជម្លៀសទាំងអស់ត្រឡប់ទៅរស់នៅមូលដ្ឋានរបស់ខ្លួនវិញ ។ បន្ទាប់មក ខ្មែរក្រហមបានបែងចែកប្រជាជនទាំងអស់ឲ្យធ្វើការទៅតាមកងរៀងៗខ្លួន ដែលសូម្បីតែកូនក្មេងនិងមនុស្សចាស់ក៏តម្រូវឲ្យធ្វើការជូនអង្គការដែរ ។ ពៅ បន្តថា ដោយសារតែបង្ខំឲ្យធ្វើការស្ទើរគ្មានសម្រាក ពីរ-បីថ្ងៃក្រោយមក បងៗរបស់គាត់ក៏រត់គេចពីការងារត្រឡប់មកផ្ទះវិញ ។ ពេលនោះ មេកងខឹងជាខ្លាំងរហូតដល់ចង់យកគាត់ទៅធ្វើទារុណកម្មទៀតផង ។ ដោយសារតែបារម្ភខ្លាចក្រែងអង្គការយកទៅកូនទៅសម្លាប់ ឪពុកម្តាយរបស់ ពៅ តែងតែដេញកូនត្រឡប់ទៅកងវិញជានិច្ច ។

ចំណែក ឪពុកម្តាយរបស់ ពៅ ទោះបីជាគាត់ធ្វើការអស់កម្លាំងយ៉ាងណាក៏ដោយ ក៏គាត់ទាំងពីរនាក់មិនដែលរអ៊ូឡើយ ហើយថែមទាំងធ្វើការលើសផែនការកំណត់ទៀតផង ។ ជាក់ស្តែង គាត់បានឃើញមន្ទីរឃុំមួយកន្លែងសម្រាប់ឃុំអ្នកទោសដែលមានកំហុស ដូចជាលួចដំឡូង ឬសត្វរបស់អង្គការហូប ឬអ្នកដែលហៅទៅកសាងជាច្រើនលើកហើយនៅតែមិនស្តាប់ អង្គការនឹងចោទប្រកាន់ថាជាខ្មាំងបដិវត្តន៍ រួចចាប់យកទៅដាក់នៅមន្ទីរឃុំនេះ ។ លើសពីនេះទៅទៀត គាត់បានឃើញខ្មែរក្រហមបញ្ជាឲ្យប្រជាជនរែកទឹកស្រោចដំណាំនៅលើព្រះវិហារវត្តស្រះដីខ្ពស់នៅក្នុងភូមិបឹងត្រាញ់ជើង ដែលមួយរយៈក្រោយមកអ្នកទាំងនេះក៏ត្រូវស្លាប់ដោយសារតែបាក់កម្លាំង ។

ដោយសារការរស់នៅស្ថិតក្រោមការគាបសង្កត់ គ្មានសិទ្ធិសេរីភាព និងសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃបែបនេះ ជីតារបស់ ពៅ សុខចិត្តបន្ទត់បាយខ្លួនឯងជារៀងរាល់ថ្ងៃ ។ ពៅ បានរៀបរាប់ថា «ទោះបីជាមានការអង្វរករពីម្តាយរបស់ខ្ញុំឲ្យព្យាយាមហូបបបរដែលអង្គការចែកឲ្យក៏ដោយ ក៏គាត់មិនព្រមហូបដែរ ។ ដូច្នេះហើយ រយៈពេល១៥ថ្ងៃក្រោយមក គាត់ក៏ទទួលអនិច្ចកម្មទៅ» ។ ក្រោយពីស្លាប់ភ្លាម ឈ្លបខ្មែរក្រហមបានរុំសាកសពរបស់គាត់យកទៅបោះចោលភ្លាម ដោយមិនទៅរង់ចាំឲ្យម្តាយរបស់គាត់បានឃើញមុខជាលើកចុងក្រោយទេ ។ ពេលនោះ ម្តាយរបស់ ពៅ លួចយំ មិនឲ្យអង្គការដឹងឡើយ ។ ក្រោយមកប្រហែលជាឆ្នាំ១៩៧៧ ជីដូនរបស់ ពៅ ក៏ត្រូវស្លាប់ទៀតដោយសារតែជំងឺ ។

ពេលវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ គ្រួសាររបស់ ពៅ នាំគ្នាត្រឡប់មកលំនៅឋានវិញដោយមានដឹករបស់របរមួយចំនួនមកជាមួយទៀតផង ។ ទោះបីជា ពៅ កើតមិនទាន់របបខ្មែរក្រហមក៏ដោយ ប៉ុន្តែក្រោយពីឃើញភស្តុតាងដែលបន្សល់ទុកដូចជាលលាដ៏ក្បាលជាច្រើនដែលនៅសេសសល់ក្នុងភូមិ និងតាមរយៈការរៀបរាប់អំពីបទពិសោធន៍របស់ឪពុកម្តាយគាត់ធ្វើឲ្យ ពៅ ចង់សិក្សានិងស្រាវជ្រាវអំពីរបបនេះជាខ្លាំង ។ ពៅ បានបន្តថា «ក្រោយពីខ្ញុំប្រឡងជាប់ទុតិយភូមិភ្លាម ខ្ញុំក៏ដាក់ពាក្យធ្វើជាគ្រូបង្រៀនតែម្តង ។ ក្រោយមក ទោះបីជាខ្ញុំប្រឡងធ្លាក់ពីរលើកទៀតក៏ដោយ ក៏ខ្ញុំនៅតែតស៊ូប្រឡងធ្វើគ្រូរហូតដល់ខ្ញុំទទួលបានជោគជ័យ ដោយឥឡូវនេះខ្ញុំជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា និងភូមិវិទ្យានៅវិទ្យាល័យកោះស្រឡៅ» ។

**គាត លក្ខិណា**

# អៀង មី សួររកកូន និងក្មួយដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម

*លោកយាយ អៀង មី អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិដូនបុស ឃុំចម្ការអណ្តូង ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ លោកយាយមានកូនចំនួនប្រាំបួននាក់ ១) នុត សុង (ប្រុស) , ២) នុត សឿន (ប្រុស) , ៣) នុត សេត (ស្រី) , ៤) នុត សឿង (ស្រី) , ៥) នុត សឺន (ប្រុស) , ៦) នុត ស៊ឹម (ប្រុស) , ៧) នុត សំ (ប្រុស) , ៨) នុត គុល (ប្រុស) និង ៩) នុត ច្រិប (ស្រី) ។ លោកយាយមានស្រុកកំណើតនៅភូមិផ្លូវទទឹង ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ លោកយាយសូមប្រកាសសួររកកូនប្រុសឈ្មោះ នុត សុង ដែលមានអាយុ១៨ឆ្នាំ និងក្មួយរបស់គាត់ម្នាក់ទៀតឈ្មោះ ឡេង ខន អាយុ១៣ឆ្នាំ ដែលត្រូវបានប្រធានភូមិឈ្មោះ តាអ៊ុត (សព្វថ្ងៃស្លាប់) បង្ខំឲ្យចូលបដិវត្តន៍នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ភូមិនេះ ។ ពេលនោះ ដោយមិនចង់ឲ្យកូនចាកចេញឆ្ងាយ លោកយាយបានបដិសេធមិនឲ្យកូនទៅទេ ព្រមទាំងយំអង្វរថា «ក្មួយឯងបង្ខំយកកូនមីងទៅធ្វើអី បើយកទៅវាប្រាកដជាស្លាប់ហើយ ព្រោះកូនរបស់មីងនៅតូចណាស់» ។*

*នៅឆ្នាំ១៩៧៤ នៅពេលដែលអ្នកទាំងពីរត្រូវបានបញ្ជូនឲ្យទៅប្រយុទ្ធនៅសមរភូមិស្រុកលើ អ្នកទាំងពីរបានលួចរត់ត្រឡប់មកផ្ទះវិញដើម្បីព្យាបាលជំងឺ ។ ពេលដែលឃើញកូនមានរូបរាងស្គម និងមានជំងឺជាប់ខ្លួនបែបនេះ លោកយាយអាណិតកូនជាខ្លាំងដោយបានរកកន្លែងឲ្យកូនសម្ងំលាក់ខ្លួននៅក្នុងព្រៃទៀតផង ។ សម្រាកបានរយៈពេលបីថ្ងៃ ស្រាប់តែប្រធានភូមិឈ្មោះ អ៊ុត និងយោធាឈ្លបឈ្មោះ វ៉ើត មកតាមកូនរបស់គាត់ដល់ផ្ទះ ដោយប្រាប់ថា «មានពេទ្យគេមើលហើយ» ។ បន្ទាប់មក លោកយាយបានប្រាប់ថា «ឲ្យទៅធ្វើអី កូនរបស់ខ្ញុំឈឺបែបនេះ» ។ ឈ្លបទាំងពីរមិនបានស្តាប់សម្តីរបស់គាត់ទេ ដោយប្រាប់មកវិញថា «ឈឺក៏ដោយ គេយកទៅមើលខ្លួនគេ» ។*

*នៅឆ្នាំ១៩៧៦ កូនស្រីទីបីរបស់គាត់ឈ្មោះ នុត សេត បានជួប សុង នៅតាមផ្លូវទៅបារាយណ៍ម្តងទៀត ដោយពេលនោះគាត់ខូចឡាននៅកណ្តាលផ្លូវ ។ សេត ក៏បានសួរថា «បងឯងនៅហ្នឹងធ្វើអី ហើយតើបងឯងអត់ទៅលេងស្រុកទេឬ?» ពេលនោះបងប្រុសរបស់គាត់ឆ្លើយថា «បងខូចឡាន ។ បងអត់បានទៅទេ ព្រោះមានភារកិច្ចច្រើនណាស់» ។ ចាប់តាំងពីពេលនោះមក លោកយាយមិនដែលបានទទួលដំណឹងពីកូន និងក្មួយរបស់គាត់ឡើយ ។*

*ប្រសិនបើបងប្អូនណាបានស្គាល់ ឬមានដំណឹងពីកូន និងក្មួយរបស់លោយយាយ អៀង មី សូមមេត្តាទំនាក់ទំនងមកលោកយាយតាមរយៈទូរស័ព្ទលេខ ០៨៩ ៨១៧ ៩៩៦ ឬ ០៨៩ ៨១៧ ៩៩៧ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។*




***លោកយាយ អៀង មី និងកូនទីបី នុត សេត***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់ ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់ ៤) ភេទអ្នកស្លាប់ ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន) ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ ៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី) ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?) ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ ៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន ២) ភេទ ៣) អាយុ ៤) ត្រូវជាអ្វី ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ ៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ

ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 133, January 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.